ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**


**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**Chambres Extraordinaires au sein des Tribunaux Cambodgiens**

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**


**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No: 002/14-08-2006**

**លេខស៊ើបសួរ/Investigation/Instruction**
**លេខ/No: 001/18-07-2007-ECCC-OCIJ**

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះ កាំង ហ្គេកអ៊ាវ ហៅ ឌុច

# CLOSING ORDER indicting Kaing Guek Eav alias Duch

# ORDONNANCE DE RENVOI Kaing Guek Eav alias Duch

យើង **យូ ប៊ុនឡេង** និង **Marcel LEMONDE** (ម៉ាសែល ឡឺម៉ុង) សហចៅក្រមស៊ើបអង្កេតនៃអង្គជំនុំ-ជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក)

បានឃើញការបើកការស៊ើបសួរលើ៖

ឈ្មោះ **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** ភេទប្រុស កើតថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ១៩៤២

ត្រូវបានដាក់ឲ្យស្ថិតក្រោមការពិនិត្យចំពោះឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើសន្ធិសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩ បទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញ ចុះថ្ងៃទី ២៧ ខែតុលា ឆ្នាំ២០០៤

ត្រូវបានឃុំខ្លួន ដោយដីកាសម្រេចឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ៣១ ខែកក្កដា ឆ្នាំ ២០០៧ និង ដីកាសម្រេចបន្តការឃុំខ្លួនបណ្ដោះអាសន្ន ចុះថ្ងៃទី ២៨ ខែកក្កដា ឆ្នាំ ២០០៨

ដើមបណ្ដឹងរដ្ឋប្បវេណី: [២៨ នាក់]

បានឃើញដីកាសម្រេចបំបែកសំណុំរឿង ចុះថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៧

បានឃើញដីកាសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា ចុះថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ ២០០៨

បានឃើញសារណាតបរបស់មេធាវីការពារក្ដី ចុះថ្ងៃទី ២៤ ខែកក្កដា ឆ្នាំ ២០០៨

យល់ឃើញថា ការស៊ើបសួរបានបង្ហាញនូវអង្គហេតុដូចតទៅ៖

## សេចក្ដីផ្ដើម

១. នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យដែលបានគ្រប់គ្រងកម្ពុជាចាប់តាំងពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥នោះ បានដួលរលំ ហើយថ្នាក់ដឹកនាំទាំងអស់នៃរបបនេះដែលស្ថិតក្រោមបញ្ជារបស់ ប៉ុល ពត បានរត់ខ្ចាត់ខ្ចាយពីទីក្រុងភ្នំពេញ។ កងទ័ពវៀតណាមដែលបានចូលក្នុងទីក្រុងនាគ្រានោះ បានប្រទះឃើញមន្ទីរឃុំឃាំង និងកន្លែងសួរចម្លើយ ដែលទើបតែត្រូវបានគេបោះបង់ចោលនៅកណ្ដាលទីក្រុងភ្នំពេញ។ ក្រោយពេលចូលក្នុងបរិវេណនៃមន្ទីរនេះ កងទ័ពទាំងនោះបានឃើញមានសាកសពមួយចំនួន ដែលទើបត្រូវបានសម្លាប់ថ្មីៗ

ដែលនៅចងភ្ជាប់នឹងគ្រែដែក រួមទាំងឯកសាររាប់ពាន់សន្លឹកទៀតស្ថិតក្នុងសភាពរាយប៉ាយនៅខាងក្នុង និងនៅជុំវិញអគារ។ ទីកន្លែងនេះត្រូវបានគេស្គាល់ឈ្មោះថា **ទួលស្លែង** ដែលជាទីតាំងរបស់ "មន្ទីរស-២១" ដែលជាមន្ទីរសន្តិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា (បកក)។ នៅក្នុងអំឡុងពេលភាគច្រើននៃដំណើរការ មន្ទីរនេះត្រូវបានដឹកនាំដោយមនុស្សម្នាក់ឈ្មោះ **ឌុច** ដែលត្រូវបានកំណត់អត្តសញ្ញាណថាជាជនត្រូវចោទឈ្មោះ កាំង ហ្គេកអ៊ាវ។

២. **ឌុច** ដែលជាអតីតគ្រូបង្រៀនគណិតវិទ្យា បានចូលរួមជាសម្ងាត់ក្នុងកងកម្លាំងកុម្មុយនីស្តដែលត្រូវបានគេស្គាល់ឈ្មោះថា "ខ្មែរក្រហម" តាំងពីឆ្នាំ១៩៦៧ បន្ទាប់ពីមានការចាប់ខ្លួនកូនសិស្សគាត់៣នាក់។ គាត់ត្រូវបានចាប់ខ្លួននៅថ្ងៃទី ៥ ខែមករា ឆ្នាំ ១៩៦៨ និង ត្រូវបានផ្តន្ទាទោសឲ្យជាប់ពន្ធនាគាររយៈពេល ២០ឆ្នាំ ពីបទបង្កគ្រោះថ្នាក់ដល់សន្តិសុខជាតិ ដោយសារជាប់ពាក់ព័ន្ធជាមួយបរទេស។ ប៉ុន្តែ **ឌុច**ត្រូវបានដោះលែងវិញពីរបីសប្តាហ៍ក្រោយរដ្ឋប្រហារ ថ្ងៃទី ១៨ មីនា ឆ្នាំ១៩៧០ រួចគាត់ក៏បានបន្តសកម្មភាពបដិវត្តន៍បន្តទៅទៀត។ ក្នុងចន្លោះខែកក្កដា ឆ្នាំ១៩៧១ ដល់ខែមករា ឆ្នាំ១៩៧៥ **ឌុច** មានតួនាទីជាប្រធានមន្ទីរ ម១៣ ("ម១៣" ជាមន្ទីរសន្តិសុខមួយទៀតដែលស្ថិតនៅអមលាំង ខេត្តកំពង់ស្ពឺ) ហើយបំពេញការងារចាប់តាំងពីអំឡុងឆ្នាំ ១៩៧៣ ក្រោមបញ្ជារបស់ **A** និង សុន សេន ហៅ "បងខៀវ" "បង៨៩" ឬ "បង ៥០" ដែលខ្លួនគាត់ត្រូវបានតែងតាំងជានាយសេនាធិការកងទ័ពកុម្មុយនីស្តនៅឆ្នាំ១៩៧២។ បន្ទាប់មក ចាប់តាំងពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៩ **ឌុច**កាន់កាប់តួនាទីរបស់ខ្លួននៅស២១ គឺនៅពេលដែលគាត់មានអាយុ ចន្លោះពី ៣៣ឆ្នាំ ទៅ ៣៧ឆ្នាំ។

៣. ម្ភៃឆ្នាំក្រោយការរកឃើញមន្ទីរស-២១ ឌុចត្រូវបានគេរកឃើញគាត់រស់នៅតាសាញ់ ស្រុកសំឡូត(ខេត្តបាត់ដំបង) តាមរយៈការប្រើឈ្មោះមួយផ្សេងទៀត ។ តាមរយៈអត្ថបទសារព័ត៌មាននានា រួមមានទាំងបទសម្ភាសន៍ផង ឌុចបានលាតត្រដាងឈ្មោះពិត និងតួនាទីជាអតីតប្រធានមន្ទីរ ស-២១ ដូច្នេះសាធារណៈជនក៏បានដឹងអំពីទីកន្លែង ដែលគាត់កំពុងរស់នៅ។ ហេតុនេះហើយបានជានៅខែឧសភា ក្នុងឆ្នាំ១៩៩៩ ឌុចត្រូវបានតុលាការយោធាចាប់ខ្លួន និងឃុំខ្លួនក្នុងមន្ទីរឃុំឃាំង[1]។

## ការរំលឹកឡើងវិញអំពីនីតិវិធី

៤. នៅឆ្នាំ ២០០៦ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ដែលតទៅនេះហៅថា អ.វ.ត.ក) ត្រូវបានបង្កើតឡើងដើម្បីវិនិច្ឆ័យទោស មេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យនិង អ្នកដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅក្នុងប្រទេសកម្ពុជា ក្នុង អំឡុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃ៦ ខែមករា ឆ្នាំ១៩៧៩។ នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៦ សហព្រះរាជអាជ្ញាបានបើកការអង្កេតបឋមលើបឧក្រិដ្ឋកម្មទាំងនេះ។ នៅថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៧ ដោយអនុលោមតាមមាត្រា ៥៣ នៃវិធានផ្ទៃក្នុងនៃអង្គជំនុំ-ជម្រះ វិសាមញ្ញក្នុងតុលាការកម្ពុជា សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ ស៊ើបសួរ ដោយបានធ្វើការផ្តើមចោទជនជាប់សង្ស័យចំនួនប្រាំរូប ដែលក្នុងនោះរួមមានទាំង **ឌុច**[2]ផងដែរ អំពីអំពើឧក្រិដ្ឋកម្មនានា ដែលបានប្រព្រឹត្តនៅកន្លែងជាច្រើន។ ដូច្នេះសំណុំរឿង ត្រូវបានបញ្ជូនទៅការិយាល័យសហចៅក្រមស៊ើបអង្កេត ដើម្បីបើកការស៊ើបសួរ ស្របតាម វិធាន ៥៥។ នៅថ្ងៃទី៣០ ខែ កក្កដា ឆ្នាំ២០០៧ **ឌុច**ត្រូវបានសហចៅក្រមស៊ើបអង្កេត ចេញដីកាបង្គាប់ឱ្យឃុំខ្លួន និងត្រូវបានបញ្ជូនទៅឃុំខ្លួននៅក្នុងមន្ទីរឃុំឃាំងរបស់ អ.វ.ត.ក។ នៅក្នុងក្របខណ្ឌនៃកិច្ចស៊ើបសួរនេះ **ឌុច** ត្រូវបានដាក់ឱ្យស្ថិតក្រោមការពិនិត្យអំពីបទឧក្រិដ្ឋ ប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩[3]។

៥. ដោយពិនិត្យឃើញពីភាពចាំបាច់ក្នុងការធ្វើសេចក្តីសម្រេចឱ្យបានឆាប់រហ័សទាក់ទិននឹង **ឌុច** នៅថ្ងៃទី១៩ ខែកញ្ញា ឆ្នាំ២០០៧ សហចៅក្រមស៊ើបអង្កេតបានចេញដីកាបំបែកសំណុំរឿង ដែលពាក់ព័ន្ធនឹងការទទួលខុសត្រូវរបស់ **ឌុច** ទាក់ទិននឹងអង្គហេតុនានាដែលមានទំនាក់ទំនង ជាមួយនឹង ស ២១[4]។ អង្គហេតុផ្សេងទៀត ដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យ ស៊ើបសួរ ជាកម្មវត្ថុនៃការស៊ើបសួរដាច់ដោយឡែកដែលកំពុងតែដំណើរការ។

៦. នៅក្នុងអំឡុងពេលនៃការស៊ើបសួរ ដោយផ្អែកតាមវិធាន ២៣ មានបុគ្គលប្រាំបីរូបបានតាំងខ្លួន

ជាភាគីដើមបណ្តឹងរដ្ឋប្បវេណី ដែលក្នុងនោះមានអតីតអ្នកទោសនៃមន្ទីរស-២១ និងសមាជិកក្រុមគ្រួសារអតីតអ្នកទោសដែលត្រូវបានសម្លាប់នៅមន្ទីរនេះ។ ភាគីដើមបណ្តឹងរដ្ឋប្បវេណីចំនួន **១៥** រូបផ្សេងទៀតបានដាក់ពាក្យបណ្តឹងនៅចន្លោះពេលនៃការជូនដំណឹងអំពីការបញ្ចប់កិច្ចស៊ើបសួរ និងការបិទការស៊ើបសួរដោយដីកាដំណោះស្រាយនេះ[5]។

៧. ថ្ងៃទី ១៥ ខែឧសភា ឆ្នាំ ២០០៨ សហចៅក្រមស៊ើបអង្កេតបានជូនដំណឹងដល់ភាគីនានាថា ការស៊ើបសួរត្រូវបានបញ្ចប់[6]។ កាលពីថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៨ សហចៅក្រមស៊ើបអង្កេតបានបញ្ជូនសំណុំរឿងទៅការិយាល័យសហព្រះរាជអាជ្ញាដើម្បីពិនិត្យ និងសន្និដ្ឋានស្ថាពរស្របតាមវិធាន ៦៦[7]។

៨. កាលពីថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០០៨ ក្រោយពីបានពិនិត្យសំណុំរឿងរួច សហព្រះរាជអាជ្ញាបានចេញដីកាសន្និដ្ឋានស្ថាពរ ដោយស្នើឲ្យសហចៅក្រមស៊ើបអង្កេតធ្វើការចោទប្រកាន់ **ឌុច** និងបញ្ជូនទៅជំនុំជម្រះ ពីបទល្មើសប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ និងបទល្មើសដែលមានចែងក្នុងក្រមព្រហ្មទណ្ឌកម្ពុជាឆ្នាំ១៩៥៦[8]។ នៅថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៨ មេធាវីរបស់ឌុចបានដាក់សារណាឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានស្ថាពររបស់សហព្រះរាជអាជ្ញា។

៩. ភស្តុតាងនានា ដែលដាក់បញ្ចូលក្នុងសំណុំរឿងរួមមាន កំណត់ហេតុនៃការសួរចម្លើយ **ឌុច** ចំនួន ២១ កំណត់ហេតុនៃការស្តាប់យកចម្លើយសាក្សីជាច្រើននាក់ ដែលរួមមាន អតីតបុគ្គលិក និងអ្នកទោសនៅមន្ទីរស-២១ របាយការណ៍នៃការសម្តែងឡើងវិញដែលបានធ្វើឡើងនៅទីកន្លែងពីរផ្សេងគ្នា និងចុងក្រោយគឺឯកសារផ្សេងៗ ដែលត្រូវបានដាក់បញ្ចូលក្នុងសំណុំ-រឿង ដោយការិយាល័យសហចៅក្រមស៊ើបអង្កេត ការិយាល័យសហព្រះរាជអាជ្ញា ជនត្រូវចោទ និងមេធាវីរបស់ខ្លួន បន្ថែមពីលើឯកសារ ដែលបានដាក់ដោយការិយាល័យសហ-ព្រះរាជអាជ្ញាដើម្បីគាំទ្រដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

# ផ្នែកទី ១. ការបង្ហាញអំពីអង្គហេតុ

## ក- បរិបទប្រវត្តិសាស្ត្រ និងនយោបាយ

១០. នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ដឹកនាំដោយបក្សកុម្មុយនីស្តកម្ពុជា បានចូលដល់ទីក្រុងភ្នំពេញ និងបានដណ្ដើមកាន់កាប់អំណាចទាំងស្រុងនៅកម្ពុជា[9]។ ជាមួយនឹងការបញ្ចប់សង្គ្រាមស៊ីវិលប្រឆាំងនឹងរបបសាធារណរដ្ឋខ្មែររបស់ លន់ ណុល បក្សកុម្មុយនីស្តកម្ពុជាបានអនុវត្តគោលនយោបាយមួយឆ្ពោះទៅ *"ដំណាក់កាលបន្ទាប់នៃការកសាងបដិវត្តន៍សង្គមនិយម"*[10]។ ក្នុងអំឡុងបីឆ្នាំ ប្រាំបីខែ និងម្ភៃថ្ងៃ បក្សកុម្មុយនីស្តកម្ពុជាបានប្រើអំណាចយ៉ាងមានប្រសិទ្ធិភាពទៅលើ របបកម្ពុជាប្រជាធិបតេយ្យ ហើយបានដាក់ចេញនូវគោលនយោបាយ *"បំបែកចេញទាំងស្រុង"* នៃរចនាសម្ព័ន្ធសេដ្ឋកិច្ច និងនយោបាយរបស់របបសាធារណរដ្ឋខ្មែរ[11] ហើយបង្កើតនូវ *"អំណាចរដ្ឋបដិវត្តន៍ថ្មីមួយ"*[12]។

១១. អ្នកប្រវត្តិសាស្ត្រ និងអ្នកជំនាញ បានឯកភាពថា កម្មវិធីនយោបាយនេះត្រូវគេអនុវត្តតាមរយៈមធ្យោបាយមួយចំនួន ដែលរួមមានការជម្លៀសដោយបង្ខំអ្នករស់នៅភ្នំពេញ និងអតីតកងកម្លាំងដ៏រឹងមាំរបស់របបសាធារណរដ្ឋខ្មែរឱ្យទៅនៅតាមជនបទ ការបង្កើតសហករណ៍ក្រោមការគ្រប់គ្រងរបស់បក្សក្នុងគោលបំណងដើម្បីបង្កបង្កើនផលិតផលស្បៀងហើយដែលនៅទីនោះប្រជាជនត្រូវបានគេបង្ខំឱ្យធ្វើការក្នុងស្ថានភាពលំបាកក្រៃលែង ឬការលុបបំបាត់មន្ត្រី និងអ្នកគាំទ្ររបបចាស់[13]។ គោលនយោបាយជាច្រើនរបស់បក្សកុម្មុយនីស្តកម្ពុជា គឺមានគោលដៅប្រែក្លាយ *"ប្រជាជនថ្មី"* ឱ្យទៅជាកសិករ។ *"ប្រជាជនថ្មី"* ទាំងនេះភាគច្រើនជាអ្នករស់នៅទីក្រុង ព្រមទាំងកសិករដែលរស់នៅក្រោមរបប លន់ ណុល រហូតដល់ខែមេសា ឆ្នាំ១៩៧៥ ខុសពី *"ប្រជាជនចាស់"* ឬ *"ប្រជាជនមូលដ្ឋាន"* ដែលភាគច្រើនជាកសិករស្ថិតក្រោមការគ្រប់គ្រងរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងអំឡុងពេលនៃរបបសាធារណរដ្ឋខ្មែរ[14]។

១២. ការសម្លាប់ក្រៅច្បាប់ដែលមានចរិតលក្ខណៈនយោបាយបានកើតឡើងតាំងពីដំបូង ដោយ

អង្គភាពយោធា។ បន្ទាប់មក ការសម្លាប់ទាំងនេះបានបន្តអនុវត្តនៅតាមមន្ទីរសន្តិសុខនានានៅទូទាំងប្រទេស។ ការសម្លាប់បែបនេះត្រូវបានគេប្រមើលឃើញទុកជាមុនរួចទៅហើយ៖ ជាក់ស្តែង នាខែកុម្ភៈ ក្នុងឆ្នាំ១៩៧៥ បក្សកុម្មុយនីស្តកម្ពុជា បានរៀបចំ "មហាសន្និបាតជាតិរបស់រណសិរ្សរួបរួមជាតិកម្ពុជា" ហើយនៅពេលនោះ បានប្រកាសជា ឱឡារឹកតាមប្រព័ន្ធផ្សព្វផ្សាយរបស់ខ្លួនថា "*ពួកមហាក្បត់*" ទាំង ៧រូបរបស់សាធារណរដ្ឋខ្មែរ នឹងត្រូវប្រហារជីវិតភ្លាមៗក្រោយថ្ងៃរំដោះពីបទក្បត់ជាតិ[15]។ រដ្ឋាភិបាលនេះក៏បានប្រកាសអំពីជំហររបស់ខ្លួនចំពោះមន្ត្រីថ្នាក់ទាបនៃរបបសាធារណរដ្ឋខ្មែរថា ពួកគេនឹងត្រូវបានកងកម្លាំងបដិវត្តន៍ស្វាគមន៍ "*ប្រសិនបើពួកគេឈប់បម្រើពួកជនក្បត់ទាំង៧នាក់ និងឈប់បន្តសហការជាមួយពួកទាំងនោះ*"[16]។ ការប្រកាសដូច្នេះមានន័យថា មន្ត្រីណាដែលមិនទាន់បានចូលមកខាងពួកកុម្មុយនីស្ត ពួកគេនឹងត្រូវបានសម្លាប់ដូចអ្នកទាំងនោះផងដែរ។ តាមការពិត នេះបានបង្ហាញថា អង្គការសន្តិសុខរបស់បក្សកុម្មុយនីស្តកម្ពុជា ដូចជាមន្ទីរម១៣ ដែលឌុចជាប្រធានជាដើម បានធ្វើការប្រហារជីវិតមនុស្សចាប់តាំងពីដើមទសវត្សរ៍ឆ្នាំ៧០ រហូតមក[17]។ ទង្វើទាំងអស់នេះបានបញ្ជាក់ច្បាស់ថា គោលនយោបាយសម្លាប់មនុស្ស ដែលបក្សកុម្មុយនីស្តកម្ពុជាបានចាត់ទុកថាជា "ខ្មាំង" បដិវត្តន៍នោះ មានតាំងពីមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[18] មកម្ល៉េះ។

១៣. បក្សកុម្មុយនីស្តកម្ពុជាបានបំផ្លាញរចនាសម្ព័ន្ធច្បាប់ និងតុលាការនៃរបបសាធារណរដ្ឋខ្មែរ[19]។ ទោះបីជាការពិតថា កម្ពុជាប្រជាធិបតេយ្យបានអនុម័តរដ្ឋធម្មនុញ្ញមួយនាខែមករា ឆ្នាំ១៩៧៦ ក៏ដោយ ក៏ជំពូក ៧ នៃរដ្ឋធម្មនុញ្ញនេះ ដែលមានចំណងជើង "*អំពីតុលាការ*" បានបង្ហាញបញ្ហាជាអាទិភាពរបស់បក្សកុម្មុយនីស្តកម្ពុជាគឺ "*ការការពារប្រទេសពីរាល់សកម្មភាព របស់ប្រជាជនដែលប្រឆាំងនឹងរដ្ឋ*"។ មាត្រា១០វិញ ចែងដោយមិនមានការបញ្ជាក់ឲ្យបានច្បាស់ថា "*ការផ្តន្ទាទោសកម្រិតខ្ពស់បំផុត*" ចំពោះ "*ប្រភេទសកម្មភាពប្រឆាំង និងបំផ្លិចបំផ្លាញ ដែលមានលក្ខណៈជាខ្សែសង្វាក់ ហើយគ្រោះថ្នាក់ដល់រដ្ឋរបស់ប្រជាជន*" និងចែងទៀតថា "*ចំពោះប្រភេទល្មើសផ្សេងៗទៀត [...] ត្រូវអប់រំកសាងក្នុងក្របខណ្ឌអង្គការរដ្ឋ ឬក្នុងក្របខណ្ឌអង្គការប្រជាជន*"[20]។ ចំណែកឯ "*តុលាការប្រជាជន*" ដែលមានចែងនៅក្នុង

មាត្រា៩ ដើម្បី *"តំណាង និងការពារយុត្តិធម៌របស់ប្រជាជន"* និង *"ការពារសិទ្ធិសេរីភាពប្រជាធិបតេយ្យរបស់ប្រជាជន"* វិញ គ្មានភស្តុតាងណាមួយបានបង្ហាញថា តុលាការនេះធ្លាប់ត្រូវបានបង្កើតឲ្យមានឡើយ[21]។ទោះបីជាសភាតំណាងប្រជាជន ដែលទំនងជាត្រូវបានបោះឆ្នោតជ្រើសតាំងនោះបានប្រជុំតែមួយលើកគត់ ហើយដែលត្រូវបានផ្តល់អំណាចឲ្យបង្កើតគណៈកម្មាធិការតុលាការក្នុងខែមេសា ឆ្នាំ១៩៧៦ ក៏ដោយ ក៏មិនមានភស្តុតាងណាមួយបានបង្ហាញថា មានការអនុវត្តតាមមាត្រា ៩[22] នៃរដ្ឋធម្មនុញ្ញម្តងណាឡើយ។ នេះបង្ហាញឲ្យឃើញថា ទោសដែលមានចែងនៅក្នុងមាត្រា១០ ត្រូវបានយកមកអនុវត្តដោយរំលោភបំពាន[23]។ បន្ថែមពីលើចំណុចនេះ គ្មានភស្តុតាងមួយណាបង្ហាញថា បក្សកុម្មុយនីស្តកម្ពុជាបានបង្កើតឲ្យមានបទប្បញ្ញត្តិ ដែលចាំបាច់សម្រាប់ឈ្លើយសឹក ឬជនស៊ីវិល ឬយន្តការផ្លូវច្បាប់ណាមួយសម្រាប់តវ៉ានឹងការចាប់ខ្លួន ការឃុំខ្លួន និងការដាក់ទោសទៅលើអ្នកទាំងនោះទេ។

១៤. ស្ថាប័នតុលាការរបស់សាធារណរដ្ឋខ្មែរត្រូវបានជំនួសដោយមន្ទីរអប់រំកែប្រែ កន្លែងសួរចម្លើយ និងមន្ទីរសន្តិសុខសម្រាប់ឃុំខ្លួន និងប្រហារជីវិតអតីតអ្នករដ្ឋការ និងអ្នកគាំទ្ររបបសាធារណរដ្ឋខ្មែរ ព្រមទាំងមនុស្សឯទៀតដែលត្រូវបានចោទថា ប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជា[24]។ បណ្តាញនៃមន្ទីរសន្តិសុខទាំងនេះបានត្រូវបន្ថែមដោយប្រព័ន្ធតាមដាននៅគ្រប់ជាន់ថ្នាក់ សំដៅរែកមុខ រាយការណ៍ និងកម្ទេចខ្មាំងចេញពីជួរថ្នាក់ដឹកនាំរបស់បក្ស[25]។

១៥. ហេតុដូច្នេះហើយ ចាប់តាំងពីថ្ងៃរំដោះទីក្រុងភ្នំពេញរហូតដល់ពេលដែលរបបនេះត្រូវដួលរលំ បក្សកុម្មុយនីស្តកម្ពុជាបានដាក់ទោស ឬសម្លាប់មនុស្សជាច្រើន ដែលត្រូវបានចោទប្រកាន់ទាំងខុស ឬទាំងត្រូវ ថាមានជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរ ឬមនុស្សសំខាន់ៗនៃរបបសាធារណរដ្ឋខ្មែរ។

១៦. ក្រោយពីបានកាន់កាប់ទីក្រុងភ្នំពេញភ្លាមដោយកងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥[26] ជម្លោះប្រដាប់អាវុធអន្តរជាតិរវាងកម្ពុជា និង

វៀតណាមក៏ផ្ទុះឡើងភ្លាមដែរ។ ការប្រឈមមុខដាក់គ្នានេះបានអូសបន្លាយយ៉ាងហោចណាស់រហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[27]។

១៧. ជាការពិតណាស់ ទោះបីជាកម្ពុជាប្រជាធិបតេយ្យ និងសាធារណរដ្ឋសង្គមនិយមវៀតណាម បានទទួលស្គាល់ជាផ្លូវការអំពីអត្ថិភាពនៃជម្លោះប្រដាប់អាវុធអន្តរជាតិ តែនៅថ្ងៃទី៣១ ខែធ្នូឆ្នាំ ១៩៧៧ ក៏ដោយ[28] ក៏គេមានភស្តុតាងបង្ហាញថា អំពើហិង្សាប្រដាប់អាវុធ និងភាពតានតឹងរវាងប្រទេសទាំងពីរបានកើនឡើងជាបន្តបន្ទាប់ចាប់តាំងពីពាក់កណ្តាលខែមេសាឆ្នាំ១៩៧៥ មកម្ល៉េះ។ ការផ្អាកធ្វើសង្គ្រាមបង្ហូរឈាមគ្នានេះត្រូវបានសង្កេតឃើញថាមានតែនៅក្នុងអំឡុងពេលមានកិច្ចចរចាសន្តិភាព ឬការផ្លាស់ប្តូរទស្សនកិច្ចការទូត និងវប្បធម៌ប៉ុណ្ណោះ។ ជាក់ស្តែង កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា ដែលបានប្តូរឈ្មោះជាកងទ័ពបដិវត្តន៍កម្ពុជា និងកងទ័ពប្រជាជនវៀតណាមបានប្រយុទ្ធគ្នាជាច្រើនលើកច្រើនសានៅខេត្តរតនគិរី មណ្ឌលគិរី ក្រចេះ កំពង់ចាម ព្រៃវែង ស្វាយរៀង កណ្តាល តាកែវ កំពត និងនៅកោះមួយចំនួនដូចជាកោះវៃ កោះអាចម៍ កោះត្រល់ កោះសេះ កោះថ្មី កោះសំពោច កោះរ៉ុង និងកោះមុខរាម[29] ជាដើម។

១៨. ក្រោយពីជម្លោះប្រដាប់អាវុធរវាងកម្ពុជាប្រជាធិបតេយ្យ និងវៀតណាមបានឈានដល់កម្រិតតានតឹងបំផុត នៅចុងឆ្នាំ១៩៧៧ ជម្លោះនោះបានឈានទៅដល់សង្គ្រាមមួយពិតប្រាកដ ហើយការប្រយុទ្ធគ្នានៅសមរភូមិបានរំកិលចូលមកយ៉ាងជ្រៅក្នុងទឹកដីកម្ពុជា ជាហេតុធ្វើឱ្យរដ្ឋាភិបាលកម្ពុជាប្រជាធិបតេយ្យលើកយកបញ្ហានេះទៅប្តឹងក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ នៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ១៩៧៨[30]។ នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ កងទ័ពបដិវត្តន៍កម្ពុជាត្រូវបានបណ្តេញចេញពីទីក្រុងភ្នំពេញ។ គឺចាប់ពីពេលនោះហើយ ដែលរបបនេះបានបាត់បង់ការគ្រប់គ្រងទឹកដីកម្ពុជាចំនួនមួយភាគធំ។

***

១៩. គឺនៅក្នុងបរិបទនៃការបង្កើតកម្ពុជាមួយថ្មីស្រឡាង និងសង្គ្រាមជាមួយវៀតណាមនេះហើយ ដែលមន្ទីរស-២១ ត្រូវបានបង្កើតឡើង។

## ខ. ការបង្កើតមន្ទីរ ស-២១

២០. នៅថ្ងៃទី១៥ ខែសីហា ឆ្នាំ១៩៧៥ **សុន សេន**បានកោះហៅឌុច និង B មកពីកងពលធំ៧០៣នៃកងទ័ពបដិវត្តន៍កម្ពុជាឲ្យទៅប្រជុំនៅស្ថានីយរថភ្លើងក្រុងភ្នំពេញក្នុងគោលបំណងដើម្បីរៀបចំផែនការបង្កើតមន្ទីរ ស-២១។ នៅក្នុងដីកាដំណោះស្រាយនេះ ពាក្យ **ស-២១**រាប់បញ្ចូលនូវមន្ទីរឃុំឃាំងទួលស្លែង និងបរិវេណជុំវិញ (ដែលតទៅនេះហៅថា៖ "ទួលស្លែង") ព្រមទាំងទីកន្លែងសម្រាប់សម្លាប់អ្នកទោស និងជំរុំអប់រំកែប្រែនៅឯជាយក្រុងភ្នំពេញ គឺជើងឯក និងព្រៃសប្ញហៅថា ស-២៤[31] ផងដែរ។ ក្នុងចំណោមមន្ទីរសន្តិសុខនានា មានតែមន្ទីរស-២១តែមួយគត់ ដែលមានលក្ខណៈពិសេស ដោយសារមានទំនាក់ទំនងផ្ទាល់ជាមួយនិងគណៈកម្មាធិការមជ្ឈិម និងមានតួនាទីក្នុងការឃុំខ្លួន និងការសម្លាប់ កម្មាភិបាលរបស់បក្សកុម្មុយនីស្តកម្ពុជា។

២១. សុន សេន បានតែងតាំង B ជាប្រធានមន្ទីរ ស-២១ និងជាលេខាគណៈកម្មាធិការរបស់មន្ទីរនេះ[32] ហើយ ឌុច ជាអនុប្រធានទទួលបន្ទុកក្រុមអ្នកសួរចម្លើយ[33]។ ក្រោយពីកិច្ចប្រជុំនោះមក ឌុច បាននាំអតីតបុគ្គលិកមន្ទីរ ម១៣ មួយចំនួន មកទីក្រុងភ្នំពេញដើម្បីចូលរួមជាមួយកម្លាំងកងពលធំ៧០៣ ដែលធ្លាប់បានធ្វើប្រតិបត្តិការប្រឆាំងនឹងអាជ្ញាធររបបលន់ ណុល[34]។ មន្ទីរ ស២១ បានចាប់ធ្វើប្រតិបត្តិការពេញលេញ ក្នុងខែតុលា ឆ្នាំ១៩៧៥[35]។

២២. នៅក្នុងខែមីនា ឆ្នាំ១៩៧៦ B ត្រូវបានផ្លាស់ទៅសេនាធិការ ហើយតួនាទីជាប្រធាន និងជាលេខាមន្ទីរ ស-២១ របស់ណាតត្រូវបានធ្លាក់ទៅលើ**ឌុច**[36]។ **ឌុច**បានរក្សាទុកនូវតួនាទីជាអនុ

ប្រធានទទួលបន្ទុកប្រតិបត្តិការប្រចាំថ្ងៃរបស់ **C** ដែលជាអតីតកម្មាភិបាលកងពលធំ៧០៣ឲ្យនៅដដែល។ ទោះជាយ៉ាងដូច្នេះ **ឌុច**បានសារភាពថា គាត់បានបន្តមើលខុសត្រូវដោយខ្លួនឯងផ្ទាល់ទៅលើការសួរចម្លើយអ្នកទោសសំខាន់ៗ និងជាចុងក្រោយព្រមទទួលខុសត្រូវគ្រប់យ៉ាងចំពោះរាល់អ្វីៗដែលបានកើតឡើងក្នុងមន្ទីរ ស-២១[37]។ សមាជិកទីបីនៃគណៈកម្មាធិការមន្ទីរ ស-២១ មានឈ្មោះថា **D**។ **D** ក៏ជាអ្នកទទួលខុសត្រូវលើមន្ទីរស-២៤ ផងដែរ[38]។

២៣. **ឌុច**បានបញ្ជាក់ថា ដើមឡើយគាត់រារែកមិនចង់ទទួលតួនាទីនៅមន្ទីរ ស-២១ ទេ គឺគាត់ចង់ទៅបម្រើការនៅក្រសួងឧស្សាហកម្មជាង[39]។ **ឌុច**បានបញ្ជាក់ទៀតថា នៅពេលដែលគាត់ដឹងថា គាត់ត្រូវបានតែងតាំងជាប្រធាន និងជាលេខាមន្ទីរ ស-២១ ពេលនោះ គាត់បានសុំឲ្យគេប្រគល់តំណែងនោះឲ្យអ្នកផ្សេងវិញ។ ប៉ុន្តែទោះបីជាយ៉ាងណាក៏ដោយ ក៏ឌុច បានព្រមទទួលធ្វើជាអ្នកដឹកនាំ ស-២១ និងតាមការសារភាពរបស់គាត់ផ្ទាល់ **ឌុច**យល់ថា ផ្អែកតាមបទពិសោធន៍នៅមន្ទីរម១៣ គាត់មានសមត្ថភាពបំពេញការងារនេះបានប្រសើរជាងអ្នកមុន[40]។

២៤. ក្រោមការដឹកនាំរបស់ **ឌុច** មន្ទីរ ស-២១ ត្រូវបានចែកចេញជាអង្គភាពជាច្រើន ដែលមានតួនាទីរៀងៗខ្លួន[41]។ អង្គភាពការពារមាន **C** និងអនុរបស់ខ្លួនឈ្មោះ **E** ជាអ្នកគ្រប់គ្រង។ អង្គភាពសួរចម្លើយ ដែលស្ថិតនៅក្រោមការមើលខុសត្រូវរបស់**ឌុច**ផ្ទាល់ ជាទូទៅ មាន **F** និង **G** ជាអ្នកចាត់ចែង[42]។ **H** មានតួនាទីទទួលបន្ទុកផ្នែកឯកសារ ហើយរាយការណ៍ជូន**ឌុច**តាមរយៈ **C**[43]។ **I** ជាអ្នកទទួលខុសត្រូវ អង្គភាពពិសេស។ អង្គភាពនេះមានភារកិច្ចចាំបាច់មួយចំនួនដូចជា ទទួលអ្នកទោសដែលបញ្ជូនមកមន្ទីរ ស-២១ នាំអ្នកទោសទៅប្រគល់ឲ្យប្រធានអង្គភាពការពារ ធ្វើអន្តរាគមន៍ក្នុងករណីបន្ទាន់ និងចុងក្រោយទទួលបន្ទុកក្នុងការសម្លាប់[44]។ ក្រៅពីនេះ មន្ទីរមានផ្នែកមួយចំនួនទៀតរួមមាន ផ្នែកថតរូប ពេទ្យ ដាំស្ល និងភស្តុភារ។ **ឌុច**គ្រប់គ្រងមន្ទីរ ស-២១ តាមឋានានុក្រម និងបានបង្កើតប្រព័ន្ធរាយការណ៍គ្រប់ជាន់ថ្នាក់ ដើម្បីធានាថា រាល់បទបញ្ជារបស់គាត់ត្រូវបាន

អនុវត្តភ្លាមៗ និងជាក់លាក់[45]។

២៥. សាក្សីជាច្រើនបាននិយាយថា គេខ្លាចឌុចគ្រប់គ្នានៅមន្ទីរស-២១[46]។ ឌុចមិនត្រឹមតែបានអនុវត្តមាគ៌ាទូទៅរបស់បក្សទាក់ទិននឹងការងាររបស់សន្តិបាលប៉ុណ្ណោះទេ[47] ថែមទាំងអនុវត្តវិន័យឲ្យបានតឹងរឹង ដែលឌុចខ្លួនឯងផ្ទាល់ជាអ្នកតាក់តែងសម្រាប់ប្រតិបត្តិការនៅមន្ទីរ ស-២១[48]។ ឌុច មិនបានអនុញ្ញាតឲ្យអ្នកដទៃជ្រើសរើសបុគ្គលិកទេគឺគាត់ជ្រើសរើសដោយខ្លួនឯង[49]។ ដំបូងគាត់ជ្រើសរើសអ្នកក្រោមបង្គាប់របស់គាត់មកពីមន្ទីរ ម-១៣[50] ដោយសារអ្នកទាំងនោះគឺជាមនុស្សដែលគាត់ទុកចិត្តបំផុត។ ក្រោយមក ឌុចបានជ្រើសរើសយកក្មេងៗ និងមនុស្សវ័យជំទង់មកធ្វើជាអ្នកយាម ពីព្រោះបើតាមសំដីរបស់គាត់ ពួកគេ *"ដូចជាក្រដាសស"* ដែលអាចអប់រំមនោគមវិជ្ជាបានដោយងាយ[51]។

២៦. ដំបូងឡើយ បរិវេណមន្ទីរ ស-២១ ស្ថិតនៅទីក្រុងភ្នំពេញក្នុងសង្កាត់បឹងកេងកង៣ (ខណ្ឌចំការមន) ចំណែកឯមន្ទីរឃុំឃាំង និងសួរចម្លើយស្ថិតនៅក្នុងផ្ទះមួយប្លុកត្រង់កាច់ជ្រុងផ្លូវលេខ១៦៣ និងលេខ៣៦០[52]។ នៅចុងខែវិច្ឆិកា ឆ្នាំ១៩៧៥ មន្ទីរ ស-២១ បានរើទៅអគ្គស្នងការដ្ឋាននគរបាលជាតិតាមបណ្តោយផ្លូវលេខ៥១ (ផ្លូវប៉ាស្ទ័រ) ជិតផ្សារថ្មី។ ក៏ប៉ុន្តែក្នុងខែមករា ឆ្នាំ១៩៧៦ បានរើត្រឡប់មកទីតាំងចាស់វិញ[53]។

២៧. ជាចុងក្រោយគឺនៅក្នុងខែមេសា ឆ្នាំ១៩៧៦ តាមបញ្ជារបស់ឌុច អ្នកទោស ត្រូវបានគេយកទៅឃុំឃាំងនៅក្នុងបរិវេណវិទ្យាល័យពញាយ៉ាត ដែលមានទីតាំងស្ថិតនៅចន្លោះផ្លូវលេខ១១៣ ១៣១ ៣២០ និងលេខ ៣៥០[54] គឺនៅត្រង់បរិវេណសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែងសព្វថ្ងៃ។ មន្ទីរ ស-២១ បានស្ថិតនៅលើទីតាំងនេះរហូតដល់ថ្ងៃទី០៦ ខែមករា ឆ្នាំ១៩៧៩[55]។ អគារកណ្តាល ("អគារ E") សម្រាប់ទទួល កត់ឈ្មោះ និងថតរូបអ្នកទោស[56]។ នៅក្នុងអគារនោះមានបន្ទប់មួយទៀតសម្រាប់គូរ និងឆ្លាក់រូបមេដឹកនាំរបបកម្ពុជាប្រជាធិបតេយ្យ។ អគារបួនផ្សេងទៀត (A B C និងD) ប្រើសម្រាប់ឃុំឃាំង[57]។ អគារ B C និង D សម្រាប់ដាក់អ្នកទោសទូទៅនៅតាមបន្ទប់ឃុំឃាំងតូចៗដាច់ដោយឡែកធ្វើពីឈើ ឬឥដ្ឋ ឬក្នុងបន្ទប់ធំរួមគ្នា។ អគារ A និងផ្ទះមួយប្លុកនៅខាងត្បូងអតីតវិទ្យាល័យពញាយ៉ាត ជា "គុកពិសេស"

សម្រាប់ដាក់អ្នកទោសសំខាន់ៗ[58]។

២៨. អតីតវិទ្យាល័យពញាយ៉ាត និងគុកពិសេស ជាកន្លែងឃាមកាមតឹងតែង និងសម្ងាត់បំផុតនៃមន្ទីរ ស-២១។ អគារទាំងនោះហ៊ុមព័ទ្ធដោយរបង និងមានការការពារទាំងខាងក្នុង និងខាងក្រៅ ដោយអ្នកយាមដែលមានកាន់កាំភ្លើង[59]។ អាគារជាច្រើនផ្សេងទៀតនៅក្បែរៗនោះក៏ជាផ្នែករបស់មន្ទីរ ស-២១ ដែរ[60]។ តួយ៉ាងផ្ទះសម្រាប់សួរចម្លើយ ទីកន្លែងសម្រាប់ប្រហារជីវិត និងរណ្តៅសាកសពរួម រោងបាយ កន្លែងដាក់ឱសថ ផ្ទះបុគ្គលិក ការិយាល័យផ្សេងៗ ផ្ទះរបស់ឌុច និងផ្ទះសម្រាប់ទទួលអ្នកទោស[61]។ អគារទាំងអស់នោះ ស្ថិតនៅខាងក្នុងបរិវេណទីពីរ ដោយមានអ្នកយាមការពារដែលមានកាន់កាំភ្លើងផងដែរ។

២៩. កាលពីដំបូង អ្នកទោសត្រូវបានគេសម្លាប់នៅក្នុង ឬនៅជុំវិញបរិវេណមន្ទីរ ស-២១[62]។ ដោយមិនបានដឹងពីថ្ងៃខែច្បាស់លាស់ ពីចន្លោះឆ្នាំ១៩៧៦ ដល់ពាក់កណ្តាលឆ្នាំ១៩៧៧ ម្យ៉ាងដើម្បីបញ្ចៀសជម្ងឺឆ្លង ឌុចបានជ្រើសរើសយកជើងឯកធ្វើជាទីកន្លែងសម្រាប់សម្លាប់អ្នកទោស[63]។ ជើងឯកស្ថិតនៅប្រមាណ១៥ គីឡូម៉ែត្រ ភាគនិរតីនៃក្រុងភ្នំពេញក្នុងខេត្តកណ្តាល[64]។ សព្វថ្ងៃ ជើងឯកបានក្លាយជាបូជនីយដ្ឋានមួយទៅហើយ។ នៅឯវាលពិឃាតជើងឯក មានផ្ទះឈើមួយខ្នង[65]សម្រាប់ដាក់អ្នកទោសមុនពេលសម្លាប់ និងរណ្តៅដែលនៅមាត់រណ្តៅនោះ ជាកន្លែងសម្រាប់វាយសម្លាប់អ្នកទោស[66]។ ទោះបីជាជើងឯកបានក្លាយទៅជាកន្លែងសម្លាប់អ្នកទោសក៏ដោយ ក៏នៅមានអ្នកទោសខ្លះនៅតែត្រូវបានគេសម្លាប់ និងកប់នៅក្នុងបរិវេណមន្ទីរ ស-២១ ឬក្បែរបរិវេណនោះ[67]។

៣០. ឌុចបានទទួលស្គាល់ថា មន្ទីរ ស-២៤ ជាផ្នែកមួយរបស់មន្ទីរ ស-២១[68]។ ជាគោលការណ៍ មន្ទីរ ស-២៤នេះមានភារកិច្ចកែប្រែ និងកសាងយុទ្ធជន[69] ព្រមទាំងធ្វើស្រែដើម្បីផ្គត់ផ្គង់មន្ទីរ ស-២១ និងសាខានានា[70]។ មន្ទីរ ស-២៤មានទីតាំងនៅក្រៅក្រុងភ្នំពេញជិតជើងឯក ក្នុងតំបន់វត្តក្តុល ស្រុកដង្កោ ខេត្តកណ្តាល[71]។ ទោះបីជាសាក្សីអះអាងថា រចនាសម្ព័ន្ធ និងសកម្មភាពរបស់ ស-២៤ លាតសន្ធឹងពីគុកព្រៃសដល់ភូមិចេកក៏ដោយ ក៏តំបន់មន្ទីរ ស-២៤ ទាំងមូលទំនងជាមានទំហំធំជាងនេះ[72]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

## គ. ការអនុវត្តន៍គោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជានៅមន្ទីរ ស-២១

១. គោលនយោបាយ "កម្ទេច" ខ្មាំង

៣១. តួនាទីជាចម្បងរបស់មន្ទីរ ស-២១ គឺការអនុវត្តន៍ "*មាគ៌ានយោបាយបក្សចំពោះខ្មាំង*" ដែល តាមរយៈមាគ៌ានេះ អ្នកទោស "*ត្រូវតែកម្ទេចចោលជាដាច់ខាត*"[73]។ នៅសម័យនោះ ពាក្យថា "កម្ទេច" បានត្រូវប្រើ និងយល់ជាទូទៅថាជាការ "*សម្លាប់*"[74]។ ជាគោលការណ៍ អ្នកទោសទាំងឡាយដែលបញ្ជូនមកមន្ទីរ ស-២១ ត្រូវតែសម្លាប់ទាំងអស់។ ទោះបីជាមានសាក្សីមួយរូប[75]បានអះអាងថាអាចចាកចេញពីមន្ទីរ ស-២១ បានក៏ដោយ ក៏ភស្តុតាងភាគច្រើនលើសលប់នៅតែបង្ហាញថា គោលនយោបាយអនុវត្តនៅមន្ទីរ ស-២១ គឺមិនដោះលែងអ្នកទោសណាម្នាក់ឡើយ[76]។ សក្ខីកម្មនានាបានបញ្ជាក់ចំណុចនេះយ៉ាងច្បាស់ គឺមានអ្នកទោសមួយចំនួនត្រូវបានគេចាប់ និងនាំខ្លួនមកមន្ទីរ ស-២១ ដោយភ័ន្តច្រលំ ប៉ុន្តែក៏ត្រូវបានគេសម្លាប់ចោលដែរដើម្បីរក្សាការសម្ងាត់ និងសន្តិសុខ[77]។ ឌុចក៏បានអះអាងថា គាត់បានព្យាយាមដោះលែងអ្នកទោសប៉ុន្មានលើកដែរ ក៏ប៉ុន្តែមិនបានសម្រេច[78]។ មានអ្នកទោសផ្សេងទៀតបានទទូចសុំឱ្យឌុចទុកជីវិតខ្លួន ឬបានសរសេរសំបុត្រផ្ញើទៅមេដឹកនាំជាន់ខ្ពស់តាមរយៈឌុច ក៏ប៉ុន្តែមិនបានជោគជ័យដដែល[79]។

***

៣២. បក្សកុម្មុយនីស្តកម្ពុជា បានគ្រប់គ្រងកម្ពុជាប្រជាធិបតេយ្យ ជាចម្បងតាមរយៈអង្គការរដ្ឋកម្ពុជាប្រជាធិបតេយ្យ អង្គការរដ្ឋបាលរបស់បក្ស និងកងទ័ពបដិវត្តន៍កម្ពុជា[80]។ រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យឆ្នាំ១៩៧៦[81] និងលក្ខន្តិកៈបក្ស[82]បានផ្តល់អំណាចយ៉ាងធំទៅឱ្យគណៈកម្មាធិការមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជា ដោយរួមមានលទ្ធភាពក្នុងការកំណត់គោលនយោបាយបក្ស និងសិទ្ធិអំណាចបញ្ជាទៅថ្នាក់ភូមិភាគនិងតំបន់។ប៉ុន្តែ ក្នុងការអនុវត្តជាក់ស្តែង គឺអនុគណៈកម្មាធិការនៃគណៈកម្មាធិការកណ្តាល ឬហៅថាគណៈ កម្មាធិការ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(0)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(0)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

អចិន្ត្រៃយ៍[83]ជាអ្នកដើរតួនាទីជាអង្គភាពប្រកបដោយសិទ្ធិអំណាចធំបំផុត និងខ្ពស់បំផុតរបស់រដ្ឋ[84]។ សេចក្តីសម្រេចមួយរបស់គណៈកម្មាធិការអចិន្ត្រៃយ៍កាលពីថ្ងៃទី០៩ ខែតុលា ឆ្នាំ១៩៧៥ បានតែងតាំង **ប៉ុល ពត** ជាមេបញ្ជាការជាន់ខ្ពស់កងទ័ព[85] និងសុន សេន ជានាយសេនាធិការទទួលបន្ទុកផ្នែកសន្តិសុខ[86]។ ជាច្រើនលើកច្រើនសា **ឌុច**តែងបានចាត់ទុកមន្ទីរ ស-២១ ជាផ្នែកសំខាន់មួយនៃរចនាសម្ព័ន្ធនយោបាយយោធារបស់បក្សកុម្មុយនីស្តកម្ពុជានៅថ្នាក់មជ្ឈិម ដែលឌុចបានហៅថា *"អង្គការ[87]" "មជ្ឈិមបក្ស[88]" "គណៈកម្មាធិការមជ្ឈិម[89]"* ឬ *"គណៈកម្មាធិការអចិន្ត្រៃយ៍[90]"*។

៣៣. ឌុច បានពន្យល់ថា នយោបាយ "កម្ទេច" ខ្មាំង ក៏ដូចជាមាគ៌ានយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជាផ្សេងទៀតដែរ គឺមានលក្ខណៈសកល។ ពោលគឺសម្រាប់ មន្ទីរ ស-២១ *"បក្សទាំងមូល កងទ័ព អាជ្ញាធរមូលដ្ឋាន និងផ្នែកសន្តិបាលទូទាំងប្រទេស..."[91]*។ ឌុច បានបញ្ជាក់ថា សេចក្តីសម្រេចមួយចំនួនទាក់ទងនឹងអ្នកទោសដែលត្រូវបញ្ជូនមកមន្ទីរ ស-២១ គឺធ្វើឡើងដោយ *"ថ្នាក់លើ"*[92]។ ដោយហេតុថា តួនាទីពិតប្រាកដរបស់ "ថ្នាក់លើ" បច្ចុប្បន្នជាកម្មវត្ថុនៃការស៊ើបសួរមួយដាច់ដោយឡែកនោះ គេយកតែសំដីរបស់ ឌុច ដែលបានប្រកាសថា មន្ទីរ ស-២១ *"ត្រូវបានដឹកនាំដោយផ្ទាល់ពីគណៈមជ្ឈិមបក្ស"[93]*។ ឌុច បានបញ្ជាក់ថា គាត់មានទំនាក់ទំនងជាចម្បងជាមួយ សុន សេន និង J ដែលជាអនុលេខាបក្សកុម្មុយនីស្តកម្ពុជា ហើយ **ឌុច**បាននិយាយថា អ្នកទាំងពីរធ្វើការក្នុងនាមគណៈកម្មាធិការអចិន្ត្រៃយ៍[94]។

៣៤. ទោះបីគោលនយោបាយ "កម្ទេច" ខ្មាំង ទំនងជាត្រូវបានអនុវត្តនៅពេលមុន[95] និងក្នុងអំឡុងពេលនៃយុត្តាធិការអ.វ.ត.កក៏ដោយ ក៏និយមន័យនៃអ្នកដែលបក្សកុម្មុយនីស្តកម្ពុជាចាត់ទុកថាជាខ្មាំងនោះ មានការប្រែប្រួល និងពង្រីកទៅតាមការវិវត្តន៍នៃស្ថានភាពក្នុងស្រុក និងជម្លោះប្រដាប់អាវុធជាអន្តរជាតិ រវាងកម្ពុជានិងវៀតណាម។

៣៥. ហេតុដូច្នេះ ចាប់ពីចុងឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៦ មន្ទីរ ស-២១ បានជាប់ពាក់ព័ន្ធជាសំខាន់ក្នុងការឃុំឃាំង ការកសាងខ្លួន ការធ្វើទារុណកម្ម និងការសម្លាប់ ជនទាំងឡាយណាដែលមាន

ជាប់ពាក់ព័ន្ធនឹងរបបសាធារណរដ្ឋខ្មែរដែលបានដួលរលំ[96]។ ប៉ុន្តែ នៅពេល **ឌុច**ជាប្រធានមន្ទីរ ស-២១[97] បក្សបានបញ្ជាក់អំពីថ្នាក់ដែលមានអំណាចក្នុងការបញ្ជាឲ្យមានការសម្លាប់[98] ហេតុដូច្នេះហើយបានជាមានសមាជិកក្នុងជួរបដិវត្តន៍ត្រូវបានបញ្ជូនទៅកាន់មន្ទីរ ស-២១ កាន់តែច្រើនឡើងៗ[99]។ ឯកសារមួយចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ របស់គណៈមជ្ឈឹមបក្សកុម្មុយនីស្តកម្ពុជាបានលើកឡើងពីបញ្ហាផ្សេងៗមួយចំនួន ដែលក្នុងនោះមានសេចក្តីសម្រេចមួយបានសរសេរថា ដើម្បី *"ឲ្យមានក្របខ័ណ្ឌមួយក្នុងកិច្ចអនុវត្តន៍ផ្តាច់ការបដិវត្តន៍របស់យើង"* និងដើម្បី *"ពង្រឹងប្រជាធិបតេយ្យសង្គមនិយមរបស់យើង"* *"សិទ្ធិសម្រេចកម្ទេចខ្មាំងក្នុងជួរ និងក្រៅជួរ"* បានត្រូវប្រគល់ឲ្យដូចខាងក្រោម៖

- *"បើនៅក្នុងក្របខណ្ឌមូលដ្ឋាន ត្រូវអចិន្ត្រៃយ៍ភាគសម្រេច។*
- *នៅជុំវិញមន្ទីរមជ្ឈឹម ត្រូវគណៈមន្ទីរមជ្ឈឹមសម្រេច។*
- *តំបន់ឯករាជ្យ ត្រូវអចិន្ត្រៃយ៍សម្រេច។*
- *កងទ័ពមជ្ឈឹម ត្រូវសេនាធិការសម្រេច"*[100] ។

៣៦. នៅពេលសហចៅក្រមស៊ើបអង្កេតបានបង្ហាញឲ្យឌុច ឃើញឯកសារខាងលើនោះ **ឌុច**បាននិយាយថា៖ *"ឯកសារនេះមានលក្ខណៈប្រវត្តិសាស្ត្រ។ វាបញ្ជាក់ពីរបត់មួយ ពីព្រោះវាបញ្ជាក់ពីការចាប់ផ្តើមនៃការសំរិតសំរាំងផ្ទៃក្នុង។ កាលពេលមុន មន្ត្រីរាជការនៃរបបចាស់ត្រូវបានកម្ទេចចោល។ ប៉ុន្តែនាពេលក្រោយមក ការសម្លាប់បានធ្វើឡើងនៅក្នុងជួរ"*[101]។ **ឌុច** និយាយបន្ថែមទៀតថា *"ក្នុងឆ្នាំ១៩៧៦ ប៉ុល ពតបានបញ្ចប់ជាមួយវណ្ណៈជិះជាន់ ជាមួយកម្មសិទ្ធឯកជន ជាមួយមនុស្សរបបចាស់ ជាមួយសាសនា ជាមួយសិក្សាធិការ"* (គ្រូបង្រៀនត្រូវបានបញ្ជូនទៅធ្វើស្រែ)។ *សេចក្តីសម្រេចចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ១៩៧៦ បានចាប់ផ្តើមនូវជំហានពេលវេលាថ្មីមួយ ដែលនាំមកនូវការបោសសំអាតផ្ទៃក្នុងដ៏ច្រើនឥតគណនា"*[102] ។ ជាច្រើនខែក្រោយមក ឯកសារផ្ទៃក្នុងរបស់បក្សកុម្មុយនីស្តកម្ពុជាតម្រូវឲ្យមានការបង្កើនការ *"ប្រុងប្រយ័ត្នបដិវត្តន៍"* ដើម្បី *"ធានាមិនឲ្យខ្មាំងស៊ីរូងផ្ទៃក្នុង"* បក្ស និងកងទ័ពបាន[103]។

៣៧. **ឌុច**បានទទួលស្គាល់ថា ក្នុងតួនាទីរបស់គាត់ជាប្រធានមន្ទីរស-២១ គឺផ្តោតជាសំខាន់ទៅលើ

ការកម្ទេចអ្នក ដែលគេសន្មត់ថា ជាជនក្បត់បង្កប់ក្នុងជួរបដិវត្តន៍។ គាត់បានពន្យល់ទៀតថា "*ពីដំបូងស-២១ មានសមត្ថកិច្ចត្រឹមតែចំពោះអ្នកទោសដែលសំខាន់ ឬអ្នកទោសដែលរស់នៅភ្នំពេញ និងសមាជិកនៃគណៈកម្មាធិការមជ្ឈិមប៉ុណ្ណោះ។ ដូច្នេះពីដំបូង យុទ្ធជនថ្នាក់ទាបមិនត្រូវបានបញ្ជូនមក ស-២១ នោះទេ លើកលែងតែនៅពេលណា ដែលពួកគេត្រូវបានចាប់ខ្លួននៅភ្នំពេញតែប៉ុណ្ណោះ*"[104]។ ជាទូទៅ ខ្មាំងដែលមានឋានៈខ្ពស់ (សមាជិកជាន់ខ្ពស់របស់បក្សរបស់រដ្ឋ របស់កងទ័ព ឬរបស់សន្តិបាល) ដែលត្រូវបានអ្នកទោសឆ្លើយដាក់តាមរយៈចម្លើយសារភាពត្រូវបានបញ្ជូនមកមន្ទីរស-២១[105]។ នៅពេលដែលថ្នាក់ដឹកនាំណាម្នាក់ត្រូវបានចាប់ខ្លួន ឧទាហរណ៍ដូចជា **K** រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងជាសមាជិកមជ្ឈឹមបក្ស អ្នកនៅក្រោមបង្គាប់របស់ **K** ក៏បានត្រូវចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរ ស-២១ ជាបន្តបន្ទាប់ផងដែរ[106]។ លើសពីនេះ **ឌុច**បានទទួលស្គាល់ថា គោលនយោបាយកម្ទេចខ្មាំងនោះ គឺកម្ទេចទាំងក្រុមគ្រួសារ រួមទាំងកូនៗរបស់ពួកគេផងដែរ[107]។

៣៨. **ឌុច**បានទទួលស្គាល់ទៀតថា "*ប៉ុន្តែ ពេលក្រោយមក នៅពេលដែលការបង្ក្រាបមានចំនួនកើនឡើងខ្លាំង ស-២១ ក៏ទទួលមនុស្សមកពីជនបទផងដែរ។ ខ្ញុំក៏បានសង្កេតឃើញការបញ្ជូនមកជាឈុតនៃអ្នកទោសមកពីតំបន់មួយចំនួន៖ ឧទាហរណ៍ នៅពេលដែលប្រធាននៃមន្ទីរសន្តិសុខនៃភូមិភាគបស្ចិមឈ្មោះ **L** ត្រូវបានចាប់ខ្លួន ខ្ញុំបានឃើញការបញ្ជូនមក ស-២១ នូវមនុស្សជាច្រើននៃតំបន់នោះផងដែរ។ ការចាប់ខ្លួនទាំងនេះគឺធ្វើឡើងមុនការចាប់ខ្លួនថ្នាក់លើរបស់ឈ្មោះ **L** ដែលមានឈ្មោះ **M**។ នេះគឺជាការអនុវត្តន៍ទ្រឹស្តីរបស់ ហ្វូជីមុិញ៖ "មុននឹងកាប់ឫស្សី ត្រូវឆ្ការបន្លាចេញសិន"។ ដូចគ្នានេះដែរចំពោះភូមិភាគពាយ័ព្យផងដែរ*"[108]។ ព្រឹត្តិការណ៍នេះ ត្រូវបានបញ្ជាក់យ៉ាងច្បាស់តាមរយៈបញ្ជីអ្នកទោស ដែលបានបង្ហាញថាគិតមកដល់ខែមករា ឆ្នាំ១៩៧៩ មន្ទីរ ស-២១ មានអ្នកទោសមកពីស្ទើរតែគ្រប់ភូមិភាគក្រសួង និងអង្គភាពយោធាទូទាំងប្រទេស[109]។

៣៩. តួនាទីមន្ទីរ ស-២១ បានឈានដល់ការកំទេចអ្នកដែលស្ថិតនៅក្នុងជួរបដិវត្តន៍ទាំងឡាយណាដែលទទួលរងនូវការចោទប្រកាន់ថា ទទួលឥទ្ធិពលឬស្ថិតនៅក្រោមការបញ្ជារបស់វៀតណាម


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ព្រោះតែកន្លងមកពួកគេធ្លាប់មានទំនាក់ទំនងជាមួយបក្សកុម្មុយនីស្តវៀតណាម[110]។ ជាក់ស្តែង មូលហេតុដែលនាំឲ្យមានការចាប់ខ្លួនបានកើនឡើង ស្របពេលជាមួយនឹងភាពតានតឹងនៃជម្លោះប្រដាប់អាវុធជាអន្តរជាតិ។ ដូច្នេះហើយ ខណៈពេលជម្លោះរវាងប្រទេសទាំងពីរកាន់តែខ្លាំងក្លាទៅៗ ចំនួនជនស៊ីវិលវៀតណាមរួមទាំងកងទ័ពផង ដែលត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរ ស-២១ ក៏កាន់តែមានចំនួនច្រើនឡើងដែរ[111]។

២. ការផ្សព្វផ្សាយមាគ៌ានយោបាយបក្សនៅមន្ទីរ ស-២១

៤០. មាគ៌ានយោបាយនៃបក្សកុម្មុយនីស្តកម្ពុជាត្រូវបានគេយកមកបង្រៀនដោយផ្ទាល់នៅមន្ទីរស-២១ ។ **ឌុច** ព្រមទាំងកម្មាភិបាលនៅមន្ទីរស-២១ បានចូលរួមវគ្គអប់រំរៀនសូត្រអំពីគោលនយោបាយទូទៅ[112]និងរៀបចំផែនការបង្កបង្កើនផល ដែលត្រូវបានរៀបចំឡើងដោយសេនាធិការរបស់មជ្ឈឹម[113]។ **ឌុច** និងអតីតកម្មាភិបាលទាំងនេះបានបញ្ជាក់ថា ពួកគេក៏ធ្លាប់បានចូលរួមវគ្គរៀនសូត្រដែលរៀបចំឡើងដោយ សុន សេន ដើម្បីពិភាក្សាអំពីភាពចាំបាច់ក្នុងការបោសសំអាត និងកម្ទេចខ្មាំងដែរ[114]។ អតីតបុគ្គលិកមន្ទីរស-២១ ជាច្រើនបានអះអាងថា គោលនយោបាយក្នុងការសម្លាប់អ្នកទោសក្រៅច្បាប់ត្រូវបានគេផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅមន្ទីរស-២១ក្នុងឱកាសនៃកិច្ចប្រជុំពេញអង្គប្រចាំឆ្នាំ និងក្នុងឱកាសកិច្ចប្រជុំតូចៗផ្សេងៗទៀត ដែលរៀបចំឡើងដោយអង្គភាពនានា[115]។

៤១. **ឌុច** និងសមាជិករបស់បក្សកុម្មុយនីស្តកម្ពុជា ឬសមាជិករបស់សម្ព័ន្ធយុវជនកុម្មុយនីស្ត ដែលធ្វើការនៅមន្ទីរស-២១ បានដឹងអំពីតួនាទីរបស់មជ្ឈឹមបក្សក្នុងការអនុវត្តន៍គោលនយោបាយទាំងនេះ តាមរយៈទស្សនាវដ្តីពីររបស់បក្សគឺៈ *ទង់បដិវត្តន៍* និង*យុវជនបដិវត្តន៍*[116]។ ការចោទប្រកាន់ពីបទក្បត់ជាតិ ដែលអ្នកទោសបានទទួលសារភាពក្រោមការបង្ខិតបង្ខំ ត្រូវបានលាតត្រដាងនៅក្នុងព្រឹត្តិប័ត្រទាំងនោះ ក្នុងលក្ខណៈជាការឃោសនាផ្លូវការរបស់កម្ពុជាប្រជាធិបតេយ្យ។ ឈ្មោះមនុស្សដែលខ្មែរក្រហមចោទថាក្បត់ជាតិ ដែលមានជាអាទិ៍ ដូចជា **N O P** និង **K** ត្រូវបានគេលើកឡើងជាច្រើនលើកច្រើនសានៅក្នុងអត្ថបទទាំងនោះ[117]។ **ឌុច**

បានបញ្ជាក់ថា ដើម្បីការពារសកម្មភាពរបស់បក្ស ក្នុងអំឡុងពេលនៃការប្រជុំដែលរៀបចំឡើងនៅក្រៅ មន្ទីរស-២១ ចម្លើយសារភាពទាំងនោះត្រូវបានគេចាក់តាមម៉ាញ៉េ ឬអានឱ្យអ្នកចូលរួមប្រជុំស្តាប់[118]។

៤២. **ឌុច** បានទទួលស្គាល់ថា ចាប់តាំងពីបានធ្វើជាប្រធានមន្ទីរស-២១ មក រាល់សេចក្តីណែនាំនានា ដែលធ្វើឡើងចំពោះមន្ទីរស-២១ ឬចេញមកពីមន្ទីរស-២១ ហើយដែលទាក់ទងទៅនឹងការងារសន្តិសុខត្រូវតែឆ្លងកាត់គាត់សិន[119]។ អតីតបុគ្គលិកមន្ទីរស-២១ បានបញ្ជាក់ថា **ឌុច**គឺជាអ្នកដែលមានតួនាទីក្នុងការផ្សព្វផ្សាយមាគ៌ាបក្សនៅក្នុងស-២១[120]។ នៅក្នុងសៀវភៅកំណត់ដៃរបស់អ្នកសួរចម្លើយម្នាក់ មានការកត់ត្រាសម្តីអះអាងរបស់ឌុច ដែលមានខ្លឹមសារថា សកម្មភាពនៅមន្ទីរស-២១ *“គឺជាការងារតស៊ូវណ្ណៈ ពោលគឺដើម្បីកម្ទេចវណ្ណៈជិះជាន់ ជីកគាស់ដើម និងឫសរបស់វាដើម្បីការពារបក្ស ការពារវណ្ណៈអធនការពារកម្ពុជាប្រជាធិបតេយ្យ និងការពារមាគ៌ាឯករាជ្យ និងម្ចាស់ការខ្លួនទីពឹងខ្លួន”*[121]។ សៀវភៅកំណត់ដៃរបស់អ្នកសួរចម្លើយ ឈ្មោះ F ដែលជាជំនួយការរបស់ ឌុច ទំនងជាគាំទ្រចំពោះអ្វី ដែលឌុចបានអះអាងថា ខ្លឹមសារនៃការរៀន
សូត្ររបស់បុគ្គលិកមន្ទីរស-២១ គឺបានធ្វើតាម “ការណែនាំពីថ្នាក់លើ”[122]។

៣. ការប្រើប្រាស់ “ចម្លើយសារភាព” ដែលទទួលបាននៅមន្ទីរស-២១

៤៣. ចម្លើយសារភាព និងឯកសារពាក់ព័ន្ធនានា ដែល**ឌុច**បានទទួលស្គាល់ថាត្រឹមត្រូវ បានបង្ហាញពីតួនាទីយ៉ាងសកម្មរបស់មន្ទីរស-២១ ក្នុងការ*“វាយ”* និង *“កម្ទេច”* ខ្មាំង *“ស៊ីរូងផ្ទៃក្នុង”*[123]។ ក្រៅពីការសម្លាប់អ្នកទោសដែលត្រូវបានចោទជាមុនថាជាជនក្បត់ មន្ទីរស-២១ មានតួនាទីយ៉ាងសំខាន់ក្នុងការយកចម្លើយសារភាពពីអ្នកទោសដើម្បីរែកមុខបណ្តាញក្បត់ផ្សេងទៀត។ **ឌុច** បានអះអាងថា *“អត្ថន័យនៃចម្លើយសារភាព គឺជាការងារចម្បងរបស់មន្ទីរស-២១”*[124]។ ចម្លើយសារភាពភាគច្រើនមានទំរង់ជាប្រវត្តិនយោបាយ ដែលសរសេរដោយអ្នកទោសខ្លួនឯង ហើយដោយទទួលរងនូវការបង្ខិតបង្ខំ ចម្លើយសារភាពនេះក្លាយទៅជាការបរិហារអំពី


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ខ្លួនឯង និងការចោទប្រកាន់អ្នកដទៃថាក្បត់ ព្រោះបានបម្រើឲ្យចារកម្មបរទេស ដែលជាសត្រូវរបស់បដិវត្តន៍កម្ពុជា[125] ដូចជាពួកសេអ៊ីអា(CIA) កាហ្សេបេ(KGB) និងភ្នាក់ងារបក្សកុម្មុយនីស្តវៀតណាម។ ចម្លើយសារភាពខ្លះមានរហូតដល់រាប់រយទំព័រ ដែលមិនត្រឹមតែធ្វើការពណ៌នាលំអិតអំពីការចោទប្រកាន់អំពីអំពើក្បត់ប៉ុណ្ណោះទេ ថែមទាំងបរិយាយយ៉ាងលំអិតផងដែរអំពីររចនាសម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់អង្គការបក្សគ្រប់ជាន់ថ្នាក់ និងគ្រប់អង្គភាពរដ្ឋបាលទាំងអស់។ **ឌុច**បានអាន វិភាគ ធ្វើចំណារ[126] និងសង្ខេបយ៉ាងល្អិតល្អន់[127] លើចម្លើយសារភាពភាគច្រើន ដើម្បីរាយការណ៍ជូនថ្នាក់លើ[128]។ ដូច្នេះ **ឌុច**ឋិតនៅក្នុងមុខតំណែងសំខាន់មួយ ដែលអាចអនុញ្ញាតឲ្យគាត់យល់ដឹងអំពីខ្លឹមសារនៃគោលនយោបាយរបស់បក្សកម្មុយនីស្តកម្ពុជា ដែលត្រូវបានអនុវត្តនៅមន្ទីរស-២១។

៤៤. **ឌុច**ពន្យល់ថា មន្ទីរស-២១មិនមានតួនាទីក្នុងការកំណត់ថាតើអ្នកទោសពិតជាជនក្បត់មែនឬមិនមែននោះទេ ព្រោះការចាប់ខ្លួន និងបញ្ជូនមកកាន់មន្ទីរស២១ គឺមានន័យគ្រប់គ្រាន់ថាពួកគេមានពិរុទ្ធភាពរួចទៅហើយ[129]។ ចម្លើយសារភាពដែលប្រមូលបានពីអ្នកទោសត្រូវបានយកមកធ្វើជាមូលដ្ឋាននៃការឃុំខ្លួនពួកគេ និងដើម្បីប្រើប្រាស់សម្រាប់ផលប្រយោជន៍នយោបាយ ព្រមទាំងការឃោសនារបស់អ្នកដឹកនាំបក្ស និងដើម្បីតាមរកបណ្តាញជនក្បត់ដែលពាក់ព័ន្ធផ្សេងទៀតផងដែរ[130]។ **ឌុច**បានអះអាងថា គាត់មានការសង្ស័យចំពោះភាពត្រឹមត្រូវនៃចម្លើយភាពទាំងអស់នោះតាំងពីពេលនោះមកម្លេះ ប៉ុន្តែវាជាការចង់បានរបស់ថ្នាក់លើ[131]។ **ឌុច**បញ្ជាក់ថា ខ្លឹមសារនៃចម្លើយសារភាពទាំងអស់នេះត្រូវបានប្រើជាលេស *"ដើម្បីបំបាត់អ្នកដែលបង្កើតជាឧបសគ្គតែប៉ុណ្ណោះ"* និងបានបន្តថា *"សូម្បីតែគណៈកម្មាធិការអចិន្ត្រៃយ៍បើតាមគំនិតរបស់ខ្ញុំ ក៏មិនជឿចម្លើយសារភាពទាំងស្រុងនោះទេ"*[132]។ គាត់ក៏បានទទួលស្គាល់ផងដែរថា បែបផែននៃការប្រព្រឹត្តទៅរបស់មន្ទីរស-២១ *"មានវិសមិតភាពជាមួយនឹងអត្ថិភាពនៃតុលាការ និងការធានាផ្នែកនីតិវិធី"*[133]។ គាត់បញ្ជាក់ថា ជារឿយៗគាត់តែងតែបានទទួលសេចក្តីណែនាំអំពីខ្លឹមសារជាក់លាក់ ដែលគាត់ត្រូវយកឲ្យបានពីអ្នកទោសដែលគេកំណត់ឲ្យ[134]។ ជាពិសេស គាត់បានបញ្ជាក់ថា

ក្រោមការញុះញង់របស់ថ្នាក់លើ *"ពាក្យសេអ៊ីអា(CIA) និង កាហ្សេបេ(KGB) ត្រូវបានប្រើជាដំបូងដោយអ្នកសួរចម្លើយខ្លួនឯង"*[135]។

៤៥. ឌុចនិយាយថា ដោយមិនខ្វល់ខ្វាយថាតើចម្លើយសារភាពពិត ឬមិនពិតយ៉ាងណានោះទេ គេនៅតែប្រើចម្លើយសារភាពទាំងអស់នោះដើម្បីជាលេសក្នុងការសម្រេចចាប់ខ្លួនអ្នកទាំងឡាយណា ដែលត្រូវបានបង្ហាញនៅក្នុងចម្លើយសារភាពថាជាភ្នាក់ងាររបស់ខ្មាំង។ **ឌុច** បានពន្យល់ថា *"ជាទូទៅការដែលឈ្មោះរបស់មនុស្សម្នាក់ត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពមួយផងមិនជាការគ្រប់គ្រាន់ដើម្បីឱ្យមានការចាប់ខ្លួននោះទេ"*[136]។ ចម្លើយសារភាពរបស់មនុស្សម្នាក់ ជាញឹកញាប់តែងតែនាំទៅដល់ការចាប់ខ្លួនមនុស្សច្រើននាក់ផ្សេងទៀត ដែលត្រូវបានឆ្លើយដាក់ថាជាជនក្បត់[137]។ ទំនងជាដូចគ្នានេះដែរ ឈ្មោះរបស់មនុស្សជាច្រើន ដែលស្រង់ចេញពីចម្លើយសារភាពខុសៗគ្នា ត្រូវបានប្រមូល ចងក្រងជាបញ្ជីខ្មាំង[138]។ ចម្លើយសារភាពដែលមានចំណាររបស់ឌុចបានបញ្ជាក់គាំទ្រចំនុចខាងលើ គឺថាការសារភាពរបស់អ្នកទោសត្រូវបានបញ្ជូនទៅឱ្យសមាជិកជាន់ខ្ពស់របស់បក្ស[139]។

## ឃ. ដំណើរការនៃមន្ទីរ ស-២១

៤៦. ផ្នែកខាងក្រោមនេះពណ៌នា និងវិភាគអំពីអំពើ ដែលបានប្រព្រឹត្តិជាប្រចាំថ្ងៃរបស់ **ឌុច** និងអ្នកក្រោមបង្គាប់របស់ខ្លួន នៅទួលស្លែង ព្រៃស និងជើងឯក ដោយអនុវត្តតាមនយោបាយរបស់បក្សកម្មុយនីស្តកម្ពុជា។ ផ្នែកខាងក្រោមនេះក៏បង្ហាញផងដែរ អំពីរបៀបនៃការប្រព្រឹត្តិចំពោះអ្នកទោសចាប់តាំងពីពេលចាប់ខ្លួន ក្នុងអំឡុងពេលឃុំខ្លួន នៅពេលសួរចម្លើយ និងរហូតដល់ពេលយកទៅសម្លាប់។

### ១. ការចាប់ខ្លួន និង ការឃុំឃាំង

### ក.សមាសភាពរបស់ប្រជាជនដែលជាប់ឃុំឃាំង

៤៧. ឯកសារដែលបានរកឃើញ អាចបញ្ជាក់អំពីចំនួន និងអត្តសញ្ញាណរបស់អ្នកជាប់ឃុំនៅមន្ទីរ

ស-២១។ ការិយាល័យសហព្រះរាជអាជ្ញាបានធ្វើការចងក្រងភស្តុតាងទាំងនេះ តាមរយៈការបញ្ចូលគ្នានូវបញ្ជីអ្នកទោសដើម និងបញ្ជីប្រហារជីវិត ដើម្បីបង្កើតបានជាបញ្ជីមេមួយអំពីអ្នកទោសមន្ទីរស-២១ (ដែលមានឈ្មោះថា "បញ្ជីរួមនៃអ្នកទោសមន្ទីរស-២១")[140]។ បញ្ជីទាំងនេះបានបង្ហាញថា យ៉ាងតិចណាស់ក៏មានមនុស្សចំនួន ១២៣៨០នាក់ដែរ ដែលក្នុងនោះរួមមានទាំងស្ត្រី និងកុមារផងបាន ត្រូវឃុំខ្លួននៅឯទួលស្លែង។ ប៉ុន្តែការចងក្រងបញ្ជីនេះមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ ដោយសារតែមានឈ្មោះអ្នកទោសមួយចំនួនមិនត្រូវបានគេកត់ទុក[141] និង មានឯកសារខ្លះបានបាត់។ ឌុច ឯកភាពចំពោះការអះអាងខាងលើនេះ ដោយគាត់បានលើកឡើងនូវឈ្មោះអ្នកជាប់ឃុំមួយចំនួនទៀត ដែលមិនមាននៅក្នុងឯកសារ[142]។

៤៨. អ្នកទោសនៅមន្ទីរស-២១ ភាគច្រើនជាជនជាតិខ្មែរ។ ក្រុមអ្នកទោសច្រើនជាងគេ មានសមាសភាពជាអាទិ៍ដូចជា អតីតកម្មាភិបាល កម្មករ យុទ្ធជន រួមទាំងគ្រួសាររបស់ពួកគេ[143] ដែលមកពីស្ទើរតែគ្រប់មន្ទីរ និងអង្គភាពទូទាំងប្រទេស និងមកពីភូមិភាគ និងតំបន់ស្វយ័តនានាផងដែរ។ បញ្ជីរួមនៃអ្នកទោសមន្ទីរស-២១ បានបង្ហាញនូវទិដ្ឋភាពទូទៅ ដែលថា ក្នុងចំណោមអ្នកជាប់ឃុំឃាំង មានអ្នកទោសជាមន្ត្រីរាជការនៃស្ថាប័ន និងក្រសួងនានារបស់កម្ពុជាប្រជាធិបតេយ្យ លើសពីចំនួន ៥000នាក់ និងមានជាង ៤៥00 នាក់ផ្សេងទៀតមកពី ។ អ្នកទោសដែលជាកម្មាភិបាលកម្ពុជាប្រជាធិបតេយ្យមានរាប់បញ្ចូលទាំងសមាជិកមួយចំនួនរបស់គណៈកម្មាធិការមជ្ឈិម និងគណៈកម្មាធិការអចិន្ត្រៃយ៍ ដែលមានឈ្មោះជាអាទិ៍៖ A[144] K[145] O[146] N[147] និងP[148]។ ភស្តុតាងខ្លះទៀតបានបង្ហាញថា មានអតីតភ្នាក់ងារស-២១ ប្រហែលជា ២00នាក់ ក៏បានក្លាយខ្លួនជាអ្នកទោសនៅមន្ទីរ ស-២១ ផងដែរ[149]។ ដោយឡែក បុគ្គលិកមន្ទីរស-២៤ ក៏ត្រូវបានចាប់បញ្ជូនទៅកាន់មន្ទីរ ស-២១ដែរ ប៉ុន្តែគេមិនបានដឹងអំពីចំនួនពិតប្រាកដនោះទេ។ ជនជាតិកម្ពុជាផ្សេងទៀត ដែលរួមមានអតីតទាហាន និងមន្ត្រីរដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ក៏ត្រូវបានគេឃុំខ្លួននៅមន្ទីរស-២១ ផងដែរ។ ក្រៅពីនេះមានភស្តុតាងបង្ហាញថា ក៏មានជនជាតិភាគតិចក្នុងកម្ពុជាជាប់ឃុំនៅមន្ទីរស-២១ដែរ ដូចជា ជនជាតិចាមជាដើម[150]។

៤៩. មានជនបរទេសមួយចំនួន[151]ត្រូវបានគេឃុំឃាំងនៅមន្ទីរស-២១ផងដែរ ដែលមានដូចជា៖ ជនជាតិវៀតណាម ថៃ ឡាវ ឥណ្ឌា និង“ពួកបស្ចឹមប្រទេស”[152]។ ចំនួនជនបរទេស ដែលជាប់ឃុំឃាំងច្រើនជាងគេគឺជនជាតិវៀតណាម។ នៅក្នុងបញ្ជីឈ្មោះអ្នកទោស យ៉ាងហោចណាស់ក៏មានជនជាតិវៀតណាមចំនួន ៤០០នាក់[153]ដែរ ដែលក្នុងនោះមាន ១៥០នាក់ ត្រូវបានគេចុះក្នុងកំណត់ហេតុថាជា “ឈ្លើយសឹក” និងយ៉ាងហោចណាស់ក៏ ១០០នាក់ផ្សេងទៀត ជាជនស៊ីវិល។ មានភស្តុតាងជាច្រើនទៀតបានបង្ហាញអំពីវត្តមានរបស់អ្នកទោសជាជនបរទេសនៅមន្ទីរស-២១ តាមរយៈរូបថត សក្ខីកម្ម[154] ចម្លើយសារភាព[155] និងអត្ថបទសម្រាប់ផ្សាយតាមវិទ្យុជាដើម។ ការចាប់ខ្លួនមនុស្សម្នាក់លើកដំបូង ដែលគេថាជា “ជនជាតិវៀតណាម” ហើយដែលមានសរសេរនៅក្នុងបញ្ជី គឺធ្វើឡើងនៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ១៩៧៦[156]។ ចំនួនអ្នកទោសវៀតណាមនៅមន្ទីរស-២១ បានកើនឡើងនៅពេលដែលជម្លោះជាមួយប្រទេសវៀតណាមកាន់តែតានតឹងឡើង។ **ឌុច**បានទទួលស្គាល់ថា គាត់បានដឹងថាមានជម្លោះប្រដាប់អាវុធ រវាងកម្ពុជាប្រជាធិបតេយ្យ ជាមួយនិងវៀតណាមចាប់តាំងពីពាក់កណ្ដាលខែមេសា ឆ្នាំ១៩៧៥[157] រហូតដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩[158]។ គាត់បានប្រកាសថា ជនស៊ីវិល និងទាហានវៀតណាមត្រូវបានគេឃុំខ្លួននៅមន្ទីរ ស-២១[159] ហើយបានធ្វើការប៉ាន់ស្មានថា ពួកគេមានចំនួនជាច្រើនរយនាក់[160]។

៥០. មានបញ្ជីឈ្មោះតិចតួចណាស់ដែលត្រូវបានរកឃើញជាហេតុនាំឲ្យមានលំបាកក្នុងការកំណត់ឲ្យបានច្បាស់នូវចំនួនមនុស្ស ដែលត្រូវបានគេបញ្ជូនទៅមន្ទីរស-២៤។ តែទោះបីជាយ៉ាងណាក៏ដោយ ចំនួនអ្នកជាប់ឃុំជាអចិន្ត្រៃយ៍នៅទីនោះអាចមានរហូតដល់រាប់រយនាក់[161] ហើយ **ឌុច** ក៏បានយល់ស្របលើចំនួននេះដែរ[162]។ សាក្សីជាច្រើនបាន អះអាងថា ទាំងបុរស ទាំងស្ត្រី[163] និងកុមារ[164] ត្រូវបានគេឃុំខ្លួននៅមន្ទីរស-២៤ នោះ។ **ឌុច** បានឲ្យដឹងថា ជនជាប់ឃុំឃាំងនៅព្រៃសមានពីរប្រភេទ៖ ទីមួយ ជនជាប់សង្ស័យដោយសារតែទំនាក់ទំនងសារលោហិតរបស់ពួកគេ និងទីពីរអ្នកក្រោមបង្គាប់របស់កម្មាភិបាលថ្នាក់លើដែលត្រូវបានគេចាប់ខ្លួន[165]។ មន្ទីរស-២៤ ក៏ទទួលផងដែរនូវយុទ្ធជនមកពីបណ្ដាអង្គភាពនានា

បុគ្គលិកមកពីបណ្ដាក្រសួងនិងស្ថាប័នដែលនៅជុំវិញទីក្រុងភ្នំពេញ និងសមាជិកក្រុមគ្រួសាររបស់ពួកគេ[166]។ ទោះបីជាមានភស្តុតាងផ្ទុយខ្លះៗក៏ដោយ[167] ក៏**ឌុច**នៅតែអះអាងថាគ្មានអ្នកទោសបរទេសណាម្នាក់ត្រូវបានគេបញ្ជូនទៅព្រៃសឡើយ[168]។

## ខ. ការចាប់ខ្លួន និង ការបញ្ជូនទៅមន្ទីរស-២១

៥១. **ឌុច**បានឲ្យដឹងថា គ្មាននរណាម្នាក់ត្រូវបានចាប់ខ្លួន ហើយបញ្ជូនទៅមន្ទីរ ស-២១ ដោយគ្មានសេចក្ដីសម្រេចរបស់បក្សទេ[169]។ **ឌុច**បានពន្យល់ថា ចំពោះការចាប់ខ្លួនសមាជិកគណៈកម្មា-ធិការមជ្ឈិម សេចក្ដីសម្រេចត្រូវធ្វើឡើងដោយគណៈកម្មាធិការអចិន្ត្រៃយ៍មជ្ឈិមបក្ស។ ចំពោះអ្នកដទៃទៀត **ឌុច**បាននិយាយថាគឺ G ដែលជាថ្នាក់លើរបស់គាត់ កោះហៅប្រធានអង្គភាពដែលពាក់ព័ន្ធមកពិភាក្សាដើម្បីធ្វើសេចក្ដីសម្រេចរួម។ **ឌុច**បានអះអាង ហើយ**សាក្សី** A ក៏បានសន្និដ្ឋានដែរថា ចំពោះមនុស្សដែលមកពីតំបន់ដទៃ ការសម្រេចចាប់ខ្លួនតែងតែត្រូវធ្វើឡើងដោយគណៈកម្មាធិការមជ្ឈិម ដោយធ្វើការទាក់ទងជាមួយភូមិភាគ តំបន់ ឬស្រុកនានាដែលពាក់ព័ន្ធ ដើម្បីចាប់ខ្លួនអ្នកដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាព[170]។ **ឌុច**បានបញ្ជាក់ថា លើកលែងតែអ្នកទោសសំខាន់ៗមួយចំនួន ជាទូទៅគាត់មិនបានដឹងអំពីហេតុផលដែលនៅពីក្រោយការចាប់ខ្លួនអ្នកទាំងនោះមកមន្ទីរស-២១ ឡើយ[171]។

៥២. លើសពីនេះទៀត **ឌុច**ទទូចថា "*មន្ទីរ ស-២១ មិនមានសិទ្ធិអំណាចក្នុងការចាប់ខ្លួននរណាម្នាក់ឡើយ*" ដោយគាត់បានបញ្ជាក់ថា ជាទូទៅថ្នាក់លើគ្រាន់តែប្រាប់ឲ្យគាត់ត្រៀមខ្លួនទទួលអ្នកទោសតែប៉ុណ្ណោះ[172]។ ភាគច្រើនអ្នកទោសត្រូវបានអង្គភាពរបស់ពួកគេនាំយកមកតែម្ដង[173]។ ប៉ុន្តែ ភស្តុតាងមួយចំនួនបានបង្ហាញឲ្យឃើញថា បុគ្គលិកមន្ទីរស-២១ ជួនកាលបានធ្វើការចាប់ខ្លួនដោយផ្ទាល់[174]។ **សាក្សី** B បានពន្យល់ថា នៅពេលដែលមន្ទីរ ស-២១ ត្រូវចាប់ខ្លួនមនុស្សនៅខាងក្រៅមន្ទីរ តែនៅក្នុងទីក្រុងភ្នំពេញ អាចធ្វើឡើងក្រោមរូបភាពពីរយ៉ាង៖ ទី១ គឺអង្គភាពនោះត្រូវអនុវត្តការចាប់ខ្លួនដោយខ្លួនឯង ទី២ ប្រសិនបើមនុស្សនោះត្រូវបានគេចាប់ខ្លួនរួចស្រេចហើយ អង្គភាពនោះគ្រាន់តែមានភារកិច្ចដឹកពួកគេទាំងនោះមក

កាន់មន្ទីរស-២១ ប៉ុណ្ណោះ[175]។ **សាក្សី** B ពន្យល់ថា គាត់ត្រូវបានគេចាត់ឱ្យចេញក្រៅក្រុងភ្នំពេញជាច្រើនដង ដើម្បីនាំយកអ្នកទោសទៅកាន់មន្ទីរស-២១ ហើយម្តងៗ គាត់បានទទួលបញ្ជីឈ្មោះអ្នកដែលត្រូវចាប់ខ្លួនពី**ឌុច**[176]។ **សាក្សី** C បានអះអាងថា គាត់បានដឹកអ្នកទោសមកពីខេត្តបាត់ដំបងជាមួយ I ផងដែរក្នុងឆ្នាំ១៩៧៧[177]ហើយ បានទទួលស្គាល់ទៀតថា មានម្តងនោះគាត់បានដឹកអ្នកទោសពីរនាក់ពីវិមានឯករាជ្យឆ្ពោះទៅកាន់ទ្វារចូលមន្ទីរស-២១[178]។ **សាក្សី** B បានឱ្យដឹងថា **ឌុច**ជាអ្នកផ្តល់នូវបញ្ជីឈ្មោះមនុស្សទាំងឡាយណាដែលត្រូវចាប់ខ្លួន ដោយមានការបញ្ជាក់អំពីទីកន្លែងដែលត្រូវចាប់ខ្លួន និងចំនួនកងកម្លាំងដែលចាំបាច់សម្រាប់ប្រតិបត្តិការចាប់ខ្លួន និងការបញ្ជូនអ្នកទោសទៅមន្ទីរស-២១[179]។ **សាក្សី** B បានអះអាងបន្តទៀតថា *"ពេលចាប់ តាឌុច អ្នកប្រាប់ប្លង់ និងឈ្មោះ ហើយ C អ្នកចាត់ការដោយនិរសាររបស់ឌុចផង*[180]។

៥៣. **ឌុច**បានទទួលស្គាល់ថា ក្នុងករណីចាំបាច់ កងពិសេសនៃមន្ទីរស-២១ត្រូវចាកចេញពីទីក្រុងភ្នំពេញដោយមានបទបញ្ជារបស់គណៈកម្មាធិការមជ្ឈិម ហើយកាន់លិខិតដើរផ្លូវពិសេស ដោយមានចុះហត្ថលេខារបស់ សុន សេន ដែលផ្តល់សិទ្ធិឱ្យពួកគេនាំយកអ្នកទោសមកកាន់ទួលស្លែង។ **ឌុច** បាននិយាយថា ពេលក្រោយមកប្រព័ន្ធនេះត្រូវបានបោះបង់ចោល[181] ហើយតួនាទីរបស់មន្ទីរស-២១ គឺគ្រាន់តែ *"រង់ចាំទទួលតែអ្នកទោសប៉ុណ្ណោះ គឺមិនមែនទៅចាប់ទេ"*[182]។ ទោះបីជាយ៉ាងណាក៏ដោយ ក្នុងនាមជាកម្មាភិបាលតែមួយគត់របស់មន្ទីរស-២១ ដែលមានសិទ្ធិក្នុងការប្រាស្រ័យទាក់ទងជាមួយ"ថ្នាក់លើ" មានតែ **ឌុច** ម្នាក់ប៉ុណ្ណោះដែលជាអ្នកទទួលខុសត្រូវក្នុងការអនុវត្តន៍ និងបញ្ជូនបន្តបទបញ្ជាឱ្យមានការចាប់ខ្លួន។

៥៤. ឈ្លើយសឹកវៀតណាមត្រូវបានគេចាប់ខ្លួនភាគច្រើននៅក្នុងតំបន់ដែលមានជម្លោះ ដែលស្ថិតនៅតាមបណ្តោយព្រំដែនជាមួយវៀតណាម ឬនៅជិតនោះ។ **ឌុច**បានអះអាងថា គាត់ត្រូវបានគេប្រាប់ឱ្យដឹងពីការមកដល់របស់ពួកវៀតណាម តាមរយៈការទទួលបញ្ជីឈ្មោះពី G ឬមិត្ត Q ដែលជាអ្នកក្រោមបង្គាប់ផ្ទាល់របស់ G និងជាអតីតកងការពាររបស់ ប៉ុល ពត[183]។

ឌុច ក៏បានបញ្ជាក់ទៀតថាមន្ទីរស-២១ មិនដែលទទួលបន្ទុកក្នុងការដឹកជញ្ជូនពួកវៀតណាមពីសមរភូមិមុខទេ ព្រោះនេះជាការងាររបស់អង្គភាពដែលជាអ្នកចាប់ខ្លួនពួកគេ[184]។ ផ្ទុយទៅវិញ **សាក្សី** B បានអះអាងថា ក្នុងឆ្នាំ១៩៧៧ និងឆ្នាំ១៩៧៨ **ឌុច**បានបញ្ជូនគាត់ពីរដងទៅសមរភូមិមុខក្នុងខេត្តស្វាយរៀង ដើម្បីដឹកជញ្ជូនទាហានវៀតណាមមកកាន់មន្ទីរស-២១[185]។ **សាក្សី** D បានអះអាងថា គាត់ត្រូវបានគេចាត់ឲ្យទៅធ្វើការនៅព្រំដែនក្នុងឆ្នាំ១៩៧៧ ហើយបានឃើញបុគ្គលិកមន្ទីរស-២១ ដឹកឈ្លើយសឹកវៀតណាមពីសមរភូមិតាមរថយន្តរបស់មន្ទីរស-២១[186]។

## គ. តួនាទីរបស់ឌុចនៅក្នុងការចាប់ខ្លួនអ្នកទោស

៥៥. ប្រភពជាច្រើនបានបង្ហាញថា **ឌុច**បានដើរតួនាទីដោយផ្ទាល់ក្នុងការសម្រេចមួយចំនួន ដែលឈានទៅដល់ការចាប់ខ្លួនអ្នកទោស។ ឧទាហរណ៍ នៅពេលខ្លះ**ឌុច** បានទទួលរបាយការណ៍ផ្ទាល់ពីអង្គភាពរដ្ឋបាល ឬឃោធា ពីខាងក្រៅ ស្តីអំពីការចាប់ខ្លួន[187]។ គេក៏ឃើញមានសំណៅសរសេរជាច្រើនផងដែរអំពីការទាក់ទងគ្នារវាង**ឌុច** និងលេខាកងពលធំ ៥០២ ឈ្មោះ R ទាក់ទិនទៅនឹងការបញ្ជូនអ្នកទោស[188]។ ប៉ុន្តែនៅពេលដែលគេសួរសុំឱ្យបំភ្លឺដល់ចំណុចនេះ **ឌុច**បានពន្យល់ថា ការណែនាំឲ្យ R សរសេរសំបុត្រទៅគាត់គឺជា "*ឧទាហរណ៍មួយនៃឧបាយកលប្រើប្រាស់ដោយ សុន សេន និង* G *ដើម្បីលាក់ឈ្មោះរបស់ពួកគេតែប៉ុណ្ណោះ*"[189]។

៥៦. **ឌុច**បានពន្យល់ទៀតថា នៅថ្ងៃទី ១៦ ខែកញ្ញា ឆ្នាំ១៩៧៦ គាត់បានចូលរួមកិច្ចប្រជុំជាមួយកងពលធំ២៩០ និង១៧០ ដែលគោលបំណងនៃការប្រជុំនោះគឺដើម្បីរៀបចំគម្រោងចាប់ខ្លួនអ្នកទោស។ សុន សេន និង S [190] ក៏មានវត្តមាននៅក្នុងកិច្ចប្រជុំនោះដែរ។ **ឌុច**បានឲ្យដឹងថា ការប្រជុំនេះត្រូវបានគេរៀបចំឡើង ពីព្រោះថាការចាប់ខ្លួនមនុស្សនៅក្នុងអង្គភាពតែមួយមានចំនួនច្រើនពេក។ **ឌុច**ក៏បានសារភាពដែរថា គាត់ធ្លាប់បានចូលរួមក្នុងកិច្ចប្រជុំដែលមានលក្ខណៈស្រដៀងនេះចំនួនពីរដងទៀតដែរ ដោយបានបន្ថែមថា "*ថ្នាក់លើ*" ជួនកាលបានពិភាក្សាជាមួយគាត់មុនពេលមានការចាប់ខ្លួនមនុស្ស ជាពិសេសចំពោះ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

សមាជិកបក្សសំខាន់ៗ[191]។ ឌុចបានពន្យល់ថា នៅពេលដែលមានការសម្រេចអំពីការចាប់ខ្លួន ការលក្ខការណ៍ និងការសម្លាត់គឺជាចំនុចចម្បងដើម្បីធានាមិនឲ្យមានការរត់គេច និងដើម្បីបង្ការការក្រោកឈរប្រឆាំង ជាពិសេសនៅពេលដែលការចាប់ខ្លួនមនុស្សជាច្រើនត្រូវធ្វើនៅក្នុងអង្គភាពតែមួយ[192]។ ក្នុងករណីទាក់ទិនទៅនឹងការចាប់ខ្លួនមនុស្សចំនួនច្រើននេះ ឌុចបានប្រកាសថា គាត់បានប្រគល់តួនាទីឲ្យ C ជាអ្នកពិភាក្សាជាមួយអ្នកទទួលខុសត្រូវរបស់អង្គភាពនោះ ដើម្បីកុំឲ្យមានការរំជើបរំជួលនៅក្នុងអង្គភាព និងដើម្បីសម្រួលដល់ការចាប់ខ្លួន[193]។

៥៧. លើសពីនេះទៀត ឌុច បានពន្យល់ថា សេចក្តីសម្រេចឲ្យមានការចាប់ខ្លួនគឺផ្អែកទៅលើចម្លើយសារភាពនៅមន្ទីរស-២១ ដែលមានការឆ្លើយដាក់ថាជាជនក្បត់[194]។ ឌុចបានសារភាពថាបានជួយសម្រួលដល់ សុន សេន និងក្រោយមក G ក្នុងការចាប់ខ្លួនអ្នកដែលគេគិតថាជាខ្មាំង ដោយធ្វើជាសេចក្តីសង្ខេបនៃ "ចម្លើយសារភាព" ដែលមានឈ្មោះអ្នកដែលត្រូវបានឆ្លើយដាក់ដោយអ្នកទោស ដែលត្រូវបានសួរចម្លើយ[195]។ ឌុចមិនត្រឹមតែបានរាយការណ៍ពីការឆ្លើយសារភាពលំអិតទៅសុន សេន ប៉ុណ្ណោះទេ ប៉ុន្តែគាត់ក៏បានចូលរួមសម្រេចផងដែរអំពីយុទ្ធសាស្រ្តចំពោះបុគ្គល ដែលជាមុខសញ្ញាត្រូវចាប់ខ្លួន។ ឌុចបានបញ្ជាក់ថា បន្ទាប់ពីការរាយការណ៍ទាំងនោះ មនុស្សសំខាន់ៗដែលត្រូវបានគេឆ្លើយដាក់នៅក្នុងចម្លើយសារភាពត្រូវបានគេបញ្ជូនទៅមន្ទីរស-២១ ដោយបញ្ជាក់ផងដែរថាមនុស្សមិនសូវសំខាន់ៗជាច្រើន មិនត្រូវបានចាប់ខ្លួនឡើយ[196]។

៥៨. សាក្សី A បានអះអាងថា អំណាចរបស់ឌុចក្នុងការស្នើឲ្យមានការចាប់ខ្លួនដោយការរាយការណ៍ទៅថ្នាក់លើគឺមិនបានកម្រិតត្រឹមតែបុគ្គលិកមន្ទីរស-២១ ឬតាមរយៈចម្លើយសារភាពប៉ុណ្ណោះទេ ប៉ុន្តែអំណាចនេះបានគ្របដណ្តប់ទៅលើករណីជាច្រើនទៀតផងដែរ។ ដើម្បីគាំទ្រសម្តីរបស់ខ្លួន សាក្សី A បានឲ្យឧទាហរណ៍លើករណី T ដែលជាប្រធានគណៈកម្មាធិការថាមពល ដែលត្រូវបានចាប់ខ្លួនបន្ទាប់ពីរបាយការណ៍មួយដែលធ្វើឡើងដោយឌុច[197]។ ឌុចបានទទួលស្គាល់ថា T ពិតជាត្រូវបានគេចាប់ខ្លួនមែន ប៉ុន្តែ

ឌុចបានបញ្ជាក់ថា ការចាប់ខ្លួននេះមិនមែនដោយសារឧបាយកលរបស់គាត់ឡើយ[198]។

៥៩. ជាងនេះទៅទៀត **ឌុច**ក៏មានវត្តមាននៅកន្លែងចាប់ខ្លួនយូរៗម្តងដែរ។ ឧទាហរណ៍ K ត្រូវបានគេចាប់ខ្លួននៅផ្ទះរបស់ **ឌុច**។ ករណីនេះមិនមែនមានតែម្តងនោះទេ។ **ឌុច** បាននិយាយថា *"ពួកគេបានបញ្ជូនមនុស្សមកពីឆ្ងាយដើម្បីចាប់ខ្លួននៅផ្ទះរបស់ខ្ញុំ (...)។ នៅក្នុងករណីការចាប់ខ្លួនរបស់ P មានមនុស្សបីនាក់ដែលពាក់ព័ន្ធ- គឺ ខ្ញុំ C និង P ខ្លួនឯង។ ខ្ញុំជាអ្នកដឹកនាំការចាប់ខ្លួន..."*[199]។ **សាក្សី** B និង **សាក្សី** E (អតីតអ្នកសួរចម្លើយ)អះអាងថា ជួនកាល **ឌុច**បានដឹកនាំការចាប់ខ្លួននៅទីក្រុងភ្នំពេញដោយផ្ទាល់[200]។ ទោះបីជា **ឌុច**បដិសេធថាមិនដែលចាប់ខ្លួននរណាម្នាក់[201] ដោយផ្ទាល់ក៏ដោយ ក៏ឌុចបានសារភាពថា ជួនកាលគាត់ "ទទួលបន្ទុកដោយផ្ទាល់" ចំពោះអ្នកទោសសំខាន់ៗ[202]។

## ឃ. ការចាប់ខ្លួនបុគ្គលិកមន្ទីរស-២១

៦០. បុគ្គលិកមន្ទីរស-២១ ក៏ត្រូវបានគេចាប់ខ្លួនដែរ។ ពួកគេអាចត្រូវបានបញ្ជូនទៅព្រៃសដើម្បីកសាងខ្លួន[203] ឬក៏ត្រូវឃុំខ្លួននៅទួលស្លែង[204]។ កម្មាភិបាលអាចត្រូវបានគេបញ្ជូនទៅព្រៃសចំពោះកំហុសតូចតាចឬស្ថិតក្រោមការតាមដាន ដូចជានៅពេលណាដែលកម្មាភិបាលនោះមានស្គាល់អ្នកទោសណាម្នាក់ ដែលជាប់ឃុំនៅមន្ទីរស-២១[205]។ ចំពោះកំហុសធ្ងន់ធ្ងរដូចជាបណ្តោយឱ្យអ្នកទោសរត់គេចខ្លួន ធ្វើអត្តឃាត ឬក៏ស្លាប់មុនពេលបញ្ចប់ការសួរចម្លើយ[206] អ្នកដែលទទួលខុសត្រូវ ត្រូវបានគេចាត់ទុកថាជាជនក្បត់បដិវត្តន៍ និងត្រូវបានគេចាប់ខ្លួន[207]។ ផ្ទុយទៅវិញសាក្សីជាច្រើនទៀតបានបង្ហាញថា ភាគច្រើននៃបុគ្គលិកមន្ទីរស-២១ និងជាពិសេសបុគ្គលិកដែលមកពីកងពលធំ៧០៣ ត្រូវបានចាប់ខ្លួន ទោះបីជាមិនបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរណាមួយក៏ដោយ[208]។

៦១. **សាក្សី** B បានប្រកាសថា មានតែ **ឌុច** ទេដែលអាចចេញបញ្ជាឱ្យមានការចាប់ខ្លួននរណាម្នាក់នៅក្នុងមន្ទីរស-២១។ **សាក្សី** B បាននិយាយទៀតថា បើអ្នកទោសឆ្លើយដាក់ ៧០៣

នោះ ឌុច ឱ្យគេចាប់ សួរចម្លើយ រួចសម្លាប់ *“ទាំងនេះជាបញ្ជារបស់ ឌុច។ ខ្ញុំកត់សម្គាល់ថា ក្នុងគុកនេះមានតែឌុចទេជាអ្នកសម្រេច”*[209]។ **សាក្សី** B បានផ្តល់ឧទាហរណ៍ជាក់ស្តែងអំពីកម្មាភិបាលមន្ទីរស-២១ ដែលត្រូវបានចាប់ខ្លួនតាមបញ្ជារបស់ **ឌុច** គឺ ករណី U ជាប្រធានកងរយការពារ V ជាប្រធានកងរយដែលក្រោយមកបានផ្លាស់ទៅក្រុមសួរចម្លើយ W មកពីកងរយ និងក្រោយមកទៀតគឺ X ជាកងរយដែលដកមកខាងសួរចម្លើយ។ **សាក្សី** B បាននិយាយថា *“អ្នកទាំងនោះបានស្លាប់អស់ហើយ មិនដឹង ចោទបទអ្វីទេ”*[210]។ **ឌុច** បានឆ្លើយតបថា *“ទំរង់ទី១ នៃការសំរិតសំរាំង (បញ្ជូនបុគ្គលិកទៅស-២៤) គឺជាសមត្ថកិច្ចរបស់គណៈកម្មាធិការរបស់ស-២១ ចំណែកឯទំរង់ទី២ នៃការសំរិតសំរាំង (ចាប់ឃុំខ្លួនបុគ្គលិកនៅស-២១) គឺជាសេចក្តីសម្រេចដែលត្រូវចេញដោយ សុន សេន និង* G *នាពេលបន្ទាប់មក*[211] ។ **ឌុច** បានទទួលស្គាល់ថា ពេលដែល C រាយការណ៍មកគាត់ គឺមានតែគាត់ម្នាក់គត់ដែលមានសិទ្ធិរាយការណ៍ពីកំហុសរបស់អ្នកទាំងនោះទៅថ្នាក់លើ[212]។ **ឌុច**បានអះអាងថា គាត់ធ្វើនេះគឺដើម្បីកុំឲ្យមានការជាប់ពាក់ព័ន្ធដល់ខ្លួនគាត់ ពីព្រោះ *“ម្នាក់ៗដោយភ័យខ្លាចពីអាយុជីវិតផ្ទាល់របស់ខ្លួន ត្រួតពិនិត្យ តាមដានគ្នាទៅវិញទៅមក”*[213]។ ពេលសួរថាតើអ្នកទាំងឡាយ ដែលមាននៅក្នុងសេចក្តីសង្ខេបរបស់ **ឌុច** តែងតែត្រូវបានគេចាប់ខ្លួនឬយ៉ាងណា គាត់ក៏បាន ឆ្លើយថា “ *ប្រសិនបើខ្ញុំចាំច្បាស់គឺមិនមានករណីលើកលែងទេ៖ ខ្ញុំជានិច្ចកាលរាយការណ៍ទៅថ្នាក់លើ ហើយថ្នាក់លើនេះ តែងតែបញ្ជាឱ្យចាប់ខ្លួន អ្នកដែលត្រូវបានគេឆ្លើយដាក់ទាំងនោះ”*[214]។

## ង. ស្ថានភាពនៃការឃុំខ្លួននៅទួលស្លែង

៦២. ការសម្តែងឡើងវិញដែលបានធ្វើឡើងនៅទួលស្លែង នៅថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០០៨ បានផ្តល់ជាភស្តុតាងយ៉ាងលំអិតស្តីអំពីស្ថានភាពនៃការឃុំខ្លួន។ អ្នកទោសបានចូលមកមន្ទីរ ស-២១ ស្ទើរតែរៀងរាល់ថ្ងៃ[215]។ នៅពេលនោះអ្នកទោសត្រូវបាននាំយកចូលក្នុងមន្ទីរឃុំឃាំង ហើយជាទូទៅ អ្នកទោសទាំងនោះត្រូវបានចងមុខ និងដាក់ខ្នោះដៃ[216]។ អ្នកទោសទាំងនោះត្រូវបានចុះឈ្មោះទៅក្នុងបញ្ជី[217] ហើយបញ្ជីនោះរៀបចំឡើងដោយ H ។ បន្ទាប់មក

អ្នកទោសត្រូវបានតម្រូវឲ្យប្រាប់អំពីប្រវត្តិរូប[218] ហើយគេសង្ខេបចម្លើយទាំងនោះ[219]។ ទោះបីជាយ៉ាងណាក៏ដោយ គេមិនបានប្រាប់អ្នកទោសទាំងនោះពី ហេតុផលនៃការចាប់ខ្លួនឡើយ។ នៅពេលមកដល់ អ្នកទោសត្រូវបានគេថតរូប[220] ដោយជាទូទៅ ពាក់លេខ និងពេលខ្លះ មានឈ្មោះ និងកាលបរិច្ឆេទនៃការចាប់ខ្លួន[221]។ **ឌុច**បានឲ្យដឹងថា រូបថតទាំងនោះត្រូវបានថតតាមការណែនាំរបស់ សុន សេន ដើម្បីបង្កលក្ខណៈងាយស្រួលក្នុងការចាប់ខ្លួនម្ដងទៀត ពេលដែលមានអ្នកទោសរត់គេច[222]។ បន្ទាប់មក ឆ្មាំគុកនាំ អ្នកទោសទាំងនោះចូលក្នុងបន្ទប់ឃុំឃាំង[223]។

៦៣. អ្នកទោសត្រូវគេបង្ខាំងស្ទើរតែ២៤ម៉ោងក្នុងមួយថ្ងៃ[224]។ មន្ទីរឃុំខ្លួន ស-២១ មានទាំងបន្ទប់ឃុំខ្លួនតូចៗដាច់ដោយឡែក[225] និងបន្ទប់ធំឃុំខ្លួនរួម។ នៅក្នុងបន្ទប់ឃុំខ្លួនរួម អ្នកទោសត្រូវបានគេដាក់ច្រវាក់ជើងបន្តគ្នា[226]។ **សាក្សី** F បានប្រាប់ថា គាត់មិនអាចក្រោកឡើងបានទេ[227]។ អ្នកទោសស្ត្រីមិនត្រូវបានដាក់ខ្នោះទេ[228]ប្រសិនបើពួកគេមិនបង្កបញ្ហា[229]។ អ្នកទោសទាំងអស់ ស្ថិតនៅក្រោមការឃាមកាមរបស់ឆ្មាំដែលមានអាវុធជាប្រចាំ[230]។ ឆ្មាំគុកខាងក្នុងនិងខាងក្រៅ មន្ទីរឃុំឃាំងបានទទួលការណែនាំយ៉ាងតឹងរ៉ឹង ដើម្បីទប់ស្កាត់មិនឲ្យអ្នកទោសប៉ុនប៉ងរត់គេចខ្លួន។ ក៏ប៉ុន្តែ ទំនងជាមានអ្នកទោសខ្លះបានរត់គេចខ្លួចដោយជោគជ័យ[231]។

៦៤. អ្នកទោសត្រូវបានដាក់ឲ្យឋិតនៅក្នុងស្ថានភាពរស់នៅមួយ ដែលបាត់នូវសិទ្ធិជាមូលដ្ឋានរបស់មនុស្ស។ អ្នកទោសមិនត្រូវបានអនុញ្ញាតឲ្យនិយាយគ្នា[232] ឬជាមួយឆ្មាំគុកឡើយ[233]។ នៅពេលអ្នកទោសបានមកដល់មន្ទីរស-២១ ដំបូង ពួកគេត្រូវបានសម្រាតសម្លៀកបំពាក់ចេញ ដោយទុកតែខោខ្លីប៉ុណ្ណោះ[234]។ លើសពីនេះទៀត ពួកគេមិនត្រូវអនុញ្ញាតឲ្យហាត់ប្រាណ ឬចាកចេញពីបន្ទប់ឃុំខ្លួនឡើយ[235]។ គ្មានគ្រែសម្រាប់ឲ្យអ្នកទោសដេកឡើយ[236]។ អ្នកទោសសំខាន់ៗខ្លះ ត្រូវបានគេផ្ដល់ពូកចាស់ៗឲ្យសម្រាប់ដេក ខណៈពេលដែលអ្នកទោសភាគច្រើនត្រូវដេកផ្ទាល់នឹងឥដ្ឋ[237]។ អ្នកទោសជាច្រើននាក់ត្រូវបានមូសខាំឡើងសុះខ្លួន[238]។

៦៥. ទោះបីជាឆ្មាំគុកមួយចំនួនដែលត្រូវបានគេសួរយកចម្លើយក្នុងអំឡុងពេលស៊ើបអង្កេត បានអះអាងថា ពួកគេមិនត្រូវបានអនុញ្ញាតឱ្យវាយអ្នកទោស[239] យ៉ាងណាក៏ដោយ ក៏ច្បាប់នេះមិនត្រូវបានគេគោរពឱ្យបានពេញលេញដែរ[240]។ **សាក្សី** F បានរំលឹកថា ឆ្មាំគុកបានដាក់ទណ្ឌកម្មដល់អ្នកទោស ដែលបានប្រព្រឹត្តខុស ដោយការវាយចំនួន២០០រំពាត់[241]។

៦៦. គ្មានសម្ភារៈសម្រាប់ងូតទឹកឡើយ ហើយគេមិនបានដោះខ្នោះចេញទេ ពេលដែលអ្នកទោសងូតទឹក[242]។ សាក្សីជាច្រើនបានអះអាងថា "ការងូតទឹក" ត្រូវបានគេបាញ់ទុយោទឹកពីមាត់ទ្វារ[243] ចូលមកក្នុងបន្ទប់។ អតីតឆ្មាំគុក ឈ្មោះ **សាក្សី** G បានបញ្ជាក់ថា អ្នកទោសមិនដែលត្រូវបានគេងូតទឹកសំអាតឱ្យបានស្អាតត្រឹមត្រូវឡើយ ពីព្រោះការងូតទឹកឱ្យអ្នកទោសទាំងនោះក៏ជាការសំអាតបន្ទប់ឃុំឃាំងដែរ[244]។ អ្នកទោសមិនត្រូវបានគេអនុញ្ញាតឱ្យចេញពីបន្ទប់ឃុំខ្លួនដើម្បីទៅបង្គន់ទេ ប៉ុន្តែត្រូវបានបង្ខំឱ្យ នោមដាក់ប៊ីដុងទឹក និងបន្ទោរបង់ដាក់កេះគ្រាប់ក្នុងបន្ទប់ឃុំខ្លួនរបស់ពួកគេ[245]។

៦៧. ជាធម្មតាអ្នកទោសបានទទួលអាហារគ្មានគុណភាពពីរដងក្នុងមួយថ្ងៃ ដែលជាបបររាវស្ទើរតែគ្រប់ពេល[246]។ ទោះបីជាឆ្មាំគុកខ្លះបានអះអាងថា អ្នកទោសក៏បានទទួលរបបបាយខ្លះ[247] យ៉ាងណាក៏ដោយ ក៏ភស្តុតាងបានបង្ហាញថាអ្នកទោសបានទទួលរបបអាហារតិចតួចស្ទើរតែដាច់ពោះស្លាប់[248]។ ជាលទ្ធផលនៃទង្វើនេះ អ្នកទោសជាច្រើនមានសភាពស្គមស្គាំង[249] និងបាក់កម្លាំងយ៉ាងខ្លាំង[250] ដែលជួនកាលបណ្តាលឱ្យអ្នកទោសខ្លះស្លាប់[251]។

៦៨. ឌុច បានអះអាងថា របបអាហារត្រូវបានសម្រេចដោយថ្នាក់លើ ហើយថាគាត់មិនអាចផ្លាស់ប្តូររបបអាហារនេះបានទេ។ គាត់មាននិយាយថា ការបង្អត់អាហារអ្នកទោស ជាគោលនយោបាយរបស់បក្សកុម្មុយនីស្តកម្ពុជា[252]។ ពិតណាស់ដែលថា ឆ្មាំគុក និងអ្នកទោសសំខាន់ៗបានទទួលរបបអាហារប្រសើរជាងអ្នកទោសធម្មតា[253]។

៦៩. អ្នកទោសជាច្រើនបានធ្លាក់ខ្លួនឈឺ និងមានរបួស។ សេវាពេទ្យមូលដ្ឋានត្រូវបានផ្តល់ជូន[254] ដោយក្រុមពេទ្យដែលមានតែគ្នា៣ទៅ៥នាក់សម្រាប់ធ្វើការព្យាបាលអ្នកទោសទាំងអស់


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

នៅក្នុងមន្ទីរឃុំឃាំងទាំងមូល[255]។ ពេទ្យទាំងនោះមិនបានសិក្សាវិជ្ជាពេទ្យទេ ហើយពេទ្យខ្លះគ្រាន់តែជាកូនក្មេង[256] និងធ្វើការដោយគ្មានការត្រួតពិនិត្យពីគ្រូពេទ្យឡើយ[257]។ អតីតអ្នកទោស **សាក្សី H** បានឃើញផ្ទាល់ភ្នែកនូវអ្នកទោសដែលបានទទួលការចាក់ថ្នាំតាមសរសៃនៅពេលល្ងាច ដែលក្រោយមកបានស្លាប់នៅពេលព្រឹកឡើង[258]។ អ្នកទាំងឡាយណាដែលចាំបាច់ត្រូវការព្យាបាលជាបន្ទាន់ ត្រូវបានគេទុកចោលមិនរវល់ ឬមិនបានទទួលការព្យាបាលត្រឹមត្រូវឡើយ[259]។ ឱសថព្យាបាលដែលស្តុកទុកមានតិចតួចមែនទែន។ នៅពេលដែលមានឱសថ ក៏ឱសថនោះត្រូវបានផលិតនៅកម្ពុជាដោយអ្នកដែលគ្មានជំនាញដែរ[260]។ អតីតគ្រូពេទ្យនៅមន្ទីរស-២១ ឈ្មោះ **សាក្សី I** យល់ថាគោលបំណងជាសំខាន់នៃការព្យាបាលជំងឺដល់អ្នកទោសទាំងនោះ គឺគ្រាន់តែសម្រាប់ទុកឲ្យពួកគេរស់ដើម្បីបញ្ចប់ការសួរចម្លើយតែប៉ុណ្ណោះ[261]។

៧០. មានភស្តុតាងបង្ហាញថា បុគ្គលិកនៅមន្ទីរ ស-២១ បានធ្វើការពិសោធន៍វេជ្ជសាស្ត្រទៅលើអ្នកទោស[262]។ **ឌុច**បានបញ្ជាក់ប្រាប់ថា "*ការស្រាវជ្រាវថ្នាំពុល ត្រូវបានធ្វើឡើងតាមបញ្ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍ និយាយឲ្យចំគឺ J*"[263]។ គាត់បានប្រកាសថា "*ទាក់ទងនឹងផ្នែកវេជ្ជសាស្ត្រ មានឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅ ស-២១ បីទំរង់៖ ការយកមនុស្សរស់ទៅវះកាត់ ការបូមឈាម ការយកថ្នាំពេទ្យទៅពិសោធន៍ជាមួយមនុស្សរស់*"[264]។ មានចំណារមួយរបស់ ឌុច ដែលសរសេរថា "*ពិសោធន៍ថ្នាំ*"[265]។ យោងតាមសម្តីរបស់ ឌុច បានឲ្យដឹងថា ចំណារនេះសំដៅទៅលើ "*ប្រភេទថ្នាំថ្មីបង្កើតដោយអង្គភាព៖ ចាប់ពីឆ្នាំ១៩៧១មក គេបានចាប់ផ្តើមផលិតថ្នាំពេទ្យ តាមរូបមន្តបូរាណ*"[266]។

៧១. ស្ថានភាពរស់នៅដូចបានពណ៌នាខាងលើ រួមបញ្ចូលទាំងភាពជាក់ស្តែងនៃការសួរចម្លើយ និងការបាត់ខ្លួនរបស់អ្នកទោស ដែលនៅជាមួយគ្នាបានធ្វើឲ្យប៉ះពាល់ដល់សុខភាពផ្លូវចិត្ត និងផ្លូវកាយរបស់អ្នកទោសភាគច្រើន ហើយបណ្តាលឲ្យពួកគេជាច្រើនបានស្លាប់[267]។ **សាក្សី H** បាននិយាយថា អ្នកទោសប្រាំបី ឬប្រាំបួននាក់ ដែលនៅរួមបន្ទប់ជាមួយគាត់បានស្លាប់ក្នុងរយៈពេលមួយខែ[268]។ អ្នកទោសខ្លះបានប៉ុនប៉ងសម្លាប់ខ្លួនផងដែរ[269]។

## ច. ស្ថានភាពឃុំខ្លួននៅព្រៃស

៧២. នៅព្រៃស មនុស្សទាំងអស់ត្រូវបានគេបង្ខំឲ្យធ្វើការ ដើម្បីកសាងខ្លួន ឬក៏ "លត់ដំខ្លួន"។ មន្ទីរនេះត្រូវបានប្រតិបត្តិការដោយយុទ្ធជន និងកម្មាភិបាលរបស់មន្ទីរ ស-២១។ ឌុច បានអះអាងថាមនុស្សទាំងនេះមិនមែននៅក្នុង "គុក" ដូចអ្នកទោសដែលនៅទួលស្លែងឡើយ[270] ហើយ **សាក្សី J** ដែលខ្លួនគាត់ផ្ទាល់ត្រូវបានគេបញ្ជូនទៅកសាងខ្លួននៅស២៤ ក៏បានអះអាងយ៉ាងដូច្នោះដែរ[271]។ **ឌុច**បានបញ្ជាក់បន្ថែមថា អ្នកទោស និងបុគ្គលិកនៅព្រៃសមិនអាចដើរហើរសេរីដោយគ្មានការអនុញ្ញាតឡើយ[272] (សាក្សីជាច្រើនទៀតក៏បានអះអាងបែបនេះដែរ[273]) ហើយច្បាប់នេះ ក៏ត្រូវបានអនុវត្តចំពោះរូបគាត់ផងដែរ។

៧៣. អ្នកដែលត្រូវបានបញ្ជូនទៅព្រៃសត្រូវបានដកហូតសិទ្ធិសេរីភាព។ អ្នកទោសទាំងនោះត្រូវបានឃាមការពារយ៉ាងតឹងរឹងទាំងនៅពេលធ្វើការ[274] និងទាំងនៅពេលយប់[275]។ សាក្សីបានបង្ហាញថា អ្នកដែលត្រូវបានបញ្ជូនទៅព្រៃស ត្រូវបានចែកជា៣ កម្រិត៖ ក្រុមទីមួយគឺសម្រាប់លត់ដំស្រាលៗ។ កម្រិតទីពីរ គឺសម្រាប់ករណីមធ្យម និងកម្រិតទីបីគឺសម្រាប់ករណីធ្ងន់ធ្ងរបំផុត[276]។ ស្ថានភាពនៃការដកហូតសេរីភាពមានលក្ខណៈធ្ងន់ធ្ងរជាងគេចំពោះអ្នកទាំងឡាយណាដែលស្ថិតក្នុងកម្រិតទីបី ពីព្រោះអ្នកទាំងនោះត្រូវបានគេដាក់ខ្នោះនៅពេលយប់[277] ហើយមិនត្រូវបានគេអនុញ្ញាតឲ្យរស់នៅក្នុងផ្ទះធម្មតាឡើយ[278]។ ចំពោះអ្នកដទៃទៀតដែលត្រូវបានគេអនុញ្ញាតឲ្យស្នាក់នៅក្នុងផ្ទះ[279]ទំនងជាមានអ្នកខ្លះក្នុងចំណោមពួកគេនោះត្រូវបានគេចាក់សោរបិទពីខាងក្រៅនៅពេលយប់[280]។

៧៤. អតីតអ្នកជាប់ឃុំជាច្រើនបញ្ជាក់ថាមានរបបអាហារពីរដងក្នុងមួយថ្ងៃ ម្តងនៅពេលថ្ងៃត្រង់និងម្តងទៀតនៅពេលល្ងាច[281]។ មានករណីលែកលែងតិចតួចបំផុត[282] តែជាទូទៅអ្នកទោស បានអះអាងថា អាហារនៅព្រៃសមានលក្ខណៈមិនគ្រប់គ្រាន់ទេ[283] ទោះបីជាឌុចបានទទួលស្គាល់ថា មានទិន្នផលស្រូវដែលលើសហើយត្រូវបានបញ្ជូនទៅគណៈកម្មាធិការមជ្ឈិម ក៏ដោយ[284]។ ស្ថានភាពកាន់តែធ្ងន់ធ្ងរចំពោះអ្នកជាប់ឃុំ ដែលនៅក្នុងក្រុមទី៣ ព្រោះបានទទួលរបបអាហារតិចជាង


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

អ្នកដទៃទៀត[285]។ ដូចដែលបានបញ្ជាក់ខាងលើរួចហើយ **ឌុច** បានអះអាងថា គាត់មិនអាចផ្លាស់ប្ដូររបបអាហារបានទេដោយនិយាយថា ការបង្អត់អាហារអ្នកទោស គឺជាគោលនយោបាយរបស់ថ្នាក់លើ[286]។

៧៥. អ្នកទោសនៅព្រៃសក្នុងនោះរាប់ទាំងស្ត្រី និងកុមារផងត្រូវបានបង្ខំឲ្យធ្វើការងារក្នុងវាលស្រែ រកត្រី ដាំបន្លែ ស្ទូងស្រូវ លើកទំនប់ ជីកប្រឡាយ និងជីកស្រះ[287]។ សាក្សីមួយចំនួនបាននិយាយថាពួកគេបានធ្វើការទាំងថ្ងៃ ទាំងយប់[288] ប្រាំពីរថ្ងៃក្នុងមួយអាទិត្យ និងមិនត្រូវបានអនុញ្ញាតឲ្យឈប់សម្រាកក្នុងពេលធ្វើការឡើយ[289]។ នៅព្រៃសគេចាប់ធ្វើការងារពីព្រលឹមស្រាងៗ គឺចន្លោះពីម៉ោងបួនដល់ម៉ោងប្រាំពីរព្រឹក ហើយបញ្ចប់ទៅវិញនៅចន្លោះពីម៉ោងដប់ដល់ម៉ោងដប់ពីរយប់[290]។ ពួកគេទទួលបានការឈប់សម្រាកពីរពេល ដែលក្នុងមួយពេលមួយម៉ោងសម្រាប់ទទួលទានអាហារ[291]។

៧៦. ការបំពេញការងារស្ថិតនៅក្រោមការឃ្លាំមើលរបស់អ្នកយាម[292] ដែលតម្រូវឲ្យអ្នកទោសប្រឹងប្រែងធ្វើការ និងមិនមានការអត់ឱនឡើយ ប្រសិនបើពួកគេធ្វើការយឺតយ៉ាវ[293]។ ពេលអ្នកទោសទាំងនោះ ឈឺ ឬមកយឺត ឬធ្វើការងារមិនបានជាទីពេញចិត្ត ពួកគេត្រូវបានវាយដំ និងជេរប្រមាថ[294]។ អ្នកទោសត្រូវបានដាក់ទារុណកម្មចំពោះទង្វើ "ខុសសីលធម៌ផ្លូវភេទ" ការធ្វើពុតជាឈឺ និងការលួច[295]។ អតីតអ្នកទោសឈ្មោះ **សាក្សី K** បាននិយាយថា គាត់ត្រូវបានគេវាយដំចំនួនពីរទៅបីលើកដែរ។ ជួនពេលខ្លះ អ្នកយាមដាក់ទណ្ឌកម្ម អ្នកទោសតាមរយៈការបង្អត់អាហារ[296]។ អតីតបុគ្គលិកមន្ទីរ ស-២១ ឈ្មោះ **សាក្សី C** ជាអ្នកត្រូវបាន គេចាប់បញ្ជូនទៅកសាងខ្លួននៅមន្ទីរ ស-២៤ បានពន្យល់ថាគាត់បានប្រឹងប្រែងធ្វើការ តាមតែគាត់អាចធ្វើទៅបានដើម្បីកែលម្អខ្លួន ដោយដឹងដោយខ្លួនឯងថា ប្រសិនបើគាត់មិនខិតខំធ្វើការនោះ គាត់នឹងត្រូវយកទៅសម្លាប់ចោលជាក់ជាមិនខាន[297]។

៧៧. ការប្រជុំណែនាំត្រូវបានធ្វើឡើងជាទៀងទាត់នៅឯព្រៃស ដែលក្នុងអំឡុងពេលនោះ អ្នកទោសត្រូវបានណែនាំឲ្យធ្វើការឲ្យរហ័សរហួន និងឲ្យបានផលច្រើន[298]។ ពួកគេបានត្រូវអប់រំ និងបំពាក់បំប៉ននយោបាយ[299] ហើយតម្រូវឲ្យចូលរួមក្នុងអង្គប្រជុំស្វ័យទិតៀន ដែល

ជាពេលដែលពួកគេត្រូវបានបង្ខំ ឲ្យសារភាពអំពីកំហុសរបស់ខ្លួនឯង និងប្រាប់អំពីកំហុសរបស់អ្នកដទៃ[300]។

៧៨. ការភ័យខ្លាចអំពីការចាប់បញ្ជូនខ្លួន[301] ការវាយដំ[302] ឬការសម្លាប់ កើតមាននៅគ្រប់ទីកន្លែង។ ការបាត់ខ្លួនអ្នកទោសនាពេលយប់ វាជារឿងសាមញ្ញទៅហើយ[303] ហើយកាលណាអ្នកណាម្នាក់ត្រូវបានគេនាំយកទៅ គឺអ្នកនោះឯងមិនដែលបានត្រឡប់មកវិញទេ[304]។ ឌុច មិនបានបដិសេធ ថាអ្នកទោស នៅព្រៃសខ្លះ មិនត្រូវបានចាប់បញ្ជូនទៅប្រហារជីវិតនៅជើងឯកឡើយ[305]។ ភស្តុតាងបានបង្ហាញថា គឺមនុស្សដែលមកពីកម្រិតទី៣ ងាយនឹងត្រូវគេប្រហារជីវិត តាមមធ្យោបាយនេះ[306]។ អ្នកទោសខ្លះត្រូវបានចាប់បញ្ជូនទៅទួលស្លែង[307]។ បញ្ជីរួមនៃអ្នកទោស មន្ទីរ ស-២១ បានបង្ហាញឈ្មោះយ៉ាងតិចណាស់ចំនួន៥៧១នាក់(ប្រាំរយចិតសិបមួយនាក់) ដែលត្រូវបានបញ្ជូនពីមន្ទីរ ស-២៤ ទៅកាន់ទួលស្លែង ហើយបញ្ជីនេះរាប់បញ្ចូល យ៉ាងច្បាស់នូវឈ្មោះ អ្នកទោស និងបុគ្គលិកមន្ទីរ ស-២៤ ខ្លួនឯងដែរ[308]។

## ២. ការសួរចម្លើយ

៧៩. ភាគច្រើននៃអ្នកទោសដែលត្រូវជាប់ឃុំនៅមន្ទីរ ស-២១ ត្រូវបានគេសួរចម្លើយជាលក្ខណៈប្រព័ន្ធ[309]។ ការសួរចម្លើយត្រូវបានធ្វើឡើងដោយបុគ្គលិកមន្ទីរ ស-២១ ដែល **ឌុច** និងអនុប្រធានរបស់គាត់បានរៀបចំបែងចែកជាច្រើនក្រុមផ្សេងៗគ្នា[310]។

៨០. ភស្តុតាងបានបង្ហាញថា អ្នកសួរចម្លើយមិនអាចជ្រើសរើសអ្នកទោសដែលខ្លួនចង់សួរបានឡើយ[311]។ នៅពេលទទួលបានការបែងចែងអ្នកទោស អ្នកសួរចម្លើយបានទៅយកអ្នកទោសចេញពីបន្ទប់ឃុំខ្លួន ដាក់ខ្នោះ និងចងមុខ ហើយយកអ្នកទោសនោះទៅបន្ទប់សួរចម្លើយ[312]។ ជាទូទៅទាល់តែអ្នកទោសត្រូវបានគេដាក់ខ្នោះជើងជាប់នឹងតុ ទើបពេលនោះគេដោះខ្នោះដៃចេញដើម្បីទុកឲ្យសរសេរចម្លើយសារភាពដោយខ្លួនឯង[313]។ អ្នកសួរចម្លើយបានសួរអ្នកទោស អំពីជីវប្រវត្តិ និងសកម្មភាពរបស់ពួកគេដែលនាំឲ្យមានការចាប់ខ្លួន[314]។ រាល់

ការសួរចម្លើយទាំងអស់ មិនមែនតែងតែឈានទៅដល់ចម្លើយសារភាពជាលាយល័ក្ខអក្សរជានិច្ច នោះទេ[315]។

៨១. ការសួរចម្លើយមានជារៀងរាល់ថ្ងៃពីម៉ោង៧ព្រឹក ដល់ម៉ោង១១ព្រឹក ពីម៉ោង២រសៀល ដល់ម៉ោង៥រសៀល និងពីម៉ោង៧យប់ ដល់ម៉ោង១១យប់[316]។ មិនមានគោលការណ៍ ជាទូទៅណាមួយថាតើអ្នកទោសម្នាក់ត្រូវសួរចម្លើយប៉ុន្មានលើក ឬក៏ក្នុងការសួរចម្លើយ មួយលើកត្រូវចំណាយពេលយូរប៉ុណ្ណានោះទេ[317]។ ការសួរចម្លើយត្រូវបញ្ចប់ លុះត្រាតែគេទទួលបានចម្លើយសារភាពមួយ "ជាទីពេញចិត្ត"[318]។ អ្នកទោសអាចត្រូវបានគេសួរចម្លើយច្រំដែល រីឯចម្លើយសារភាពរបស់ពួកគេវិញអាចត្រូវបានគេសរសេរព្រាងជាច្រើនលើកច្រើនសាមុននឹងយកជាផ្លូវការ[319]។

៨២. សាក្សីមួយចំនួនបានឃើញ ឌុច សួរចម្លើយអ្នកទោសនៅមន្ទីរ ស-២១[320]។ **សាក្សី** E បានអះអាងថា ការសួរចម្លើយដែលធ្វើឡើងដោយឌុច គឺវាជារឿងធម្មតា[321]។ ជាឧទាហរណ៍នៅលើចម្លើយសារភាពរបស់ Y មានចំណារថា *"អ្នកសួរចម្លើយទីមួយ ឌុច។ អ្នកសួរចម្លើយទីពីរ* G*"*[322]។ ទាក់ទិននឹងចម្លើយសារភាពនេះ **ឌុច**ទទួលស្គាល់ថាគាត់បានសរសេរចំណារនោះ ប៉ុន្តែគាត់បានអះអាងថា គាត់មិនបានសួរចម្លើយអ្នកទោសនោះទេ[323]។ **ឌុច**បានបញ្ជាក់ថា គាត់ធ្លាប់សួរចម្លើយមនុស្សតែម្នាក់គត់នៅមន្ទីរ ស-២១[324] ឈ្មោះ K ។ គាត់បាននិយាយថា គាត់ធ្វើបែបនេះតាមតែបញ្ជា សុន សេនប៉ុណ្ណោះ[325]។

៨៣. **ឌុច** បានពន្យល់ថា នៅមន្ទីរ ស-២១ គាត់បានណែនាំឱ្យប្រើវិធីសាស្ត្រសួរចម្លើយចំនួនបី៖ "វិធីសាស្ត្រត្រជាក់" "វិធីសាស្ត្រក្តៅ" និង "វិធីសាស្ត្រអង្កៀម"[326]។ វិធីសាស្ត្រត្រជាក់គឺជាការសួរចម្លើយតាមរបៀបប្រើការបញ្ចុះបញ្ចូលឃោសនា ដោយមិនធ្វើទារុណកម្ម ឬជេរស្តីឡើយ។ វិធីសាស្ត្រក្តៅរួមមាន*"ការជេរស្តី ការវាយដំ ឬការធ្វើទារុណកម្មផ្សេងទៀតដែលមានបទបញ្ជាអនុញ្ញាតឱ្យធ្វើ"*[327]។ **ឌុច**បាននិយាយថាវិធីសាស្ត្រអង្កៀមគឺជាទម្រង់មធ្យមដែលប្រើ *"គឺជាការពន្យល់លួងលោម ដើម្បីបង្កើតភាពទុកចិត្តគ្នា និងបន្ទាប់មកជំរុញសួរ ដោយឱ្យគាត់សេរសេរ"*[328]។ ទារុណកម្មត្រូវបានគេប្រើប្រាស់ផង


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ដែរ[329]។ **សាក្សី** E ក្នុងក្រុមអង្គៀមបានកត់សម្គាល់ឃើញថា ទារុណកម្មមិនត្រូវបានប្រើជាចាំបាច់តាំងពីដើមដំបូងទេ ប៉ុន្តែប្រសិនបើមិនបានលទ្ធផលគួរជាទីគាប់ចិត្តក្នុងរយៈពេលពីរ ឬបីថ្ងៃនោះ គេនឹងប្រើទារុណកម្មហើយ[330]។

៨៤. ឌុចបានទទួលស្គាល់ថាមន្ទីរ ម-១៣ បានបង្កើតឲ្យមានចម្លើយសារភាព ដែលមិនបានឆ្លុះបញ្ចាំងពីការពិតទេ។ គាត់បានពន្យល់ថា វិធីសាស្ត្រ ដែលបានប្រើនៅក្នុងការសួរចម្លើយនៅ ស ២១ បានចម្លងតាមវិធីសាស្ត្រដែលបានប្រើ នៅ ម ១៣[331]។ **សាក្សី** A ក៏បានបញ្ជាក់ដូច្នេះដែរ[332]។ សាក្សីជាច្រើនបានបញ្ជាក់ថា **ឌុច**បានត្រួតពិនិត្យ និងបានចូលរួមដោយផ្ទាល់ក្នុងដំណើរការសួរចម្លើយនៅម១៣[333]។ ភស្តុតាងបាន បង្ហាញឲ្យឃើញថា នៅដើមទសវត្សរ៍ឆ្នាំ៧០ អ្នកសួរចម្លើយនៅមន្ទីរ ម-១៣ តែងតែប្រើវិធីធ្វើទារុណកម្ម ដើម្បីបានការឆ្លើយសារភាពពីអ្នកទោស។ សាក្សីជាច្រើនបាននិយាយថា **ឌុច**ខ្លួនគាត់ផ្ទាល់ បានធ្វើទារុណកម្មអ្នកទោសនៅមន្ទីរ ម-១៣[334]។ ជាពិសេស ពួកគេបានចោទប្រកាន់ថា **ឌុច**បានយកភ្លើងអុចខ្លួនអ្នកទោស បានវាយ អ្នកទោសនឹងដំបងឫស្សី និងបានជ្រមុជអ្នកទោសចូលក្នុងទឹក[335]។

## ក. ការប្រើប្រាស់ទារុណកម្មជាប្រព័ន្ធក្នុងពេលសួរចម្លើយ

៨៥. **ឌុច**បានបញ្ជាក់ថា ការធ្វើទារុណកម្មនៅមន្ទីរ ស-២១ មានលក្ខណៈជាប្រព័ន្ធ ដោយនិយាយថា *"អ្នកណាដែលគេយកទៅសួរ ច្រើនជៀសមិនរួចពីទារុណកម្ម"*[336]។ នយោបាយទូទៅបែបនេះ ហាក់បីដូចជាត្រូវបានគេយកមកអនុវត្តចំពោះអ្នកទោសទាំងអស់ ដូចៗគ្នា ដោយមិនគិតអំពីហេតុផលនៃការចាប់ខ្លួននោះទេ[337]។ លើកលែងតែ **សាក្សី** A ម្នាក់ប៉ុណ្ណោះ[338] ក្រៅពីនេះអ្នកសួរចម្លើយទាំងអស់សុទ្ធតែបានសារភាពថាបានប្រើទារុណកម្មលើ អ្នកទោស[339]។ បន្ថែមពីលើចំណុចនេះ ឯកសារជាច្រើនពីមន្ទីរស-២១បានបង្ហាញយ៉ាងច្បាស់នូវចំណារឲ្យធ្វើទារុណកម្ម[340]។ ឌុច បានពន្យល់ថា *"ស្ថានភាពគឺដូចតទៅនេះ៖ ចំពោះយុទ្ធជនសាមញ្ញ* C *ជាអ្នកចាត់ចែងទាំងអស់ ហើយអាចបញ្ជាឲ្យធ្វើទារុណកម្មបាន។*


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

*ចំពោះអ្នកទោសសំខាន់ ដូចជា* O *ជាដើម គឺសុន សេន ជាអ្នកបញ្ជាមកខ្ញុំ និងជាអ្នកសម្រេចអំពីការធ្វើទារុណកម្ម*[341]។

៨៦. សៀវភៅកំណត់ដៃចំនួនបីក្បាលរបស់អ្នកសួរចម្លើយនៅមន្ទីរស-២១ មានដូចជា *"បញ្ជីស្ថិតិនៃមន្ទីរសន្តិបាលស-២១ នយោបាយ មនោគមវិជ្ជា និងអង្គការចាត់តាំង"*[342] (តទៅនេះហៅថា៖ *បញ្ជីស្ថិតិ*) *"សៀវភៅកំណត់ដៃរបស់* F*"* (របស់ F)[343] និង *"សៀវភៅកំណត់ដៃរបស់* G *និង* Z*"*[344]បានរៀបរាប់យ៉ាងលម្អិតអំពីវិធីសាស្ត្រនៃការសួរចម្លើយ និងការធ្វើទារុណកម្ម នៅមន្ទីរស-២១។ *បញ្ជីស្ថិតិ*នេះ (ប្រភពខ្លះបានហៅដោយខុសថាជា *"សៀវភៅណែនាំអំពីការធ្វើទារុណកម្ម"* និងដែលគេគិតថាក្នុងនោះមានកំណត់ត្រារបស់អ្នកសួរចម្លើយម្នាក់) [345] មានការណែនាំដែលមានលក្ខណៈនយោបាយ ទាក់ទងទៅនឹងរបៀបសួរចម្លើយ ដោយបង្រៀនអ្នកសួរចម្លើយ *"ឲ្យបំបាក់ស្មារតីអ្នកទោសដោយការអប់រំសតិអារម្មណ៍ ឬការធ្វើទារុណកម្ម"*[346]។ ឯកសារនេះបានណែនាំផងដែរថា "*ប្រសិនបើអង្គការប្រាប់ថាកុំឲ្យវាយ កុំវាយដាច់ខាត។ ប្រសិនបើបក្សបញ្ជាឲ្យយើងវាយ យើងត្រូវវាយដោយម្ចាស់ការ វាយពួកវាឲ្យទាល់តែនិយាយ កុំឲ្យរួចខ្លួនដោយសេចក្ដីស្លាប់ កុំឲ្យពួកវាអស់កម្លាំងដល់ថ្នាក់ធ្លាក់ខ្លួនឈឺ ហើយស្លាប់*"[347]។ ឌុច បានបញ្ជាក់ថាការណែនាំ និងមនោគមវិជ្ជានយោបាយ ដែលមាននិយាយ នៅក្នុង*សៀវភៅកត់ត្រារបស់* F និង *បញ្ជីស្ថិតិ* បានឆ្លុះបញ្ចាំងយ៉ាងពិតប្រាកដអំពី ការបង្រៀន និងការណែនាំរបស់ឌុច ហើយជាសំខាន់គឺថាខ្លឹមសារនៃការណែនាំ ទាំងអស់នោះជា "គំនិត" របស់ឌុច[348]។

៨៧. បុគ្គលិកទូទាំងមន្ទីរ ស-២១ បានដឹងអំពីការធ្វើទារុណកម្ម។ អ្នកយាមម្នាក់ឈ្មោះ **សាក្សី L** បាននិយាយថា គាត់បានរៀនសូត្រពីគោលការណ៍ធ្វើទារុណកម្ម "*ពីឌុច នៅកន្លែងសាលារៀន ពីប្រធានកងរយ ប្រធានកងហា ពួកគាត់ថាអ្នកទោសគឺជាខ្មាំង ហើយបើមិនឆ្លើយអាចធ្វើទារុណកម្មបាន*" [349]។

៨៨. ផលវិបាកផ្នែករាងកាយអំពីការរងទារុណកម្ម ដែលអាចមើលឃើញយ៉ាងច្បាស់ (ស្នាមរបួស ការហូរឈាម ស្នាមជាំ អ្នកទោសសន្លប់ និងអ្នកខ្លះបាត់ក្រចកដៃ ក្រចកជើង) នាំឲ្យ

អតីតបុគ្គលិកមន្ទីរស-២១ ដែលត្រូវបានសម្ភាសន៍ ស្ទើរតែទាំងអស់ សុទ្ធតែទទួលស្គាល់ថា ពួកគេអាចដឹងថា មានការធ្វើទារុណកម្មបែបនេះមែន ទោះបីជាពួកគេមិនបានចូលរួមដោយផ្ទាល់ក៏ដោយ[350]។ ឧទាហរណ៍ **សាក្សី M** បានរាយការណ៍ថាអ្នកទោសភាគច្រើននៅមន្ទីរ ស-២១ *"មានរបួស មានហើមមុខ និងខ្លោចម្ដុំត្រចៀក ដោយសារឆក់ខ្សែភ្លើង"*[351]។ អ្នកយាមមួយចំនួនបានឲ្យដឹងថា ពួកគេផ្ទាល់បានឃើញ[352] ឬបានឮ[353]អំពីការធ្វើទារុណកម្ម។

៨៩. ការប្រើប្រាស់ទារុណកម្មនៅក្នុងពេលសួរចម្លើយ គឺដើម្បីទទួលបាននូវចម្លើយ ដែលមានលក្ខណៈ "ពេញលេញ" ដែលរួមមាន បទល្មើសដែលអ្នកទោសត្រូវគេចោទ និង ឈ្មោះជនដែលគេសន្មត់ថាជារបស់ខ្មាំងរបស់របបនោះ[354]។ ទាក់ទិននឹងអ្នកទោសវៀតណាម **ឌុច** បានបញ្ជាក់ថា គោលបំណងនៃការសួរចម្លើយគឺដើម្បីទទួលបានការសារភាពថា *"វៀតណាមបានឈ្លានពានប្រទេសកម្ពុជា ដើម្បីបញ្ចូលកម្ពុជាក្នុងសហព័ន្ធឥណ្ឌូចិន"*[355]។ ខុសពីអ្នកទោសកម្ពុជា ការសួរចម្លើយអ្នកទោសវៀតណាមត្រូវគេថតយកសម្លេង ហើយចម្លើយសារភាពមួយចំនួនរបស់ពួកគេត្រូវបានផ្សព្វផ្សាយតាមវិទ្យុក្នុងគោលដៅធ្វើការឃោសនា[356]។ ប្រតិចារិតនៃចម្លើយសារភាពជាង៥០ របស់អ្នកទោសវៀតណាម ដែលបានផ្សព្វផ្សាយតាមវិទ្យុ មាននៅក្នុងសំណុំរឿង[357]។ យោងតាមសម្ដីរបស់ **ឌុច** គោលបំណងពិតគឺមិនមែនដើម្បីសួរចម្លើយឈ្លើយសឹកអំពីផែនការយោធារបស់វៀតណាមនោះទេ[358]។ ប៉ុន្តែ **សាក្សី A** បានអះអាងថា អ្នកទោសទាំងនេះត្រូវបានគេបង្ខំឲ្យផ្ដល់ព័ត៌មានទាក់ទងនឹងសមរភូមិ និងយុទ្ធសាស្ត្រនៃការប្រយុទ្ធ[359]។ ផ្អែកទៅលើឯកសារផ្សេងទៀតដែលរក្សាទុកនៅមន្ទីរ ស-២១ ចម្លើយនេះបានបង្ហាញយ៉ាងច្បាស់ថា ការសួរចម្លើយឈ្លើយសឹកមានគោលបំណងពីរយ៉ាង គឺការឃោសនា និងការប្រមូលពត៌មាន។

## ខ. ការចូលរួមធ្វើទារុណកម្មដោយផ្ទាល់របស់ ឌុច

៩០. នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត **ឌុច**បានបដិសេធជានិច្ចថា មិនដែលបានធ្វើទារុណកម្មលើអ្នកទោសនៅមន្ទីរ ស-២១ទេ[360]៖ **ឌុច** គ្រាន់តែបានទទួលស្គាល់ថា កាល

ពីពេលដែលគាត់នៅជាអនុលេខា មានពេលខ្លះគាត់ បាន "*អន្តរាគមន៍*" ក្នុងពេលមានការសួរចម្លើយដែលធ្វើឡើងដោយបុគ្គលិកមន្ទីរ ស-២១។ នៅក្នុងការធ្វើអន្តរាគមន៍ មានពេលខ្លះ គាត់បាន"*ទះកំផ្លៀងអ្នកទោសមួយ ឬពីរដែរ*"។ ឌុចបានបន្ថែមទៀតថា គាត់បានបន្តសកម្មភាពនេះរយៈពេលមួយខែ ឬពីរខែ ក្រោយពេលដែលគាត់ត្រូវបានតែងតាំងជាប្រធាននៃមន្ទីរនេះ[361]។

៩១. នៅក្នុងការអះអាងរបស់គាត់មុនៗ ឌុចបានទទួលស្គាល់ថា បានធ្វើទារុណកម្មលើអ្នកទោសជាពិសេសលើ K[362] តែចម្លើយទាំងនេះមិនមានលក្ខណៈច្បាស់លាស់ទាំងស្រុងនោះទេ។ នៅក្នុងពេលស៊ើបសួរ ឌុចបានទទួលស្គាល់ថាបានសួរចម្លើយ K មែន ប៉ុន្តែគាត់បានបញ្ជាក់ថា សុន សេន បានបញ្ជាគាត់មិនឱ្យធ្វើទារុណកម្មទេ[363]។

៩២. សាក្សីមួយចំនួនប្រកាសថាបានឃើញ ឌុច បានវាយអ្នកទោសជាច្រើន ដូចជាបានទាត់អ្នកទោស[364] វាយបុរសម្នាក់ដោយប្រើរំពាត់ផ្ដៅ[365] ឬបានវាយអ្នកទោសនឹងដៃ[366]។ សាក្សីម្នាក់ក៏បានឃើញ ឌុចវាយអ្នកទោសម្នាក់នៅខាងមុខមន្ទីរស-២១[367] ដែរ។

៩៣. **សាក្សី** E បានប្រាប់ថា គាត់បានឃើញឌុចធ្វើទារុណកម្មនារីម្នាក់ដោយឆក់ខ្សែភ្លើង នៅពេលកំពុងសួរចម្លើយ។ គាត់បានប្រាប់អ្នកស៊ើបអង្កេតថា ឌុច និងអ្នកសួរចម្លើយប្រាំ ឬប្រាំមួយនាក់ទៀត ដែលរួមមាន F AA BB CC និង G បានធ្វើទារុណកម្មនារីនោះចាប់ពីម៉ោង៩យប់ដល់ម៉ោង៣ព្រឹក ហើយដោយសារតែនារីនោះមិនព្រមសារភាព ពួកគេបានបន្តវាយនាងរហូតដល់សន្លប់។ **សាក្សី** E បានបន្ថែមថា នៅពេលសួរទៅវាមិនចេញ ឌុចធ្វើទារុណកម្ម រ៉ៃ ឆក់ខ្សែភ្លើង និងដោះអាវចេញ នៅតែខោវែងប៉ុណ្ណោះ។ ឌុចបានវាយធ្វើបាបនាងរហូតដល់ខ្លួនអស់កម្លាំងរួចទុកឱ្យអ្នកសួរ ចម្លើយម្នាក់ទៀតមកបន្តធ្វើទារុណកម្មនាង រីឯគាត់នៅចាំស្ដាប់ការឆ្លើយរបស់នាងវិញម្ដង។ គាត់បាននិយាយថា ពួកអ្នកសួរចម្លើយបានសើចសប្បាយនៅពេលដែលពួកគេធ្វើទារុណកម្មលើនារីនោះ[368]។ ឌុចបានបដិសេធការចោទប្រកាន់នេះ ដោយនិយាយថា **សាក្សី** E បានប្រឌិតរឿងនេះឡើងដើម្បីលាក់បាំងអំពើផ្ទាល់ខ្លួន[369]។ **សាក្សី** A ក៏បានបដិសេធចំពោះហេតុការណ៍

ឆក់ខ្សែភ្លើងដែលបានកើតឡើងលើនារីនោះផងដែរ[370]។

៩៤. ផ្ទុយទៅវិញ **ឌុច**បានទទួលស្គាល់ថា ពិតជាមានហេតុការណ៍មួយផ្សេងទៀត ដែលបានកើតមានឡើងរវាងអ្នកទោសនិងអ្នកទោស ដូចដែល **សាក្សី** N បានរៀបរាប់មែន៖ **សាក្សី** N បាននិយាយថា ថ្ងៃមួយនៅក្នុងបន្ទប់ជាងគំនូរ **ឌុច** បានបញ្ជាគាត់ឱ្យវាយតប់គ្នាជាមួយជាងចម្លាក់ម្នាក់ឈ្មោះ DD ដោយឱ្យវាយគ្នានឹងទុយោកៅស៊ូ។ **ឌុច** បានទទួលស្គាល់ហេតុការណ៍នេះ ប៉ុន្តែ គាត់មិនចាំពីមូលហេតុដែលធ្វើឱ្យគាត់បញ្ជាដូច្នេះទេ[371]។

៩៥. សាក្សីជាច្រើន រួមមានទាំងអតីតអ្នកសួរចម្លើយនៅមន្ទីរ ស-២១ បានពន្យល់ថា **ឌុច** ក្នុងឋានៈជាប្រធានមន្ទីរ បានបញ្ជាឱ្យមានការធ្វើទារុណកម្មលើអ្នកទោស។ **ឌុច** មិនបានបដិសេធហេតុការណ៍នេះទេ ដោយបញ្ជាក់ថា *"បើអ្នកទោសជាអ្នកសំខាន់បន្ទាប់ ខ្ញុំប្រគល់ឱ្យមិត្ត Z ព្រោះមិត្ត Z ចូលចិត្តធ្វើទារុណកម្មណាស់... នៅពេលដែលអ្នកទោសមិនឆ្លើយ ខ្ញុំប្រាប់ G ថាត្រូវបញ្ជូនអ្នកទោសទៅឱ្យ Z"*[372]។ **សាក្សី** E បានប្រាប់ថា **ឌុច** បានបង្រៀនដោយផ្ទាល់ដល់អ្នកសួរចម្លើយ អំពីការធ្វើទារុណកម្ម ដោយបានបញ្ជាក់ថា *"ក្នុងការធ្វើទារុណកម្មហ្នឹងក៏គេណែនាំដែរ ឆក់ខ្សែភ្លើង វ៉ៃ ច្រកស្បោងកៅស៊ូ ដកក្រចក ប៉ុន្តែហាមមិនឱ្យងាប់"*[373]។

៩៦. **សាក្សី** E បានបញ្ជាក់ទៀតថា អ្នកសួរចម្លើយនៅមន្ទីរស-២១ មានសិទ្ធិធ្វើទារុណកម្ម ប្រសិនបើអ្នកទោសណាម្នាក់មិនព្រមឆ្លើយ។ គាត់បាននិយាយថា ការធ្វើទារុណកម្ម ត្រូវសម្រេចដោយ**ឌុច**ដោយផ្ទាល់មាត់ ឬតាមទូរស័ព្ទ។ **សាក្សី** E បានបន្តថា នៅពេលណាដែលគាត់មិនអាចធ្វើឱ្យអ្នកទោសណាម្នាក់ឆ្លើយ គាត់បានសុំការណែនាំពី **ឌុច** ហើយ **ឌុច** ឆ្លើយថា *"អញ្ចឹងធ្វើទារុណកម្មទៅ"*[374]។

៩៧. អ្នកសួរចម្លើយម្នាក់ទៀតឈ្មោះ **សាក្សី** G បាននិយាយថា គាត់បានទទួលការណែនាំជាញឹកញាប់ពី **ឌុច** ដែលនៅរៀងរាល់បួន ឬប្រាំថ្ងៃម្តងបានបង្រៀនអំពីរបៀបរបបសួរចម្លើយ និងប្រាប់អំពីចំណុចខ្សោយរបស់អ្នកទោស។ **សាក្សី** G បានបន្ថែមទៀតថា *"ចំពោះ*


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

*ខ្លួនខ្ញុំផ្ទាល់ ខ្ញុំមិនមានសិទ្ធិធ្វើទារុណកម្មទេ ពីព្រោះខ្ញុំគឺជាអ្នកសួរចម្លើយថ្មី។ ការធ្វើទារុណកម្មគឺប្រគល់ទៅឲ្យ C ។ ចំណែកអ្នកសួរចាស់ៗ គឺមានសិទ្ធិធ្វើទារុណកម្ម*" [375]។

៩៨. ចំណែក**ឌុច**វិញ គាត់បានទទួលស្គាល់ថា គាត់បានបញ្ជាឲ្យមានការធ្វើទារុណកម្មលើអ្នកទោសទៅតាមកម្រិតខុសៗគ្នា។ ប៉ុន្តែ គាត់បានអះអាងថា គាត់បានបង្រៀនពីបច្ចេក-ទេសសួរចម្លើយតែម្តងគត់ កាលពីពេលដែលគាត់នៅជាអនុប្រធានក្រោមបង្គាប់របស់ B ។ គាត់បានបន្តទៀតថា "*ការបណ្តុះបណ្តាលមានរយៈពេលប្រហែលមួយអាទិត្យ និងពីរម៉ោងក្នុងមួយថ្ងៃ។ បន្ទាប់មក ខ្ញុំបានហៅមិត្តម្នាក់ដើម្បីផ្តល់ដំបូន្មាន ឬកែកំហុស គេ...។ ពាក្យណែនាំគឺថា មិនត្រូវពឹងផ្អែកលើការធ្វើទារុណកម្មពេកទេ ហើយត្រូវចេះអត់ធ្មត់*"[376]។ ជាងនេះទៅទៀត **ឌុច**បានទទួលស្គាល់ថា គាត់ជាអ្នកកំណត់នូវវិធាននានាសំរាប់ការសួរចម្លើយ[377]។

៩៩. នៅពេលដែលសហចៅក្រមស៊ើបអង្កេតបង្ហាញពីចម្លើយសារភាព ដែលមានចំណារ **ឌុច** បានទទួលស្គាល់នូវបញ្ជាឲ្យមានការធ្វើទារុណកម្មចំនួនបី ដែលគាត់បានសរសេរដោយផ្ទាល់ដៃ។ **ឌុច**បានបញ្ជាក់ថា គាត់ជាអ្នកសរសេរថា: "*អ្នកដែលមិនទាន់សារភាពត្រូវធ្វើទារុណកម្ម*" ហើយក្រោយមកទៀតថា "*សួរចម្លើយឲ្យបានល្អិតល្អន់ ឲ្យបានច្បាស់លាស់ ប៉ុន្តែធ្វើទារុណកម្មល្មមៗបានហើយ ដើម្បីរកឲ្យឃើញខ្សែរយៈផ្សេងៗ។ វាយរហូតដល់នាងឈប់និយាយថានាងបានទៅរៀតណាមជាមួយតារបស់នាងដើម្បីព្យាបាលជម្ងឺមហារីករបស់គាត់ និងព្យាបាលបញ្ហាមានរដូវ*"។ **ឌុច**បានអះអាងថា ពេលដែលចេញបញ្ជាចំនួនពីរដំបូង គាត់មិនទាន់បានក្លាយជាប្រធានមន្ទីរ ស-២១ នៅឡើយទេ ហើយពេលនោះគាត់គ្រាន់តែបញ្ជូនបញ្ជារបស់ថ្នាក់លើគឺ B និង សុន សេន ប៉ុណ្ណោះ[378]។ ផ្ទុយទៅវិញចំពោះបញ្ជាចុងក្រោយ **ឌុច** បានទទួលស្គាល់ថា គាត់បានសរសេរទៅកូនចៅរបស់គាត់ គឺ G ដែលជាអ្នកសួរចម្លើយ ឲ្យធ្វើទារុណកម្ម ហើយធានាថា បើសិនណាការធ្វើទារុណកម្មនេះបណ្តាលឲ្យអ្នកទោសស្លាប់នោះ G នឹងមិនត្រូវគេផ្តន្ទាទោសនោះទេ។ **ឌុច**បានអះអាងនៅពេលនោះ គាត់បានទទួលបញ្ជាពី សុន សេន តាមទូរស័ព្ទ[379]។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

## គ. វិធីធ្វើទារុណកម្ម

១០០. អ្នកសួរចម្លើយ បានប្រើវិធីធ្វើទារុណកម្មតាមរូបភាពជាច្រើន ដើម្បីទទួលបានចម្លើយសារភាពពីអ្នកទោស។ យោងតាមសម្ដីឌុច មានតែវិធីធ្វើទារុណកម្មចំនួនបួនប៉ុណ្ណោះ ដែលត្រូវបានអនុញ្ញាតឲ្យប្រើ៖ ការវាយ ការឆក់ខ្សែភ្លើង ការច្រកក្បាលក្នុងថង់ប្លាស្ទិក និងការបន្តក់ទឹកចូលក្នុងច្រមុះ[380]។

១០១. ឌុចបានបញ្ជាក់ថា វិធីដែលប្រើច្រើនជាងគេ គឺការវាយដោយដំបង ពីព្រោះវិធីផ្សេង ទៀតច្រើនតែធ្វើឲ្យខាតពេលវេលា[381]។ ប្រសិនបើអ្នកទោសមិនសារភាពឲ្យបានត្រឹមត្រូវទេ ការធ្វើទារុណកម្មកាន់តែមានលក្ខណៈឃោរឃៅឡើង។ រាល់ការសារភាពដែលមិនច្បាស់លាស់ មិនគ្រប់គ្រាន់ ឬមិនមានរៀបរាប់ឈ្មោះ "ជនក្បត់" ផ្សេងទៀត ត្រូវបានចាត់ទុកថា មិនអាចទទួលយកបានទេ[382]។

១០២. ឌុច បាននិយាយថា គាត់មិនបានដឹងអំពីវិធីធ្វើទារុណកម្មផ្សេងទៀតទេ[383] ហើយមានវិធីមួយចំនួនត្រូវបានហាមឃាត់នៅមន្ទីរស-២១ ផងដែរ។ ក្រៅពីនេះ ឌុចបានទទួលស្គាល់ដែរថា គាត់បានដឹងអំពីការចាក់ទម្លុះ ឬការដកក្រចកដៃ និងក្រចកជើង។ គាត់បានបន្ថែមទៀតថា ពេលដែលគាត់បានដឹងពីវិធីទាំងនេះគាត់មានប្រតិកម្មភ្លាម ហើយបានសរសេររបាយការណ៍មួយ[384] ប៉ុន្តែ មិនមានភស្តុតាងណាមួយដែលបង្ហាញថា គាត់បានដាក់វិន័យចំពោះអ្នកសួរចម្លើយ ដែលបានធ្វើទារុណកម្មឬប្រើវិធីធ្វើទារុណកម្មដោយគ្មានការអនុញ្ញាត។ ជាក់ស្ដែង សាក្សី E បាននិយាយថា វិធីធ្វើទារុណកម្មបែបនេះ គឺ ឌុច ខ្លួនឯងហ្នឹងជាអ្នកណែនាំឲ្យគេធ្វើ[385]។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿងបានបង្ហាញអោយឃើញថា មានអ្នកទោសយ៉ាងហោចណាស់ម្នាក់ដែរ ដែលត្រូវបានបង្ខំឲ្យស៊ីលាមក។ ត្រង់ចំនុចនេះ ឌុចនិយាយថា គាត់"ចង់បដិសេធគំនិត" ដែលថា គាត់បានដឹងអំពី "ការអនុវត្តន៍" បែបនេះ[386] ប៉ុន្តែគាត់មិនអាចចងចាំច្បាស់អំពីចំណុចលំអិតទាំងនេះទេពីព្រោះគាត់បានផ្ដោតការចាប់អារម្មណ៍ជាសំខាន់ទៅលើចម្លើយសារភាព និងមិនបានយកចិត្តទុកដាក់ចំពោះស្ថានភាពដែលគេបានប្រព្រឹត្តចំពោះអ្នកទោសនោះឡើយ[387]។ គាត់ក៏បានទទួលស្គាល់ដែរថា ទឹកត្រជាក់

និងកង្ហារក៏ជាវិធីដែលបានប្រើនៅមន្ទីរស-២១ដែរ ហើយថា គាត់មិនបានជំទាស់នឹងការអនុវត្តន៍នេះទេ[388]។ យោងតាមសម្តីរបស់ **សាក្សី** J ការប្រព្រឹត្តិសាហាវឃោរឃៅផ្សេងៗមួយចំនួនទៀតដូចជា ការសម្រាតខោអ្នកទោស រួចយកប្រដាប់ឆក់ ឆក់ប្រដាប់ភេទ ឬត្រចៀកអ្នកទោស[389]។ នៅពេលធ្វើការសម្តែងឡើងវិញ មានការលើកឡើងពីការប្រើប្រាស់ អាងត្រាំទឹក ដើម្បីធ្វើទារុណកម្មអ្នកទោស។ អាងត្រាំទឹកនេះ បច្ចុប្បន្នត្រូវបានដាក់តាំងនៅសារៈមន្ទីរប្រល័យពូជសាសន៍ទួលស្លែង។ **សាក្សី** L បានបញ្ជាក់ថា គាត់បានឃើញអាងត្រាំទឹកមួយ ហើយ **សាក្សី** H បានបញ្ជាក់ថា ជនជាតិវៀតណាមម្នាក់បានរៀបរាប់ប្រាប់គាត់ថា ខ្លួនធ្លាប់ត្រូវបានគេធ្វើទារុណកម្មនៅក្នុងអាងត្រាំទឹកនេះ។ ប៉ុន្តែ **ឌុច**បានបញ្ជាក់ថា គាត់មិនដែលបានបញ្ជាឲ្យប្រើអាងត្រាំទឹកទេ ហើយក៏មិនបានដឹងអំ ពីការប្រើប្រាស់អាងត្រាំទឹកនេះដែរ[390]។ ការស៊ើបអង្កេត ក៏បានបង្ហាញយ៉ាងច្បាស់ពីការប្រើវិធីសាស្ត្រផ្សេងៗក្នុងពេលសួរចម្លើយ ដូចជាការបង្ខំអ្នកទោសឲ្យលុតជង្គង់គោរពរូបផ្តែ[391]។ នៅចំពោះមុខសហចៅក្រមស៊ើបអង្កេត **ឌុច**បានទទួលស្គាល់ថា គាត់ដឹងអំពីការអនុវត្តន៍នេះ ប៉ុន្តែពីដំបូង គាត់មិនបានគាំទ្រទេ ក្រោយមកគាត់បានទទួលស្គាល់ថា គាត់ពិតជាបានជំរុញឲ្យមានការធ្វើបែបនោះនៅក្នុងវគ្គបណ្តុះបណ្តាលអ្នកសួរចម្លើយមួយ កាលពីថ្ងៃទី២៨ ខែឧសភា ឆ្នាំ១៩៧៨[392]។ លើសពីនេះទៅទៀត **សាក្សី** H ចាំថា គាត់បានឃើញអ្នកយាម បាននាំអ្នកទោសម្នាក់ទៅកាន់បង្គោលចងខ្សែពួរ រួចហើយចងជើងអ្នកទោសនោះព្យួរឡើងលើ និងជ្រមុជក្បាលចូលក្នុងពាងទឹក។ **សាក្សី** H បានតាមដាន សកម្មភាពនេះតាមបង្អួចបន្ទប់គូររូប[393]។

១០៣. អតីតអ្នកទោសមន្ទីរ ស-២១ ចំនួនពីរនាក់ បានរៀបរាប់ប្រាប់អ្នកស៊ើបអង្កេត អំពីទារុណកម្ម ដែលពួកគេបានទទួល។ **សាក្សី** F បាននិយាយថា គាត់ត្រូវគេវាយនឹងឈើមួយកំណាត់នៅលើខ្នងគាត់ជាច្រើនលើកច្រើនសារ[394]។ ក្រោយមកទៀត អ្នកសួរចម្លើយបានចាប់ដកក្រចកជើងទាំងសង្ខាងរបស់គាត់។ គាត់ក៏បានប្រាប់ទៀតថា ទងត្រចៀករបស់គាត់ក៏ត្រូវគេឆក់ខ្សែភ្លើងដែរ ហើយនៅថ្ងៃទីបីនៃការសួរចម្លើយ គាត់បានសន្លប់ចំនួនពីរដង។

គេប្រព្រឹត្តបែបនេះចំពោះគាត់ អស់រយៈពេល ១២ថ្ងៃ ១២យប់។ យោងតាមសម្ដីរបស់ **សាក្សី N** ពេលគាត់ចូលដល់បន្ទប់សួរចម្លើយ អ្នកសួរចម្លើយបានបង្ហាញគាត់ពីឧបករណ៍ធ្វើទារុណកម្មទាំងអស់ ហើយប្រាប់អោយគាត់ជ្រើសរើសឧបករណ៍ដែលនឹងត្រូវប្រើសំរាប់ធ្វើទារុណកម្មលើរូបគាត់។ បន្ទាប់មក ត្រូវបានគេវាយនឹងខ្សែតី រំពាត់ផ្ដៅ និងខ្សែភ្លើងលើខ្នងរបស់គាត់ ដោយដេកផ្កាប់មុខទៅលើដីដោយដៃទាំងពីរជាប់ខ្នោះ។ ខ្នងរបស់គាត់មានស្នាមរបួសពាសពេញ ហើយឈាមហូរពាសពេញលើកំរាលឥដ្ឋ។ បន្ថែមពីលើការវាយដំ គាត់ក៏ត្រូវគេឆក់ខ្សែភ្លើងផងដែរ។ គាត់បានប្រាប់ថា គាត់ត្រូវគេធ្វើទារុណកម្មពីរដងក្នុងមួយថ្ងៃអស់រយៈពេលពីរសប្ដាហ៍ជាប់ៗគ្នា[395]។

១០៤. នៅក្នុងករណីមួយចំនួន ការធ្វើបាបធ្ងន់ធ្ងរលើរាងកាយ ដែលបានរៀបរាប់ខាងលើនេះបានបណ្ដាលឲ្យអ្នកទោសស្លាប់[396]។ **ឌុច**បានទទួលស្គាល់ថា ពិតជាមានករណីដូចនេះកើតឡើងមែន ហើយគាត់បានពោលទៀតថា គាត់បានរៀបចំវគ្គរៀនសូត្រមួយដើម្បីដោះស្រាយស្ថានភាពនេះ[397]។ ប៉ុន្តែ **ឌុច**ក៏បានទទួលស្គាល់ដែរថា គាត់បានសរសេរសំបុត្រមួយចុះថ្ងៃទី១ ខែតុលា ឆ្នាំ១៩៧៦ ដើម្បីបញ្ជាអ្នកក្រោមបង្គាប់របស់គាត់ម្នាក់ឈ្មោះ G ឲ្យធ្វើទារុណកម្មដោយធានាថា រូបគេនឹងមិនទទួលខុសត្រូវទេ ទោះបីការធ្វើទារុណកម្មនោះបណ្ដាលឲ្យអ្នកទោសស្លាប់ក៏ដោយ[398]។

១០៥. មានភស្តុតាងដែលអាចបង្ហាញពីការរំលោភផ្លូវភេទ ដែលបានប្រព្រឹត្តនៅមន្ទីរស-២១។ ប៉ុន្តែមានការលំបាកក្នុងការកំណត់ឲ្យច្បាស់លាស់អំពីចំនួនពិតប្រាកដនៃការរំលោភផ្លូវភេទនេះ[399]។ **ឌុច**បាននិយាយថា មានករណីរំលោភតែមួយគត់ដែលបានប្រព្រឹត្តទៅលើអតីតគ្រូបង្រៀនរបស់គាត់ឈ្មោះ EE ដែលប្រព្រឹត្តដោយអ្នកសួរចម្លើយម្នាក់មកពីកងពលធំ៧០៣ ដោយបានយកឈើរុកចូលទៅក្នុងប្រដាប់ភេទរបស់នាង[400]។ ក្រោយពេលដែលការរំលោភនេះត្រូវបានរាយការណ៍ឲ្យ**ឌុច** ១បានពិគ្រោះយោបល់ពីរឿងនេះជាមួយ C ដែលជាអ្នកទទួលខុសត្រូវលើកម្លាំងមកពីកងពលធំ៧០៣។ គាត់បានអះអាងថា គាត់បានឲ្យ C ស្ដីបន្ទោសអ្នកដែលប្រព្រឹត្តអំពើនោះ។ **ឌុច**បាននិយាយថា គាត់បានរាយការណ៍អំពី

ហេតុការណ៍នោះទៅថ្នាក់លើ ប៉ុន្តែថ្នាក់លើ "*មិននិយាយអ្វីទេ*"។ ហេតុដូច្នេះ **ឌុច**មិនបានដាក់ទណ្ឌកម្មអ្នកដែលបានប្រព្រឹត្តនោះទេ ដោយគ្រាន់តែប្តូរឲ្យទៅសួរចម្លើយអ្នកផ្សេងប៉ុណ្ណោះ។ **ឌុច**ក៏បានស្នើផងដែរថា ប្រពន្ធរបស់កម្មាភិបាលត្រូវបានតែងតាំងជាអ្នកសួរចម្លើយអ្នកទោសស្រី ហើយសំណើនេះត្រូវបានយល់ព្រម[401]។ ទោះយ៉ាងណាក៏ដោយ **សាក្សី E** បាននិយាយថា នារីជាអ្នកសួរចម្លើយទាំងនេះត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ហើយយ៉ាងយូរ ចាប់ពីឆ្នាំ១៩៧៧មក អ្នកទោសស្ត្រីទាំងអស់ត្រូវសួរចម្លើយដោយបុរសវិញដដែល[402]។ ទីបំផុត **ឌុច** បានទទួលស្គាល់ថា នៅពេលនោះគាត់ "*មិនបានដាក់ទណ្ឌកម្មចំពោះបទឧក្រិដ្ឋដ៏ធ្ងន់ធ្ងរ ដែលប៉ះពាល់ដល់មនុស្ស*"[403]។

## ឃ. ព្រៃស

១០៦. **ឌុច**អះអាងថា ព្រៃសមិនមែនជាកន្លែងសម្រាប់សួរចម្លើយ ឬធ្វើទារុណកម្មអ្នកទោសនោះទេ[404]។ ទោះបីជាមានសាក្សីមួយចំនួនបានយល់ស្របចំពោះការលើកឡើងនេះក៏ដោយ[405]ក៏មានសាក្សីខ្លះទៀតបានអះអាងថា អ្នកយាមបានវាយដំ ឬជេរប្រមាថអ្នកទោសនៅពេលដែលពួកគេផ្តាក់ខ្លួនឈឺ ឬធ្វើការមិនបានល្អ[406]។ **សាក្សី O** ដែលជាអតីតអ្នកទោសនៅមន្ទីរស-២១ បានរៀបរាប់ឲ្យដឹងថា ទោះបីជាគាត់មិនធ្លាប់បានឃើញការធ្វើទារុណកម្មលើអ្នកទោសដោយផ្ទាល់ក៏ដោយ ក៏គាត់បានដឹងថា មានបន្ទប់មួយដែលគេទុកសម្រាប់ឆក់ខ្សែភ្លើងអ្នកទោសប្រុសស្រី ក្នុងពេលសួរចម្លើយ[407]។ សាក្សីម្នាក់ទៀតឈ្មោះ **សាក្សី P** បានពណ៌នាអំពីស្ថានភាពរបស់មិត្តរបស់គាត់ ដែលត្រលប់មកពីព្រៃសវិញ ត្រូវគេកោរសក់ក្បាលអស់ ហើយស្បែកមានដំបៅរលួយ ដោយសារការឆក់ខ្សែភ្លើង ការវាយដំ និងការវាយដោយរំពាត់នៅពេលសួរចម្លើយ[408]។

## ៣. ការសម្លាប់

## ក.អំណាចក្នុងការបញ្ជាសម្លាប់

១០៧. អ្នកទោសជាង ១២ ៣៨០នាក់ ត្រូវបានគេសម្លាប់នៅមន្ទីរស-២១[409]។ **ឌុច**បាននិយាយថា ពីដំបូងគាត់បានផ្ទេរការទទួលខុសត្រូវលើការសម្លាប់ឱ្យទៅ C ហើយចាប់ពីពេលនោះមកគឺ ហ៊ីជាអ្នកចាត់វិធានការចាំបាច់នានាដោយខ្លួនឯងផ្ទាល់[410]។ ប៉ុន្តែបន្ទាប់ពីមានហេតុការណ៍ មួយ ដែលមានអ្នកទោសម្នាក់ស្លាប់មុនបញ្ចប់ការសួរចម្លើយ សុន សេនបានតម្រូវឱ្យឌុច សម្រេចលើរាល់ការសម្លាប់[411]។ ហេតុដូច្នេះ ចាប់តាំងពីពេលនោះមក គឺ**ឌុច** ជាអ្នក សម្រេចអំពីអាយុជីវិតរបស់អ្នកទោសម្នាក់ៗ ពីព្រោះថា **ឌុច**ជាអ្នកបញ្ជាឱ្យសម្លាប់ បន្ទាប់ ពីគាត់យល់ថាចម្លើយសារភាពមានលក្ខណៈគ្រប់គ្រាន់ហើយ[412]។ មិនមានអ្នកទោស ណាម្នាក់ អាចត្រូវបានគេដោះលែងនោះទេ[413] ហើយការបញ្ជាដោយប្រយោលរបស់ឌុច ក្នុងឋានៈជាប្រធាន គឺត្រូវសម្លាប់អ្នកទោស ស្របតាមប្រព័ន្ធដែលបានបង្កើតឡើងនៅមន្ទីរ ស-២១។

១០៨. **សាក្សី** Q បានបញ្ជាក់ថា គ្មានអ្នកទោសណាម្នាក់អាចត្រូវបានបញ្ជូនចេញពីមន្ទីរស-២១ ដោយគ្មានការអនុញ្ញាតពី **ឌុច** នោះទេ។ គាត់ក៏បានបន្ថែមថា **ឌុច**រៀបចំ និងបញ្ជាឱ្យមាន ការសម្លាប់អ្នកទោស ដោយចារពាក្យថា "កំ" ជាអក្សរកាត់របស់ពាក្យ"*កម្ទេច*" ដែលមាន ន័យថា "សម្លាប់" លើឈ្មោះរបស់អ្នកទោស ដែលត្រូវ "បញ្ជូនចេញ" [414]។

១០៩. **សាក្សី** B បានអះអាងថា **ឌុច** និង C ជាអ្នកបញ្ជាឱ្យសម្លាប់អ្នកទោសនៅក្នុង បរិវេណ មន្ទីរស-២១[415]។ គាត់បានរៀបរាប់ថា **ឌុច**បានបញ្ជាដោយផ្ទាល់ឱ្យគាត់សម្លាប់មនុស្ស ម្នាក់នៅជើងឯក ហើយក៏គាត់បានយកដែកស្ពៀរទេះទៅវាយសម្លាប់អ្នកទោសម្នាក់នោះ ខណៈពេលដែល**ឌុច**នៅឈរមើល[416]។ **ឌុច** អះអាងថា មិនដែលមានរឿងបែបនេះបានកើត ឡើងឡើយ[417]។

១១០. **ឌុច**បានអះអាងថា ការសម្លាប់អ្នកទោសអាចធ្វើឡើងតាមការណែនាំពីថ្នាក់លើ ហើយគាត់ បញ្ជូនទៅឱ្យអ្នកក្រោមបង្គាប់ជាអ្នកអនុវត្ត[418] ឬផ្អែកតាមការសម្រេចចិត្តដោយឯកឯង របស់គាត់ បន្ទាប់ពីបានពិចារណាលើកត្តាជាច្រើន ដូចជា៖ ចំនួនអ្នកទោសច្រើនពេក កង្វះ ចំណីអាហារ ការភ័យខ្លាចជម្ងឺឆ្លង ឬការភ័យខ្លាចការរត់គេចខ្លួន[419]។ ក្រៅពីការចេញបញ្ជា

ឲ្យសម្លាប់អ្នកទោស **ឌុច** ក៏បានបង្រៀនផងដែរ អំពីវិធីសម្លាប់។ **សាក្សី** B បានរំលឹកឡើងវិញជាពិសេសអំពីការប្រជុំមួយ ដែលក្នុងពេលនោះ **ឌុច**បានផ្តល់ការណែនាំថា៖ *"វាយក នឹងដែកមិនងាប់ទេ ទាល់តែអារ ក ទៀត"*[420]។

១១១. ជាទូទៅ អ្នកទោសត្រូវបានគេសម្លាប់ ក្នុងរយៈពេលមួយដ៏ខ្លី ក្រោយពីពួកគេបានឆ្លើយសារភាពរួច។ ប៉ុន្តែ **ឌុច**បានទទួលស្គាល់ថា គាត់មានអំណាចក្នុងការពន្យាពេល ការសម្លាប់អ្នកទោសមួយចំនួន ដែលមានជំនាញ ។ គាត់បានពិពណ៌នាអំពីអំណាចនោះថាជា "*ការអត់ឱនដែលធ្វើឡើងដោយថ្នាក់លើ*" ដែលតាមរយៈនេះ C និង គាត់ អាចទុកជីវិតឲ្យអ្នកទោសមួយចំនួនដើម្បីឲ្យពួកគេបន្តធ្វើការនៅក្នុងមន្ទីរស-២១។ ទោះជាយ៉ាងនេះក្តី គាត់បានបន្ថែមថា ពួកគេក៏នឹងត្រូវបានសម្លាប់ តាមក្រោយដដែល ដោយជៀសមិនផុត[421]។

**ខ- ការសម្លាប់នៅជើងឯក**

១១២. ដោយគិតអំពីស្ថានភាពនៅកម្ពុជាបន្ទាប់ពីការដួលរលំភ្លាមៗនៃរបបខ្មែរក្រហម និងដោយគិតពីពេលវេលាដែលកន្លងផុតទៅ គេមានការលំបាកណាស់ក្នុងការកំណត់ចំនួនមនុស្សដែលត្រូវបានសម្លាប់នៅជើងឯក។ ប៉ុន្តែតាមរយៈសក្ខីកម្មអំពីប្រព័ន្ធនៃការសម្លាប់នៅស២១ បញ្ជីអ្នកទោស និងបញ្ជីអ្នកដែលត្រូវសម្លាប់ និងការសិក្សាផ្នែកឧក្រិដ្ឋវិទ្យា បង្ហាញថាមានមនុស្សរាប់ពាន់នាក់រួមមាន បុរស ស្ត្រី និងកុមារត្រូវបានសម្លាប់ និងកប់ នៅជើងឯក[422]។ ទោះបីជាមានសាក្សីមួយចំនួនបានបដិសេធថាមិនធ្លាប់បានឃើញមានកុមារនៅជើងឯកក៏ដោយ[423] ប៉ុន្តែយ៉ាងហោចណាស់ ក៏គេឃើញមានរណ្តៅកប់សាកសពមួយដែលមានឆ្អឹងរបស់កុមារនៅសេសសល់ដែរ[424]។ បញ្ជីឈ្មោះអ្នកដែលត្រូវសម្លាប់ ដែលរកឃើញនៅមន្ទីរស-២១ បានបង្ហាញថា ក្នុងខែកក្កដា ឆ្នាំ១៩៧៧ កុមារចំនួន១៦០នាក់ត្រូវបានគេសម្លាប់នៅជើងឯកក្នុងរយៈពេលតែមួយថ្ងៃ[425]។ ក្នុងអំឡុងពេលនៃការសម្តែងឡើងវិញ ដែលបានធ្វើឡើងនៅជើងឯក កាលពីថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៨ **ឌុច**បាន

និយាយថា គាត់មិនបានដឹងអំពីវិធីដែលគេសម្លាប់កុមារនៅទីនោះទេ ប៉ុន្តែគាត់មិនបានបដិសេធអំពីការដែលកុមារត្រូវបានគេសម្លាប់នៅកន្លែងនោះឡើយ[426]។

១១៣. **សាក្សី** B បានបញ្ជាក់ថា គាត់ពិតជាបានឃើញ**ឌុច**នៅជើងឯក[427]។ **ឌុច**បានទទួលស្គាល់ថា គាត់បានទៅជើងឯកមែន តែទៅតែម្តងគត់[428] នាឆ្នាំ១៩៧៧[429] តាមការបញ្ជារបស់ សុន សេន ដោយបានបញ្ជាក់ថា គាត់នៅទីនោះតែ១០ ទៅ១៥នាទី តែប៉ុណ្ណោះ[430]។

១១៤. អ្នកទោសត្រូវបានដឹកតាមឡាន ទៅជើងឯក[431] ពីរ ឬបីដងក្នុងមួយខែ[432]។ **សាក្សី** B បាននិយាយថា ពួកអ្នកទោសត្រូវបានដឹកតាមឡានពីរ ដែលក្នុងឡាននីមួយៗ មានអ្នកទោសពី ៣០ ទៅ៤០នាក់។ គាត់បានបញ្ជាក់ថា ដើម្បីកុំឱ្យអ្នកទោស ស្រែកពេលដឹកចេញ អ្នកទោសទាំងនោះត្រូវបានគេប្រាប់ថា ប្តូរផ្ទះថ្មី[433]។ បន្ទាប់មកទៀត ពួកគេត្រូវបានគេដាក់ខ្នោះដៃ ចងមុខ និងបណ្តើរឆ្ពោះទៅរកឡាន[434]។ នៅក្នុងពេលកំពុងធ្វើដំណើរ មានអ្នកយាមពីរនាក់នៅផ្នែកខាងក្រោយនៃរថយន្ត ដើម្បីការពារកុំឱ្យអ្នកទោសលោតចេញពីរថយន្តបាន[435]។

១១៥. យោងតាមសម្តីរបស់**ឌុច** មានអ្នកយាមពីបីទៅបួននាក់ប្រចាំនៅជើងឯក។ នៅក្នុងពេលសម្លាប់ អាចមានវត្តមានអ្នកយាមរហូតដល់ដប់នាក់ ព្រោះចំនួននេះរួមបញ្ចូលទាំងចំនួន នៃអ្នកយាម ដែលដឹកអ្នកទោសមក[436]។ មានក្រុមចំនួនបី គឺ៖ កងពិសេស, ក្រុម FF និងក្រុម GG[437]។ **ឌុច**បាននិយាយថា អ្នកទោសត្រូវបានសម្លាប់ដោយប្រើវិធី ដូចគ្នាទៅនឹងវិធី ដែលធ្លាប់បានប្រើតាំងតែពីសម័យ ដែលគាត់នៅជាលេខាមន្ទីរម១៣ មកម្ល៉េះ។ ផ្ទុយទៅវិញ **ឌុច** បានបញ្ជាក់ថា គាត់គ្រាន់តែដឹងថា អ្នកទោសត្រូវបានចងបិទមុខ និងចងដៃទៅក្រោយតែប៉ុណ្ណោះ[438] ហើយគាត់មិនបានដឹងអំពី "*បច្ចេកទេសលម្អិត*" នៃការសម្លាប់ឡើយ[439]។

១១៦. នៅពេលរថយន្តមកដល់ជើងឯក[440] គេបានបញ្ឆេះម៉ាស៊ីនភ្លើង[441] ហើយអ្នកទោសត្រូវបានគេបណ្តើរឱ្យចូលទៅក្នុងផ្ទះឈើមួយ[442]។ បន្ទាប់មកទៀត អ្នកយាមបាននាំអ្នកទោសចេញក្រៅម្តងមួយៗ ដោយនិយាយទៅកាន់ពួកគេថា នាំទៅផ្ទះ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ផ្សេងមួយទៀត។ I ឈរនៅខាងក្រៅ និងកត់ឈ្មោះអ្នកទោសទៅក្នុងបញ្ជី មុនពេលដែលពួកគេត្រូវបានបណ្ដើរឆ្ពោះទៅរណ្ដៅដើម្បីសម្លាប់[443]។

១១៧. សាក្សីជាច្រើនបាននិយាយថា អ្នកទោសត្រូវគេសម្លាប់ដោយប្រើដំបងដែក ដែកស្ពៃរទេះ និងបំពង់ទីប ដោយវាយត្រង់កញ្ចឹងក[444]។ បន្ទាប់មកទៀត អ្នកទោសត្រូវគេធាក់ទម្លាក់ទៅក្នុងរណ្ដៅ បន្ទាប់ពីត្រូវបានដោះខ្នោះដៃចេញ[445] និងវះពោះ ឬអារក[446]។ ក្រោយពីការប្រហារជីវិតបានបញ្ចប់ អ្នកយាមបានកាយដីដើម្បីកប់រណ្ដៅ[447]។

១១៨. ការសម្លាប់ក្នុងទ្រង់ទ្រាយធំជាច្រើន ទំនងជាបានកើតឡើងផងដែរនៅជើងឯក។ **ឌុច** បាននិយាយថា **សុន សេន** និង J បានបញ្ជាគាត់ឱ្យបញ្ជូនអ្នកទោសដ៏ច្រើន ដែលជាប់ឃុំនៅមន្ទីរស-២១ទៅជើងឯកដើម្បីសម្លាប់ក្នុងពេលបួនដងខុសៗគ្នា[448]។ ការសម្លាប់ដ៏ច្រើនបែបនេះត្រូវបានសម្រេចឡើង ដោយយោងទៅលើភាពចាំបាច់នៃតម្រូវការទីកន្លែង សម្រាប់ដាក់អ្នកទោសថ្មីៗជាច្រើន ដែលទើបចាប់ខ្លួនបាន[449]។ **ឌុច**បានទទួលស្គាល់ថា បានបញ្ជា និងបានរៀបចំការសម្លាប់ជាឈុតចំនួនពីរដង[450]។ តាមសម្ដីរបស់គាត់ ការសម្លាប់ក្នុងទ្រង់ទ្រាយធំជាច្រើនបានកើតឡើងតាមបញ្ជា ដែលគាត់បានទទួល និងបានបញ្ជូនបន្តទៅឱ្យអ្នកក្រោមបង្គាប់របស់គាត់ធ្វើ ដោយគ្មានការសួរចម្លើយជាមុននោះឡើយ។ **ឌុច**បានបញ្ជាក់ថា មានចំណារផ្ទាល់ដៃរបស់គាត់នៅលើបញ្ជីអ្នកទោសមួយចំនួន។ នៅលើបញ្ជីរមួយនោះ គាត់បានធ្វើចំណារថា "*ពូ* FF *វាយចោលឱ្យ ម៉ត់-ថ្ងៃទី៣០ ខែឧសភា ឆ្នាំ១៩៧៨*"។ **ឌុច**បានពន្យល់ថា នេះជាករណីនៃការសម្លាប់ជាទ្រង់ទ្រាយធំ ដែលធ្វើឡើងក្នុងលក្ខណៈពិសេសមួយ ប៉ុន្តែគាត់មិនបានចាំអំពីចំនួននៃជនរងគ្រោះនោះទេ។ នៅលើបញ្ជីមួយផ្សេងទៀត ដែលមានឈ្មោះអ្នកទោសចំនួន២៩នាក់ គាត់បានចារថា "*ស្មើសួរបួននាក់ ក្រៅពីនេះ វាយចោល*"[451]។

១១៩. **ឌុច**បាននិយាយថា ក្រោយមកទៀតនៅក្នុងខែធ្នូ ឆ្នាំ១៩៧៨ អ្នកទោសប្រហែលជា ៣០០នាក់ មកពីភូមិភាគបូព៌ា ដែលត្រូវគេចោទថា បានបះបោរប្រឆាំង ត្រូវបានគេបញ្ជូនទៅជើងឯក


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១
ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

ហើយត្រូវបានសម្លាប់តែម្តង[452]។ គាត់ក៏បានបន្ថែមថា នៅថ្ងៃទី២ ឬទី៣ ខែមករា ឆ្នាំ ១៩៧៩ J បានបញ្ជាគាត់ឱ្យកម្ទេចអ្នកទោសទាំងអស់នៅមន្ទីរស-២១[453]។ ដូច្នេះ មនុស្ស ប្រហែលជា២០០នាក់ត្រូវបានគេបញ្ជូនទៅជើងឯក ហើយសម្លាប់ចោល[454]។ តាមសម្តី របស់ឌុច បន្ទាប់ពីព្រឹត្តិការណ៍នោះមក គ្មានការសម្លាប់ជាទ្រង់ទ្រាយធំណាមួយទៀត ដែល ត្រូវបានធ្វើឡើងនោះទេ[455]។ **សាក្សី** L គឺជាសាក្សីដែលបានឃើញការសម្លាប់ទ្រង់ទ្រាយ ធំចុងក្រោយនេះដោយផ្ទាល់ភ្នែក[456] ហើយបុគ្គលិកដ៏ទៃទៀតរបស់មន្ទីរស-២១ ក៏បាន ដឹងអំពីព្រឹត្តិការណ៍នេះផងដែរ[457]។ ឌុចបានទទួលស្គាល់ថា មានមនុស្សពីរប្រភេទ ដែលជា ជនរងគ្រោះនៃការសម្លាប់ជាទ្រង់ទ្រាយធំលើកចុងក្រោយនេះ គឺ៖ ជនជាតិកម្ពុជា និង ទាហានវៀតណាម[458]។

## គ.ការសម្លាប់នៅទួលស្លែង

១២០. ឌុច និងសាក្សីផ្សេងៗទៀត បានប្រាប់ឱ្យដឹងថា ទោះបីជាជើងឯកបានក្លាយទៅជាទីកន្លែង ពិឃាតដ៏សំខាន់ក៏ដោយ ក៏ការសម្លាប់អ្នកទោសសំខាន់ៗ មួយចំនួនដូចជា៖ K A T និង B ព្រមទាំងជនបរទេស នៅតែបន្ត ក្នុងបរិវេណខាងក្នុងទួលស្លែង ឬនៅជិតនោះដដែល[459]។ ភស្តុតាងដែលមាននៅក្នុងសំណុំរឿងក៏បានបង្ហាញថា មានរណ្តៅកប់សាកសពជាច្រើននៅក្នុង និងនៅជុំវិញទួលស្លែង[460]។

១២១. តាមការណែនាំរបស់ថ្នាក់លើ ឌុច បានឱ្យគេថតរូបសាកសពអ្នកទោសសំខាន់ៗបន្ទាប់ពីការ សម្លាប់[461]។ រូបថតទាំងនេះត្រូវបានយកធ្វើជាភស្តុតាងដើម្បីបញ្ជាក់បានថា អ្នកទោស ទាំងនេះមិនត្រូវបានដោះលែង ឬបានរត់គេចខ្លួន។ ឌុចបាននិយាយថា គាត់ចាំច្បាស់ណាស់ថា បានថតរូបសាកសពអ្នកទោស បីរូប គឺ៖ Y A និង T[462]។

១២២. នៅក្នុងឆ្នាំ១៩៧៨ ជនបរទេសបួននាក់ត្រូវបានគេដុតទាំងរស់ជាមួយនឹងសំបកកង់ឡាន[463] នៅចន្លោះមហាវិថីម៉ៅសេទុង និងសង្កាត់បឹងទំពុន[464]។ J ទំនងជាបានបញ្ជា ឌុច ឱ្យធ្វើ


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

យ៉ាងណា កុំឲ្យគេរកឃើញសាកសពជនទាំងនោះ[465]។ **សាក្សី** E ត្រូវបានគេប្រាប់អំពីហេតុការណ៍នេះ ប៉ុន្តែមិនបានឃើញផ្ទាល់ភ្នែកនោះទេ[466]។ **សាក្សី** R ដែលជាអតីតអ្នកយាមនៅមន្ទីរស-២១ បាននិយាយថា នៅក្នុងឆ្នាំ១៩៧៧ ឬ១៩៧៨ គាត់បានឃើញ អ្នកទោសបរទេសម្នាក់ត្រូវបានគេដុតទាំងរស់ ដោយប្រើសំបកកង់ឡានពាក់នៅជុំវិញក នៅលើផ្លូវបំបែកវត្តទួលទំពូង[467]។

១២៣. អ្នកទោសមួយចំនួនដែលជាប់ឃុំនៅមន្ទីរស-២១ បានស្លាប់ បន្ទាប់ពីគ្រូពេទ្យ បានបូមយកឈាមក្នុងចំនួនដ៏ច្រើន[468]។ **សាក្សី** E បានអះអាងប្រាប់អ្នកស៊ើបអង្កេតថា *"មានមនុស្សមិនតិចជាងមួយពាន់នាក់ទេ"* ដែលត្រូវបានសម្លាប់ដោយវិធីនេះ ដោយគូសបញ្ជាក់ថា គេបូមឈាមអ្នកទោស ពី២០ ទៅ៣០នាក់ នៅរៀងរាល់បួន-ប្រាំថ្ងៃម្តង[469]។ **សាក្សី** Q បានប្រាប់ឲ្យដឹងថា C បានបញ្ជាគាត់ឲ្យធ្វើបញ្ជីឈ្មោះអ្នកទោសទាំងឡាយ ដែលត្រូវបានសម្លាប់តាមវិធីនេះចំនួនពីរលើក។ លើកទីមួយ គាត់បានស្រង់បានចំនួនពីរនាក់ និងលើកទីពីរ បានបួន ឬប្រាំនាក់[470]។ នៅក្នុងសំណុំរឿង មានបញ្ជីឈ្មោះអ្នកទោសដែលត្រូវបានសម្លាប់តាមវិធីនេះ[471]។ អតីតគ្រូពេទ្យនៅមន្ទីរ ស-២១ **សាក្សី** S បានអះអាងថាមានពេលមួយនោះគាត់បានប្រទះឃើញឈាម ពី៣០ ទៅ៤០ប្លោក[472]។

១២៤. **សាក្សី** E បានរៀបរាប់បញ្ជាក់ថា គេបូមឈាមពីអ្នកទោសម្នាក់ៗ ពីបួន ទៅប្រាំប្លោក *ដែល "បន្ទាប់ពីបូមរួច ធ្វើឲ្យអ្នកទោសលែងដឹងខ្លួន និងនៅសល់ដង្ហើមផ្ញឹកៗ"*។ គាត់បានបន្ថែមថា "*ពេលនោះ ខ្ញុំឃើញអញ្ចឹង ខ្ញុំមានការរន្ធត់ជាខ្លាំង ចំពោះរូបខ្ញុំ ពេលធ្វើទារុណកម្ម ខ្ញុំមិនសូវរន្ធត់ទេ តែការដែលបូមឈាមហ្នឹង គឺខ្ញុំរន្ធត់ពេក ខ្ញុំនៅចងចាំរហូតអត់ភ្លេចទេ អារឿងបញ្ហាហ្នឹង*"។ បន្តិចក្រោយមក អ្នកទោសតែងតែស្លាប់ ហើយទើបមានឡានចូលមកដឹកយកសាកសពទៅជើងឯក[473]។

១២៥. ភស្តុតាងបានបង្ហាញថា ឈាមដែលគេបូមបានពីអ្នកទោស ត្រូវបានគេបញ្ជូនទៅតាមបណ្តាមន្ទីរពេទ្យនានា[474]។ **សាក្សី** E បានពន្យល់ប្រាប់អ្នកស៊ើបអង្កេតថា គ្រូពេទ្យនៅមន្ទីរនោះបានបង្ហើបប្រាប់គាត់ថា៖ *"ឈាមហ្នឹងយកទៅពេទ្យ ១៧ មេសា និងពេទ្យមុនីវង្ស"*[475]។ **សាក្សី** I

បានដឹងពី "គ្រូពេទ្យ" ផ្សេងទៀតថា៖ "មានការបូម*ឈាមពីអ្នកទោស ទៅឱ្យពេទ្យខាងក្រោស-២១*"[476]។ **សាក្សី T** ដែលអតីតអ្នកយាមនៅមន្ទីរស-២១ ត្រូវបានគេប្រាប់ថា "*មានកន្លែងចិញ្ចឹមឈាមនៅកន្លែងមួយ ហៅថាស្រះស្រង់ នៅខាងកើតគុកទួលស្លែង*"[477]។

១២៦. **ឌុច**បានបដិសេធថា គាត់មិនបានដើរតួនាទីណាមួយក្នុងសកម្មភាពនៃការបូមឈាមពីអ្នកទោសនោះទេ។ តែទោះជាយ៉ាងណាក៏ដោយ គាត់ក៏ "*មិនប៉ានបដិសេធ*" ថា មិនមានការបូមឈាមពីអ្នកទោសនៅមន្ទីរស-២១ នោះឡើយ។ គាត់បាននិយាយថា ប្រសិនបើពិតជាមានការបូមឈាមនៅមន្ទីរ ស-២១មែន គឺ"*មានតំណាតាំងតែពីពេលដែល* B *នៅជាប្រធានមកម្ល៉េះ*"[478]។ ក្នុងអំឡុងពេលនៃការសួរយកចម្លើយក្រោយៗមកទៀត ឌុច នៅតែមិនបដិសេធថាអ្នកទោសនៅមន្ទីរស-២១មិនត្រូវបានគេបូមឈាមឡើយ ប៉ុន្តែនៅតែរក្សាជំហរថា មិនធ្លាប់បានដឹងអំពីទង្វើនេះទេ[479]។

១២៧. អតីតបុគ្គលិកមន្ទីរស-២១ខ្លះ បានអះអាងផងដែរថា ក្មេងៗត្រូវបានគេសម្លាប់នៅក្នុងបរិវេណនៃមន្ទីរនេះ។ សក្ខីកម្មផ្សេងៗបានបង្ហាញថា កូនៗរបស់អ្នកទោស ត្រូវបានគេបំបែកចេញពីឪពុកម្តាយ សម្លាប់ និងកប់នៅទីតាំងខាងជើងគុក[480]។ វិធីនៃការសម្លាប់មួយ ដែលទំនងជាត្រូវបានគេប្រើ ដើម្បីសម្លាប់កុមារទាំងនោះ គឺការបោះទម្លាក់ពួកគេមកពីជាន់ទីបីនៃអគារ ដើម្បីបំបាក់កតែម្តង[481]។

១២៨. យុទ្ធជនបួននាក់ ដែលមកពីកងយោធាមួយដែល ឌុចចាំបានថាមានឈ្មោះ យ៨ ក៏ត្រូវបានគេសម្លាប់ក្រោយពីការសម្លាប់ជាទ្រង់ទ្រាយធំចុងក្រោយ ដែលធ្វើឡើងកាលពីថ្ងៃទី២ ឬទី៣ ខែមករា ឆ្នាំ១៩៧៩ ដែរ។ ឌុច បានធ្វើការបញ្ជាក់ថា យុទ្ធជនទាំងនេះ ត្រូវបានសម្លាប់ ដោយអ្នកសួរចម្លើយម្នាក់ ឈ្មោះ HH ដោយប្រើចំពុះទង់ កាលពីថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ គឺសាកសពរបស់ពួកគេនេះហើយដែលនៅសល់លើគ្រែ[482]មិនមានអ្នកណាយកទៅកប់ និងដែលពួកទាហានវៀតណាមបានប្រទះឃើញ នៅពេលដែលពួកគេមកដល់មន្ទីរស-២១[483]។

## ផ្នែកទី២. ការកំណត់ប្រភេទបទល្មើស

១២៩. ការស៊ើបសួរបានបង្ហាញថា ទោះជា**ឌុច**មិនមែនជាមេដឹកនាំជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យ ក៏គាត់អាចត្រូវបានចាត់ទុកថាចូលក្នុងប្រភេទនៃអ្នកទទួលខុសត្រូវខ្ពស់បំផុតនៃឧក្រិដ្ឋកម្ម និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរនានា ដែលបានប្រព្រឹត្តក្នុងចន្លោះថ្ងៃទី ១៧ ខែមេសា ឆ្នាំ ១៩៧៥ ដល់ ថ្ងៃទី ០៦ ខែមករា ឆ្នាំ ១៩៧៩ ដោយផ្អែកលើអំណាចឋានានុក្រមជាផ្លូវការ និងប្រកបដោយប្រសិទ្ធភាពរបស់ខ្លួន ក្នុងឋានៈជាអនុលេខា បន្ទាប់មកជាលេខា ក៏ដូចជាតាមរយៈការចូលរួមរបស់គាត់ដោយផ្ទាល់នៅក្នុងឧក្រិដ្ឋកម្ម ដែលបានប្រព្រឹត្តនៅមន្ទីរ ស-២១ ដែលជាមន្ទីរសន្តិសុខគ្រប់គ្រងផ្ទាល់ដោយគណៈកម្មាធិការមជ្ឈិមបក្សនៃបក្សកុម្មុយនីស្តកម្ពុជា។

***

១៣០. ដោយផ្អែកលើអង្គហេតុដែលបានរៀបរាប់ខាងលើ មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ក្នុងការបញ្ជូន **កាំង ហ្គេកអ៊ាវ** ហៅ**ឌុច** ទៅអង្គជំនុំជម្រះចំពោះបទល្មើសដែលមានចែងនៅក្នុងច្បាប់ អ.វ.ត.ក និងច្បាប់ពាក់ព័ន្ធដែលមានជាធរមាន ក្នុងឆ្នាំ១៩៧៥ ៖

### ក. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ

#### ធាតុផ្សំទូទៅ

១៣១. មន្ទីរ ស-២១ ត្រូវបានបង្កើត និងផ្តល់នូវអំណាចយ៉ាងពិសេសដើម្បីឃុំឃាំង អប់រំកែប្រែ ឬ កម្ទេចចោលអ្នកប្រឆាំងនយោបាយពិតប្រាកដ ឬអ្នកដែលត្រូវបានសន្មត់ថា ជាអ្នកប្រឆាំងនឹងអ្នកកាន់អំណាចរបស់បក្សកុម្មុយនីស្តកម្ពុជា ដែលបានដឹកនាំប្រទេស ក្នុងអំឡុងពេលនៃអង្គហេតុទាំងនោះ។ ឧក្រិដ្ឋកម្មជាច្រើនដែលត្រូវបានប្រព្រឹត្តជាបន្តបន្ទាប់នៅមន្ទីរ ស-២១ បានបញ្ជាក់ថា ការវាយប្រហារមានលក្ខណៈជាហូហែ និងរាលដាលលើអ្នកប្រឆាំងទាំងនោះ ដែលនិយមន័យនៃពាក្យអ្នកប្រឆាំងបានវិវត្តន៍ជាប្រចាំ អាស្រ័យលើអ្វីដែលបក្សចាត់ទុកថាជាការគម្រាមកំហែង។ មន្ទីរស-២១ បានដំណើរការជាអង្គភាពយោធា និងនយោបាយដែលមានបេសកកម្មពីរគឺ៖ រាយការណ៍ដោយផ្ទាល់ ទៅថ្នាក់លើបំផុតរបស់បក្ស និងឃុំឃាំងអ្នកទោសដែលភាគច្រើនជាជនស៊ីវិល ស្របតាមន័យកំណត់ក្នុងច្បាប់អន្តរជាតិ។ អ្នកទោសទាំងនោះមកពីគ្រប់ភូមិភាគនីមួយៗ អង្គភាពរដ្ឋបាល និងអង្គភាពយោធាផ្សេងៗទូទាំងប្រទេសកម្ពុជា។ តាមរយៈតួនាទីដែលបានអនុវត្តនៅមន្ទីរស-២១ **ឌុច**បានដឹងអំពីគោលបំណងនៃមន្ទីរនេះ ហើយតាមរយៈសកម្មភាពរបស់ខ្លួន **ឌុច**បានចូលរួមដោយស្ម័គ្រចិត្តក្នុងការសម្រេចគោលបំណងទាំងនោះ។ បើទោះបីជាមានការទាមទារឲ្យបង្ហាញថា ឧក្រិដ្ឋកម្មប្រព្រឹត្តនៅមន្ទីរ ស-២១ ជាឧក្រិដ្ឋកម្មមានទំនាក់ទំនងជាមួយនឹងជម្លោះប្រដាប់អាវុធអន្តរជាតិ ក៏គេអាចមើលឃើញយ៉ាងច្បាស់ថា អំពើដែលរួមចំណែកនៅក្នុងការវាយប្រហារខាងលើត្រូវបានប្រព្រឹត្តជាច្រើនដង ខណៈពេលដែលជម្លោះជាមួយប្រទេសវៀតណាមកាន់តែតានតឹងឡើង។

១៣២. ក្រៅពីការវាយប្រហារដែលអាចត្រូវបានរកឃើញថា ប្រឆាំងនឹងប្រជាពលរដ្ឋទាំងមូលនៅកម្ពុជា ឧក្រិដ្ឋកម្មដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១បង្កើតបានជាការវាយប្រហារមួយដាច់ដោយឡែក ដែលមានលក្ខណៈទូទៅ និងជាប្រព័ន្ធប្រឆាំងនឹងជនស៊ីវិល ដែលត្រូវឃុំខ្លួននៅក្នុងមន្ទីរនេះ។

១៣៣. ដូច្នេះ អំពើឧក្រិដ្ឋកម្មខាងក្រោម ដែលមានចែងក្នុងមាត្រា៥ នៃច្បាប់អ.វ.ត.កនឹងត្រូវបានកំណត់ចូលក្នុងប្រភេទបទល្មើសខាងក្រោមទាក់ទងនឹងមន្ទីរស-២១ ដែលបានប្រព្រឹត្តនៅក្នុង

ក្របខណ្ឌនៃការវាយប្រហារទូទៅ ឬជាប្រព័ន្ធនៅមន្ទីរស-២១ ក្នុងចេតនាប្រឆាំងនឹងជនស៊ីវិល ដោយមូលហេតុនយោបាយ និងបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ស្របតាមនិយមន័យក្រោមច្បាប់ទំនៀមទម្លាប់អន្តរជាតិ ដែលនៅជាធរមានក្នុងឆ្នាំ១៩៧៥។

## ការដាក់ពន្ធនាគារ

១៣៤. បុគ្គលជាច្រើនត្រូវបានឃុំឃាំងដោយចេតនានៅមន្ទីរស-២១។ ការចាប់ខ្លួនពួកគេពុំមានមូលហេតុត្រឹមត្រូវ និងមូលដ្ឋានច្បាប់ទេ។ បន្ថែមលើនេះទៀត អ្នកទោសទាំងនោះត្រូវបានដកហូតនូវសិទ្ធិជាមូលដ្ឋាន ដូចជាសិទ្ធិទទួលបានការជូនដំណឹងអំពីមូលហេតុនៃការចាប់ខ្លួនពួកគេ។ គ្មានភស្តុតាងណាមួយដែលបានបង្ហាញថា មានប្រព័ន្ធច្បាប់ ឬតុលាការនៅកម្ពុជាក្នុងចន្លោះថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ និងថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ឡើយ។ គ្មានការធានាផ្នែកនីតិវិធីណាមួយ ទោះជានីតិវិធីរដ្ឋបាល ឬនីតិវិធីតុលាការ ដែលតាមរយៈនេះ អ្នកទោសទាំងនោះអាចតទល់ប្រឆាំង នឹងការឃុំឃាំងខ្លួនរបស់ពួកគេឡើយ។

## ការធ្វើឱ្យទៅជាទាសករ

១៣៥. អ្នកទោសមួយចំនួននៅមន្ទីរស-២១ និងព្រៃសត្រូវគេបង្ខំឱ្យធ្វើការ។ គ្រប់ទិដ្ឋភាពនៃការរស់នៅរបស់ពួកគេត្រូវបានឃាមកាមយ៉ាងតឹងរឹង និងត្រូវបានចាត់ទុកជាវត្ថុផ្តាច់មុខដែលត្រូវបានបង្ហាញ តាមរយៈការកម្រិតការដើរហើរ និងកន្លែងរស់នៅ ការចាត់វិធានការទប់ស្កាត់ ឬធ្វើឱ្យពួកគេញញើតនឹងការរត់គេច និងតាមរយៈការអនុវត្តដែលនាំឱ្យពួកគេប្រឈមនឹងអំពើឃោរឃៅ។ ជាលទ្ធផលនៃអំពើទាំងនេះ អ្នកទោសត្រូវបានដកហូតនូវសេរីភាពរបស់ពួកគេ។

## ទារុណកម្ម

១៣៦. អ្នកទោសនៅមន្ទីរស-២១ភាគច្រើនដែលត្រូវបានសួរចម្លើយទទួលរងការសួរចម្លើយតាម

របៀបឃោរឃៅ ដែលត្រូវបានប្រព្រឹត្តដោយចេតនា និងជាច្រើនលើកច្រើនសា ហើយជាញឹកញាប់ វិធីទាំងនេះបណ្តាលឲ្យមានរបួសដល់រូបរាងកាយ និងផ្លូវចិត្តធ្ងន់ធ្ងរ។ វិធីនេះត្រូវបានរៀបចំឡើងក្នុងគោលបំណងជាក់លាក់ ដើម្បីប្រមូលយកព័ត៌មាន ឬចម្លើយសារភាពពីអ្នកទោស។ ប្រសិនបើមានការទាមទារឲ្យបង្ហាញថា ចារីនៃឧក្រិដ្ឋកម្មទាំងនោះបានប្រព្រឹត្តនៅក្នុងការអនុវត្តតួនាទីផ្លូវការរបស់ខ្លួន ក៏មានភស្តុតាងបង្ហាញថា ពួកគេបានប្រព្រឹត្តអំពើទាំងនោះក្នុងតួនាទីផ្លូវការ ដូចបានកំណត់ក្នុងរចនាសម្ព័ន្ធបញ្ជាដ៏ច្បាស់លាស់មួយ។

## ការរំលោភផ្លូវភេទ

១៣៧. ភស្តុតាងដែលមាននៅក្នុងសំណុំរឿងបានបង្ហាញថាយ៉ាងហោចណាស់ មានករណីមួយនៃការស៊កបញ្ចូលក្នុងប្រដាប់ភេទដោយបង្ខំ ដែលត្រូវបានប្រព្រឹត្តនៅមន្ទីរស-២១ នោះគឺករណីដែលអ្នកសួរចម្លើយម្នាក់បានយកឈើទៅស៊កក្នុងប្រដាប់ភេទអ្នកទោសស្ត្រីម្នាក់។

## មនុស្សឃាត

១៣៨. បុគ្គលិកនៅមន្ទីរស-២១ បានបង្កឲ្យមានការស្លាប់អ្នកទោសជាច្រើនដោយផ្ទាល់ ឬដោយប្រយោល។ ក្នុងករណីជាច្រើន អ្នកទោសត្រូវបានសម្លាប់ដោយចេតនា ដោយវិធី ខុសៗគ្នា។ ក្នុងករណីផ្សេងទៀត ទោះបីជាចារីអាចគ្មានចេតនាសម្លាប់ ក៏ពួកគេដឹងថា ទង្វើរបស់ពួកគេអាចបណ្តាលឲ្យអ្នកទោសស្លាប់ ឧទាហរណ៍នៅពេលពួកគេវាយដំ ឬធ្វើទារុណកម្មលើអ្នកទោស ។

## ការសម្លាប់រង្គាល

១៣៩. ល័ក្ខខ័ណ្ឌនៃការរស់នៅដែលត្រូវបានអនុវត្តចំពោះអ្នកទោសនៅស-២១ ត្រូវបានរៀបចំឡើងដើម្បីធ្វើយ៉ាងណាបង្កឲ្យមានការស្លាប់។ ល័ក្ខខ័ណ្ឌនៃការរស់នៅទាំងនេះរាប់បញ្ចូលផងដែរជាអាទិ៍ ការបង្អត់អាហារ និងកង្វះខាតថ្នាំសង្កូវសមស្រប។

១៤០. ការសម្លាប់ដោយខុសច្បាប់នៃអ្នកទោសចំនួនលើសពី ១២៣៨០នាក់ ដែលបណ្តាលមកពីការសម្លាប់ឬល័ក្ខខ័ណ្ឌនៃការរស់នៅ បង្កើតបានជាការសម្លាប់រង្គាលនៃជនស៊ីវិល។ ការសម្លាប់រង្គាលនេះត្រូវបានបង្ហាញតាមរយៈឯកសារ ឬសក្ខីកម្មជាច្រើន ព្រមទាំងសាកសពជាច្រើន ដែលត្រូវបានរកឃើញនៅក្នុងរណ្តៅរួម។

## ការធ្វើទុក្ខបុកម្នេញ

១៤១. ការស៊ើបសួរបានបង្ហាញថា អ្នកទោសនៅមន្ទីរស-២១ត្រូវបានដកហូតនូវសិទ្ធិជាមូលដ្ឋានរបស់ពួកគេក្នុងនោះមាន៖ សិទ្ធិរស់រានមានជីវិត សិទ្ធិមានសេរីភាព សិទ្ធិមានសុវត្ថិភាពបុគ្គល សិទ្ធិទទួលបានការជំនុំជម្រះប្រកបដោយយុត្តិធម៌ និងសេរីភាពដើរហើរ។ សិទ្ធិជាមូលដ្ឋានទាំងនេះត្រូវបានដកហូត ឬបំពានចាប់ពីពេលដែលពួកគេត្រូវបានចាប់ខ្លួន និងអំឡុងពេលជាប់ឃុំឃាំង រួមទាំងពេលសួរចម្លើយ ពេលកសាងខ្លួន ហើយរហូតដល់ពេលសម្លាប់។ អ្នកទោសត្រូវបានដកហូតនូវសិទ្ធិទាំងនេះ ដោយមូលហេតុទស្សនៈនយោបាយពិតប្រាកដ ឬតាមការសន្មត់របស់ពួកគេ ឬការប្រឆាំងទៅនឹងអ្នកកាន់អំណាចនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា។ អ្នកទាំងនោះត្រូវបានឃុំឃាំងដោយបំពារបំពាន ត្រូវបានធ្វើឲ្យទៅជាទាសករ និងជាជនរងគ្រោះនៃអំពើទារុណកម្ម ការកាប់សម្លាប់ ឬអំពើអមនុស្សធម៌ផ្សេងទៀត។

១៤២. ឌុចបានដឹងអំពីគោលនយោបាយរើសអើងទាំងនេះ ដែលមន្ទីរស-២១បានអនុវត្ត ហើយចេតនារបស់គាត់នៅក្នុងការប្រព្រឹត្តស្របតាមនយោបាយនេះត្រូវបានបង្ហាញតាមរយៈអំពើរបស់គាត់ មុខតំណែងដែលគាត់បានកាន់នៅក្នុងមន្ទីរនេះ ឋានៈរបស់គាត់ជាសមាជិកបក្សកុម្មុយនីស្តកម្ពុជា និងទំនាក់ទំនងរបស់គាត់ជាមួយនិងថ្នាក់ដឹកនាំរបស់បក្ស។

## អំពើអមនុស្សធម៌ផ្សេងៗទៀត

១៤៣. អ្នកទោសនៅមន្ទីរ ស-២១ បានទទួលរងនូវការប៉ះពាល់ដល់រូបរាងកាយ និងផ្លូវចិត្ត ដែលបណ្តាលមកពីអំពើអមនុស្សធម៌ ដែលពួកគេទទួលរង ក្នុងនោះរួមមាន៖ ការមិនផ្តល់ឱ្យដោយចេតនានូវអាហារគ្រប់គ្រាន់ បរិក្ខារអនាម័យ និងការព្យាបាលជំងឺសមរម្យ។ ក្នុងពេលជាប់ឃុំឃាំង អ្នកទោសត្រូវបានវាយដំ និងប្រឈមមុខទៅនឹងការរឹតត្បិតដ៏តឹងរឹង។ ភាពធ្ងន់ធ្ងរដែលទទួលរងជាលក្ខណៈរួម ឬបុគ្គល ធ្វើឱ្យអ្នកទោសខ្សោយកម្លាំងចិត្ត អស់តម្លៃ និងអស់លក្ខណៈជាមនុស្សជាតិ។ ទាំងនេះជាស្ថានភាពដែលធ្វើឱ្យពួកគេស្ថិតក្នុងការភ័យខ្លាចជានិច្ច។

## ខ. ការបំពារបំពានយ៉ាងធ្ងន់ធ្ងរនៅលើអនុសញ្ញាក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩

### ធាតុផ្សំទូទៅ

១៤៤. អំពើហិង្សាយោធាអូសបន្លាយអស់រយៈពេលវែងរវាងកងកម្លាំងប្រដាប់អាវុធរបស់កម្ពុជាប្រជាធិបតេយ្យ និងវៀតណាមបានផ្ទុះឡើងក្នុងឆ្នាំ១៩៧៥ ហើយកាន់តែតានតឹងឡើង យ៉ាងហោចណាស់ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ១៩៧៩ ។ ក្នុងអំឡុងពេលនោះ ឈ្លើយសឹក និងជនស៊ីវិលវៀតណាមរាប់រយនាក់ត្រូវបានចាប់ខ្លួន និងបញ្ជូនមកមន្ទីរស-២១។ មនុស្សជាច្រើនទៀតដែលមេដឹកនាំកម្ពុជាចោទថាជា “គិញ” វៀតណាម ឬជាខ្សែស្រឡាយវៀតណាមត្រូវបានចាប់ដាក់ឃុំឃាំងផងដែរ។ ភាគច្រើននៃអ្នកទោសទាំងនេះត្រូវបានបញ្ជូនពីសមរភូមិប្រយុទ្ធទៅមន្ទីរស-២១ដោយផ្ទាល់។ ការឆ្លើយសារភាពជាច្រើនរបស់អ្នកទោសទាំងនោះ ដែលទទួលបានមកពីការធ្វើទារុណកម្ម និងដែលត្រូវបានសរសេរដោយដៃឬថតទុក បានបង្ហាញអំពីការស៊ើបការណ៍យោធា ឬក៏ត្រូវបានចាក់តាមវិទ្យុ ហើយត្រូវបានបោះពុម្ពដោយស្ថាប័នផ្លូវការរបស់បក្សកុម្មុយនីស្តកម្ពុជាក្នុងគោលបំណងដាក់ជាផ្នែកមួយនៃយុទ្ធសាស្ត្រឃោសនាយោធា។ តាមរយៈតួនាទី របស់គាត់នៅមន្ទីរស-២១ ដែលអនុញ្ញាតឱ្យគាត់ទាក់ទងជាប្រចាំជាមួយមេដឹកនាំនយោបាយនិងយោធានៃរបបនោះ ឌុចបានដឹងយ៉ាងច្បាស់លាស់ថា ឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅមន្ទីរស-២១បានកើតឡើង នៅក្នុងបរិបទ

នៃជម្លោះប្រដាប់អាវុធអន្តរជាតិជាមួយប្រទេសវៀតណាម និងប្រឆាំងនឹងអ្នកដែលមិនគាំទ្ររបបកម្ពុជាប្រជាធិបតេយ្យឬអ្នកដែលជាភាគីបដិបក្ខនៃជម្លោះ។

១៤៥. ដូច្នេះ អំពើឧក្រិដ្ឋខាងក្រោមដែលបានកំណត់ចូលក្នុងប្រភេទបទល្មើស ដែលមានចែងក្នុងមាត្រា៦នៃច្បាប់អ.វ.ត.ក បង្កើតបានជាការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញា ទីក្រុងហ្សឺណែវ ថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩ ពីព្រោះថាអំពើទាំងនោះត្រូវបានប្រព្រឹត្តនៅក្នុងបរិបទជម្លោះប្រដាប់អាវុធអន្តរជាតិ និងប្រឆាំងនឹងជនដែលទទួលបានការការពារ។ ចារីក៏បានដឹងផងដែរអំពីកាលៈទេសៈអង្គហេតុដែលបង្កជម្លោះ និងឋានៈជាជនដែលត្រូវបានការពារដែលផ្តល់ទៅឱ្យអ្នកទោសទាំងនោះ។

## ការឃុំឃាំងជនស៊ីវិលដោយខុសច្បាប់

១៤៦. ជនស៊ីវិលវៀតណាមជាងមួយរយនាក់ត្រូវបានឃុំឃាំងនៅមន្ទីរស-២១។ គ្មានភាពខុសគ្នាឡើយរវាងជនស៊ីវិលវៀតណាម និងអ្នកទោសផ្សេងៗទៀត ពោលគឺពួកគេទាំងអស់ត្រូវបានដកហូតនូវសិទ្ធិសេរីភាពរបស់ពួកគេដោយបំពារបំពាន។

## ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌ និងទៀងទាត់

១៤៧. យ៉ាងហោចណាស់ជនដែលទទួលបានការការពារចំនួន៤០០នាក់ ត្រូវបានដកហូតដោយចេតនា នូវសិទ្ធិទទួលបានការវិនិច្ឆ័យដោយតុលាការអនាគតិ និងឯករាជ្យ ដូចដែលបានកំណត់នៅក្នុងអនុសញ្ញាទីក្រុងហ្សឺណែវឆ្នាំ១៩៤៩ និងជាពិសេសសិទ្ធិត្រូវបានជូនដំណឹងក្នុងរយៈពេលសមស្រប អំពីបទល្មើសដែលចោទប្រកាន់ទៅលើពួកគេ សិទ្ធិមិនត្រូវបានដាក់ទោសជាសមូហភាព សិទ្ធិទទួលបានការការពារតាមគោលការណ៍នីត្យានុកូលភាព ឬសិទ្ធិទទួលបានការផ្តន្ទាទោសដោយតុលាការមានសមត្ថកិច្ច។

### ការបង្កដោយចេតនាឲ្យមានការឈឺចាប់ធ្ងន់ធ្ងរ

១៤៨. ជនទទួលបានការការពារទាំងនេះត្រូវបានដាក់ឲ្យប្រឈមមុខដោយចេតនាទៅនឹងការឈឺចាប់ផ្លូវកាយ ឬផ្លូវចិត្តធ្ងន់ធ្ងរ ដោយសារអំពើអមនុស្សធម៌ ដែលរួមមាន៖ ការមិនផ្ដល់ឲ្យដោយចេតនា នូវម្ហូបអាហារគ្រប់គ្រាន់ បរិក្ខារអនាម័យ និងការព្យាបាលជំងឺដោយសមរម្យ។ អ្នកទោសត្រូវបានវាយដំ និងដាក់ឲ្យប្រឈមមុខនឹងការរឹតត្បិតដ៏តឹងតែងក្នុងអំឡុងពេលនៃការឃុំឃាំង។ ភាពធ្ងន់ធ្ងរនៃស្ថានភាពរួម ឬស្ថានភាពដាច់ដោយឡែកធ្វើឲ្យអ្នកជាប់ឃុំឃាំងថមថយកម្លាំងចិត្ត អស់តម្លៃ និងអស់លក្ខណៈជាមនុស្សជាតិ។ ទាំងនេះជាស្ថានភាពដែលធ្វើឲ្យពួកគេស្ថិតក្នុងការភ័យខ្លាចជានិច្ច។

### ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌

១៤៩. ក្នុងពេលសួរចម្លើយ បុគ្គលិកនៅមន្ទីរ ស-២១ បានបង្កដោយចេតនា អោយមានការឈឺចាប់ ឬការរងទុក្ខផ្លូវកាយ ឬផ្លូវចិត្តដល់អ្នកទទួលបានការការពារ។ ការប្រើប្រាស់វិធីទាំងនេះក្នុងពេលសួរចម្លើយគឺមានគោលបំណងទាញយកចម្លើយសារភាព ដែលអាចឲ្យដឹងអំពីព័ត៌មានយោធា ឬអាចគាំទ្រដល់យុទ្ធសាស្ត្រឃោសនារបស់បក្សកុម្មុយនីស្តកម្ពុជា។

១៥០. បុគ្គលិកមន្ទីរ ស-២១ បានបង្កដោយចេតនា ឱ្យមានរបួសផ្លូវចិត្តធ្ងន់ធ្ងរ និងការឈឺចាប់ដល់រាងកាយ ឬសុខភាពរបស់អ្នកទោស ឬឲ្យពួកគេស្ថិតក្នុងស្ថានភាពដែលអាចកំណត់បានជាការប៉ះពាល់ធ្ងន់ធ្ងរដល់សេចក្ដីថ្លៃថ្នូររបស់មនុស្សជាតិ។

### ការធ្វើមនុស្សឃាតដោយចេតនា

១៥១. បុគ្គលិកមន្ទីរស-២១បង្កដោយចេតនាឲ្យមានការស្លាប់ជនទទួលការការពារ យ៉ាងហោចណាស់ ៤០០នាក់ដោយផ្ទាល់ និងដោយប្រយោល តាមរយៈវិធីសាស្ត្រផ្សេងៗ។

## គ. បទឧក្រិដ្ឋជាត

១៥២. អំពើជាក់លាក់មួយចំនួនដែលបានបង្ហាញតាមរយៈការស៊ើបសួរ និងដែលបានកំណត់ជាបទឧក្រិដ្ឋខាងលើ អាចត្រូវបានកំណត់យ៉ាងច្បាស់លាស់ផងដែរ ស្របតាមច្បាប់ជាតិកម្ពុជា ជាបទល្មើសមនុស្សឃាត និងទារុណកម្មដែលមានចែង និង ផ្តន្ទាទោសដោយមាត្រា៥០០ មាត្រា៥០១ មាត្រា៥០៣ និង មាត្រា ៥០៦ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦ និង ដូចមានចែងក្នុងមាត្រា៣ថ្មី នៃច្បាប់ អ.វ.ត.ក។ ប៉ុន្តែ អំពើទាំងនេះត្រូវតែទទួលបានការចោទប្រកាន់ក្រោមការកំណត់ប្រភេទបទល្មើសដែលមានលក្ខណៈខ្ពស់ជាងគេ ដែលនៅក្នុងករណីនៃសំណុំរឿងនេះគឺឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងការបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ១៩៤៩។

## ឃ. ទម្រង់នៃការទទួលខុសត្រូវ

### ការប្រព្រឹត្ត

១៥៣. ឌុចបានធ្វើទារុណកម្មដោយផ្ទាល់ ឬប្រព្រឹត្តអមនុស្សធម៌ចំពោះអ្នកទោសនៅមន្ទីរស-២១ ហើយអំពើនេះត្រូវបានប្រព្រឹត្តក្នុងឱកាសដាច់ដោយឡែកពីគ្នា និងតាមរយៈមធ្យោបាយ ផ្សេងៗដូចបានរៀបរាប់ខាងលើ។

### ការបញ្ជា

១៥៤. ឌុចបានកាន់មុខតំណែងដែលមានអំណាចនៅមន្ទីរ ស-២១ ក្នុងរយៈពេលនៃយុត្តាធិការតាមពេលវេលា របស់អ.វ.ត.ក។ មុខតំណែងនេះអនុញ្ញាតឲ្យ ឌុចបញ្ជាអ្នកនៅក្រោមបង្គាប់ឲ្យអនុវត្តរាល់ការងារចាំបាច់ពាក់ព័ន្ធនឹងដំណើរការនៃមន្ទីរស-២១។ មន្ទីរស-២១ នេះដំណើរការក្នុងលក្ខណៈជាខ្សែសង្វាក់នៃការបញ្ជាដែលត្រូវបានបញ្ជាក់យ៉ាងច្បាស់លាស់ ហើយតួនាទីរបស់បុគ្គលិកម្នាក់ៗត្រូវបានចែង និងអនុវត្តយ៉ាងហ្មត់ចត់។

១៥៥. បញ្ជា និងសេចក្តីណែនាំ ទោះជាពីឌុចក្តី ឬពីថ្នាក់លើរបស់គាត់ក្តីត្រូវបានដាក់ចេញ ឬបញ្ជា

បន្តជាមួយនឹងចេតនា និងការដឹងយ៉ាងច្បាស់អំពីផលវិបាកពីបញ្ជានេះ ហើយដោយដឹងថា បញ្ជា ឬសេចក្តីណែនាំទាំងនេះនឹងត្រូវបានគោរព និងអនុវត្តជាប្រព័ន្ធចាត់តាំង។ បញ្ជានៅមន្ទីរស-២១ អាចមានលក្ខណៈច្បាស់លាស់ ឬ ស្រពិចស្រពិល ទូទៅ ឬជាក់លាក់ និងអាចបញ្ជូនទៅផ្ទាល់ ឬមិនផ្ទាល់ទៅដល់អ្នកអនុវត្ត។

១៥៦. តាមរយៈរបៀបដែលខ្លួនដឹកនាំនៅស-២១ ឌុចបានរួមចំណែកយ៉ាងសំខាន់ដល់ព្រឹត្តិការណ៍នានាដែលបានកើតឡើង ហើយអំពើជាច្រើនទៀតដែលអ្នកនៅក្រោមបង្គាប់របស់គាត់បានប្រព្រឹត្ត ឬប៉ុនប៉ងប្រព្រឹត្តអាចត្រូវបានកំណត់បានជាអំពើឧក្រិដ្ឋស្របតាមអត្ថន័យនៃច្បាប់ និងកិច្ចព្រមព្រៀងស្តីពី អ.វ.ត.ក។

## ការទទួលខុសត្រូវរបស់ថ្នាក់លើ

១៥៧. ក្នុងនាមជាអនុលេខា និងបន្ទាប់មកជាលេខានៅមន្ទីរស-២១ ឌុចបានប្រើប្រាស់នូវការបញ្ជា និងការគ្រប់គ្រង តាមការជាក់ស្តែង និងតាមផ្លូវច្បាប់ ទៅលើបុគ្គលិកទាំងអស់នៅមន្ទីរស-២១។ តួនាទីនេះផ្តល់ឲ្យគាត់ ជាអាទិ៍ នូវអំណាចចេញបញ្ជាដើម្បីឲ្យអនុវត្តនូវរាល់ភារកិច្ចចាំបាច់ពាក់ព័ន្ធនឹងដំណើរការនៃមន្ទីរនេះ។

១៥៨. ក្នុងអាណត្តិរបស់គាត់នៅមន្ទីរស-២១ ឌុច បានដឹង គួរតែបានដឹង ឬបានធ្វើមិនដឹងមិនលឺដោយចេតនាចំពោះព័ត៌មានដែលចង្អុលបង្ហាញយ៉ាងច្បាស់ថា អ្នកនៅក្រោមបង្គាប់របស់គាត់បានប្រព្រឹត្ត ឬបម្រុងនឹងប្រព្រឹត្តបទល្មើស ដូចពណ៌នានៅក្នុងដីកាដំណោះស្រាយនេះ។ អំពើទាំងនេះអាចត្រូវបានកំណត់ជាបទឧក្រិដ្ឋ ដែលស្ថិតក្នុងយុត្តាធិការរបស់អ.វ.ត.ក។ ដោយសារខកខានមិនបានចាត់វិធានការណ៍សមស្រប និងចាំបាច់នានាដើម្បី ទប់ស្កាត់ការប្រព្រឹត្តឧក្រិដ្ឋកម្ម ឬដាក់ទណ្ឌកម្មចំពោះចារីនៃអំពើខាងលើ ឌុចខកខានមិនបានអនុវត្តនូវកាតព្វកិច្ចរបស់គាត់ក្នុងការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពលើអ្នកនៅក្រោមបង្គាប់របស់គាត់។

## ការរៀបចំផែនការ

១៥៩. ឌុចបានចូលរួមចំណែកយ៉ាងសំខាន់នៅក្នុងដំណើរការរៀបចំ ឬការដាក់ឱ្យដំណើរការនូវគម្រោងដែលឈានទៅដល់ការបង្កើតមន្ទីរស-២១ ដោយដឹងថាសកម្មភាពនៃមន្ទីរនេះនឹងក្លាយជាអំពើឧក្រិដ្ឋ។ ម្យ៉ាងវិញទៀត នៅពេលដែលមន្ទីរនេះបានបង្កើត ឌុចបានរៀបចំផែនការឧក្រិដ្ឋកម្មជាក់លាក់នានា ដែលត្រូវបានប្រព្រឹត្តជាមួយនឹងចេតនាថា ឧក្រិដ្ឋកម្មទាំងនេះត្រូវតែប្រព្រឹត្ត។

## ការញុះញង់

១៦០. ក្នុងនាមជាអនុប្រធាន ជាប្រធានមន្ទីរស-២១ និងក្នុងនាមជាសមាជិកសកម្មរបស់បក្សកុម្មុយនីស្តកម្ពុជា ឌុច បានជម្រុញនិងលើកទឹកចិត្ត បុគ្គលិកនៅមន្ទីរ ស-២១ ឱ្យប្រព្រឹត្តបទឧក្រិដ្ឋកម្មផ្សេងៗ ដូចបានពណ៌នាក្នុងដីកាដំណោះស្រាយនេះ តាមរយៈការណែនាំ ការបង្រៀនជាទ្រឹស្តី និងមាគ៌ានយោបាយរបស់បក្ស និងប្រគល់ជាភារកិច្ច ដល់ពួកគេ ក៏ដូចជាតាមរយៈវត្តមានរបស់គាត់នៅកន្លែងកើតហេតុ និងការចូលរួមរបស់គាត់នៅគ្រប់ទិដ្ឋភាពទាំងអស់នៃដំណើរការមន្ទីរស-២១។ ការដឹកនាំ និងការចូលរួមរបស់ **ឌុច** គឺពិតជាកត្តាចំបងក្នុងការធ្វើឱ្យមន្ទីរស-២១ មានដំណើរការ ហើយបង្ហាញអំពីចេតនាក្នុងការដាក់ឱ្យបុគ្គលិកនៃមន្ទីរនេះប្រព្រឹត្តបទឧក្រិដ្ឋដូចបានរៀបរាប់ខាងលើ។

## ការជួយ និងការជម្រុញ

១៦១. មនុស្សនៅក្រោមបង្គាប់របស់ឌុច គោរព និងកោតខ្លាចអំណាចរបស់គាត់ ហើយនៅគ្រប់កំរិតនៃដំណើរការរបស់មន្ទីរស-២១ ឌុចផ្តល់ជំនួយជាក់ស្តែង ការលើកទឹកចិត្ត ឬការគាំទ្រផ្នែកស្មារតីដល់ពួកគេ។ ការជួយ និងការជម្រុញ នេះ បានរួមចំណែកយ៉ាងសំខាន់ដល់ការប្រព្រឹត្តិឧក្រិដ្ឋកម្មនានា ដូចបានរៀបរាប់ក្នុងដីកាដំណោះស្រាយនេះ។ ជាងនេះទៅទៀត ឌុចបានដឹងច្បាស់ថា ទង្វើរបស់គាត់នឹងជួយដល់ការប្រព្រឹត្តនូវឧក្រិដ្ឋកម្មទាំងនេះ ហើយ ឌុច ក៏បានយល់

អំពីធាតុផ្សំសំខាន់ៗ និងដឹងអំពីចេតនារបស់ចារីផងដែរ។

## ផ្នែកទី ៣. ព័ត៌មានអំពីបុគ្គលិកលក្ខណៈ[484]

### ក. កុមារភាព និងវ័យពេញវ័យ

១៦២. ឌុចកើតនៅថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ១៩៤២ នៅភូមិពៅរើយ ឃុំពាមបាង ស្រុកស្ទោង ខេត្តកំពង់ធំ[485]។ ឪពុករបស់គាត់ (ស្លាប់ក្នុងឆ្នាំ១៩៩០) និងម្ដាយរបស់គាត់ (នៅរស់) ទាំងពីរនាក់ គឺជាកសិករក្រីក្រ និងមានដើមកំណើតជាជនជាតិចិន។ នៅក្នុងបញ្ជីអត្រានុកូលដ្ឋាន ឌុច មានឈ្មោះថា កាំង ឈាវ។ នៅពេលដែលគាត់អាយុបានពីរ ឬបីខែ ដោយជឿតាមសម្ដីរបស់គ្រូហោរា ឈ្មោះរបស់គាត់ត្រូវបានប្ដូរទៅជា យឹម គាវ វិញ។ ប៉ុន្តែដោយហេតុថាគាត់មិនចូលចិត្តឈ្មោះនេះ នៅអាយុ១៥ឆ្នាំ គាត់បានស្នើសុំទៅឪពុករបស់គាត់ឲ្យប្ដូរឈ្មោះជាថ្មី ហើយគាត់ក៏បានឆ្លៀតឱកាសនោះប្ដូរថ្ងៃ ខែ ឆ្នាំកំណើតរបស់គាត់ឲ្យអាយុតិចជាងមុន ដើម្បីអាចចុះឈ្មោះចូលរៀនបាន។ ដូច្នេះ អត្តសញ្ញាណថ្មីរបស់គាត់គឺ កាំង ហ្គេកអ៊ាវ កើតនៅ ថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ១៩៤៥។ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ គាត់ប្រើប្រាស់ឈ្មោះ *"ឌុច"* ជាឈ្មោះដែលគាត់ប្រើញឹកញាប់ជាងគេ។ ផ្ទុយទៅវិញ គាត់ឲ្យគេហៅគាត់ថា ហង់ ពិន វិញក្នុងរយៈកាលដែល គាត់រស់នៅក្នុងប្រទេសចិនពីចុងឆ្នាំ១៩៨៦ ដល់ខែកក្កដា ឆ្នាំ១៩៨៩។

១៦៣. ឌុចគឺជាកូនច្បង និងជាកូនប្រុសទោលក្នុងចំណោមបងប្អូនប្រាំនាក់។ គាត់មានទំនាក់ទំនងល្អជាមួយឪពុកម្ដាយរបស់គាត់ និងជាមួយបងប្អូនស្រីៗរបស់គាត់។ គាត់ប្រាប់ថា គាត់ឧស្សាហ៍

ឃើញណាស់កាលគាត់នៅពីតូច។ វាជាជម្ងឺដែលគាត់ហៅថា៖ *"ជម្ងឺបង្កឡើងដោយភាពក្រីក្រ និងជីវិតនៅជនបទ*[486] *"*។ គាត់ចូលរៀនយឺតក្រោយអាយុកំណត់ គឺនៅអាយុប្រាំបួនឆ្នាំ។ ដោយសារគាត់ជាសិស្សល្អ ពោរពេញទៅដោយការកោតក្រែង និងសេចក្ដីគោរពស្រឡាញ់ដ៏ជ្រាលជ្រៅចំពោះលោកគ្រូអ្នកគ្រូ គាត់បានបញ្ចប់ការសិក្សារបស់គាត់ ជាបន្តបន្ទាប់នៅអនុវិទ្យាល័យកំពង់ធំ នៅវិទ្យាល័យសៀមរាប និងបន្ទាប់មកនៅវិទ្យាល័យស៊ីសុវត្ថិក្រុងភ្នំពេញ ដែលជាកន្លែងដែលគាត់ទទួលបានសញ្ញាប័ត្រមធ្យមសិក្សាទុតិយភូមិក្នុងឆ្នាំ១៩៦៤។

## ខ. ការប្រែប្រួលស្ថានភាពផ្ទាល់ខ្លួន វិជ្ជាជីវៈ និងនយោបាយ

១៦៤. នៅក្នុងឆ្នាំ១៩៦៥ ឌុចត្រូវបានតែងតាំងជាគ្រូបង្រៀនផ្នែកគណិតវិទ្យានៅអនុវិទ្យាល័យស្គន់។ កូនសិស្សរបស់គាត់ពណ៌នាអំពីគាត់ថា ជាមនុស្សស្មោះត្រង់ តស៊ូ និងជានិច្ចជាកាល តែងតែជួយដល់អ្នកទីទាល់ក្រ[487]។ ប៉ុន្តែវិជ្ជាជីវៈនេះមិនបានបន្តយូរប៉ុន្មានទេ ព្រោះនៅពេលនោះ ឌុចចាប់ផ្ដើមក្លាយទៅជាជនបដិវត្តន៍ ហើយដែលនេះគឺជាការងារមួយ ដែលគាត់ត្រូវបន្តបំពេញក្នុងរយៈពេលជាង២០ឆ្នាំ។ តាំងតែពីអាយុ១៥ឆ្នាំមក គាត់ចាប់ផ្ដើមមានចំណាប់អារម្មណ៍ចំពោះការតស៊ូផ្នែកនយោបាយ ដោយសារគាត់មានការអាក់អន់ចិត្តចំពោះការប្រមាថលើស្ថានភាពក្រីក្ររបស់គ្រួសារគាត់ ជាពិសេសដោយសារការប្រឈមមុខទៅនឹងការទារសំណងឥតស្រាកស្រាន្តពី សំណាក់ពូរបស់គាត់ ដែលជាអ្នករកស៊ីចងការប្រាក់ក្នុងអត្រាមួយខ្ពស់។ ដូចគ្នានេះដែរ គាត់អាចនឹងទទួលឥទ្ធិពលនយោបាយពីសំណាក់គ្រូៗជាច្រើនរបស់គាត់ ដែលបានបរិហារអំពីអំពើពុករលួយ និងភាពអយុត្តិធម៌នៅក្នុងសង្គម ហើយជាពិសេសតាមរយៈគ្រូបង្រៀនរបស់គាត់ ម្នាក់ឈ្មោះ II ដែលក្រោយមកគាត់ត្រូវបានគេសម្លាប់នៅមន្ទីរស២១[488]។

១៦៥. ជីវិតគ្រួសារ និងជីវិតស្នេហារបស់ ឌុចប្រព្រឹត្តទៅប្រកបដោយស្ថេរភាពធម្មតា លើកលែងតែការខកចិត្តស្នេហាកាលនៅយុវវ័យ ដែលគាត់បានចាត់ទុកជារឿងសំខាន់សម្រាប់គាត់។ ឌុច

និទានតែអំពីនារីម្នាក់ប៉ុណ្ណោះនៅក្នុងជីវិតរបស់គាត់ គឺប្រពន្ធរបស់គាត់ឈ្មោះ JJ ដែលជាជាងកាត់ដេរសំលៀកបំពាក់។ គាត់បានពន្យល់ថា ដោយសារតែមានការអនុញ្ញាតពី សុន សេន ទើបគាត់អាចជ្រើសរើសយកប្រពន្ធរបស់គាត់ ដែលគាត់បានស្គាល់នៅក្នុងឆ្នាំ១៩៧៥។ ឌុចបានរៀបការជាមួយនាងនៅក្នុងឆ្នាំ១៩៧៦ គឺនៅពេលដែលគាត់នៅជាប្រធានមន្ទីរស២១។ គាត់មានកូនចំនួនបួននាក់៖ កូនស្រីទីមួយ កើតនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ១៩៧៧ កូនប្រុសទីពីរ កើតនៅថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៧៨ កូនស្រីទីបី កើតនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ១៩៨១ និងកូនប្រុស ទីបួន កើតនៅថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៥។

១៦៦. បន្ទាប់ពីមានការដួលរលំនៅក្នុងឆ្នាំ១៩៧៩ ឌុចបន្តរស់នៅនិងធ្វើការជាមួយខ្មែរក្រហមអស់រយៈពេលជាងដប់ឆ្នាំ។ គាត់បានបញ្ជាក់ថា គាត់ធ្លាប់មានបំណងចាកចេញពីចលនានេះដែរ ប៉ុន្តែគាត់ ស្ថិតនៅក្នុងស្ថានភាពមួយដែលមិនអាចធ្វើទៅបានឡើយ ដោយសារតែតាំងតែពីមកដល់សំឡុត នៅថ្ងៃ ទី៣០ ខែធ្នូ ឆ្នាំ១៩៧៩ គាត់ហាក់ដូចជាត្រូវបានគេចាត់ទុកដូចជា “អ្នកទោស” នៃរបបអញ្ចើង។ នៅទីនោះ គាត់មានមុខងារសំខាន់ជាគ្រូបង្រៀន។ នៅខែតុលា ឆ្នាំ១៩៨៦ ប្រធានរបស់គាត់ឈ្មោះ សុន សេន (ប្រធានមន្ទីរ ក១៨ ជាកន្លែងដែលឌុចធ្វើការ) បានបញ្ជូនគាត់ឲ្យទៅប្រទេសចិនដើម្បី បង្រៀនភាសាខ្មែរដល់និស្សិតចិន។ គាត់រស់នៅនិងធ្វើការក្រោមបញ្ជារបស់ប្រពន្ធ សុន សេន ឈ្មោះ KK នៅក្នុងប្រទេសនោះអស់រយៈពេលពីរឆ្នាំ។ នៅក្នុងឆ្នាំ១៩៩២ នៅពេលដែល ប៉ុល ពតចាត់តាំងឲ្យគាត់ទទួលបន្ទុកផ្នែកសេដ្ឋកិច្ច នៅភូមិផ្គាំ ស្រុកថ្មពួក ខេត្តបន្ទាយមានជ័យ ឌុចចាប់ផ្តើមបាត់បង់ទំនាក់ទំនងជាមួយថ្នាក់លើរបស់គាត់។ គាត់បានពន្យល់ថា ការបែកបាក់គ្នាចេះតែរីកធំឡើងៗ ទាហានខ្មែរក្រហមចាប់ផ្តើមបែកខ្ញែកគ្នាបន្តិចម្តងៗ ក្នុងខណៈពេលដែល សង្គ្រាមចេះតែបន្ត។ គាត់បានប្រកបការងារជាគ្រូបង្រៀន រួមផ្សំជាមួយនិងការរកស៊ីលក់អង្ករ និងចិញ្ចឹមជ្រូក[489]។ នៅថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ១៩៩៥ នៅភូមិផ្គាំ គាត់ទទួលរងគ្រោះនូវ “អំពើប្លន់ក្នុងផ្ទះ” ដ៏អាចក៏កំបាំងមួយ ដែលក្នុងពេលនោះប្រពន្ធរបស់គាត់ ត្រូវបានចោរចាក់មួយកំបិតចំដើមទ្រូងបណ្តាលឲ្យស្លាប់ តែគាត់វិញគ្រាន់តែមានរបួសបន្តិចបន្តួចប៉ុណ្ណោះ។ ចំពោះព្រឹត្តិការណ៍នេះ

ឌុចគិតថា វាគឺជាការប៉ុនប៉ងធ្វើឃាដកម្មគិតទុកជាមុន ដែលរៀបចំឡើងដោយ ប៉ុល ពត[490]។ បន្ទាប់ពីការស្លាប់របស់ប្រពន្ធរបស់គាត់ ឌុចបានចាប់ផ្តើមចូលរួមក្នុងការជួបជុំរបស់ព្រះវិហារផ្សព្វផ្សាយសាសនាគ្រិស្តនៅខេត្តបាត់ដំបង។ គាត់ប្តូរមកកាន់សាសនាគ្រិស្តនៅក្នុងឆ្នាំ១៩៩៦ ហើយគាត់ក៏បាននាំកូនប្រុសស្រីរបស់គាត់ចូលក្នុងសាសនានេះផងដែរ។ ក្រោយមកគាត់បានត្រឡប់មករស់នៅសំឡូតវិញ។ ដោយសារមានការចាប់ផ្តើមឡើងវិញនៃការប្រយុទ្ធគ្នារវាងខ្មែរក្រហម ជាមួយនិងកម្លាំងខាងរដ្ឋាភិបាល គេបានជម្លៀសប្រជាជនចេញពីក្នុងឃុំនោះ ហើយគាត់ក៏បានឆ្លងទៅរស់នៅក្នុងប្រទេសថៃ ជាមួយនិងប្រជាជនទាំងអស់នោះដែរ។ នៅខែកក្កដា ឆ្នាំ១៩៩៧ គាត់បានចាប់ផ្តើមធ្វើការឱ្យសមាគមន៍មួយដែលមានឈ្មោះថា គណៈកម្មាធិការអាមេរិកទទួលបន្ទុកជនភៀសខ្លួន (American Refugee Committee: ARC) និងបានបន្តការងារនេះ រហូតដល់ក្រុមអ្នកសារព័ត៌មានស្គាល់អត្តសញ្ញាណរបស់គាត់នៅក្នុងខែឧសភា ឆ្នាំ១៩៩៩[491] ដែលនាំឱ្យមានការចាប់ខ្លួនគាត់នាប៉ុន្មានថ្ងៃក្រោយមក។

## គ. ការទទួលស្គាល់ការទទួលខុសត្រូវ

១៦៧. ឌុចទទួលស្គាល់ជានិច្ចនូវការទទួលខុសត្រូវរបស់គាត់ ក្នុងឋានៈជាប្រធានមន្ទីរស២១ ចំពោះឧក្រិដ្ឋកម្មដែលកើតមានឡើង[492]។ គាត់បានពន្យល់ថា គេបាននាំគាត់ឱ្យនិយាយបកស្រាយអំពីបញ្ហានេះនៅក្នុងឆ្នាំ១៩៩៩ ព្រោះថា *"គាត់ត្រូវតែរៀបរាប់អំពីការពិតទាំងឡាយដែលទាក់ទងទៅនឹងមន្ទីរ ស២១"* បន្ទាប់ពីគាត់បានដឹងថា *"ប៉ុល ពត បដិសេធអត្ថិភាពនៃស២១ ហើយថា ស-២១ គឺជាការប្រឌិតរបស់យួន[493] "*។ ឌុចមិនត្រឹមតែបង្ហាញជាប្រចាំនូវវិប្បដិសារីរបស់ខ្លួនចំពោះជនរងគ្រោះ និងក្រុមគ្រួសាររបស់ពួកគេប៉ុណ្ណោះទេ គាត់ថែមទាំងបានធ្វើដូច្នេះចំពោះបុគ្គលិកមន្ទីរស២១ ដែលធ្លាប់នៅក្រោមបង្គាប់របស់ខ្លួនផងដែរ[494]។ គាត់បញ្ជាក់ថា គ្មានបុគ្គលិករបស់គាត់ណាម្នាក់ ដែលបានបំពេញការងារដោយស្ម័គ្រចិត្ត ឬមានមោទនភាពចំពោះអ្វីដែលពួកគេបានធ្វើនោះទេ តែផ្ទុយទៅវិញពួកគេមានការភ័យខ្លាចជាប្រចាំ ចំពោះអាយុជីវិតរបស់ពួកគេ[495]។ ហើយម្នាក់ៗគ្មានជម្រើសអ្វីក្រៅពីអនុវត្តបទបញ្ជានោះឡើយ។


អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា មានទីតាំងស្ថិតនៅ ផ្លូវជាតិលេខ៤ សង្កាត់ ចោមចៅ ខណ្ឌ ដង្កោ ក្រុង ភ្នំពេញ ប្រអប់សំបុត្រលេខ៧១ ទូរស័ព្ទលេខ +៨៥៥(០)២៣ ២១៨៩៤១ ទូរសារលេខ +៨៥៥(០)២៣ ២១៨៩៤១។
Extraordinary Chambers in the Courts of Cambodia, National Road 4, Choam Chao, Dangkoa Phnom Penh
Mail Po Box 71, Phnom Penh Tel:+855(0)23 218914 Fax: +855(0) 23 218941.
Chambres extraordinaires au sein des tribunaux cambodgiens, Route nationale 4, Choam Chao, Dangkoa, Phnom Penh
Boite postale 71, Phnom Penh. Tel: +855(0)23 218914 Fax: +855(0) 23 218941.

១៦៨. ជាងនេះទៅទៀត ឌុច បានចូលរួមសហការណ៍ដោយស្ម័គ្រចិត្តក្នុងដំណើរការនៃកិច្ចស៊ើបសួរ ដោយបានធ្វើការអះអាងថា គាត់គ្មានបំណងដើម្បីនឹងធ្វើឲ្យអ្នកក្រោមបង្គាប់របស់គាត់មានការពាក់ព័ន្ធ ឬទម្លាក់ការទទួលខុសត្រូវទាំងអស់ទៅឲ្យថ្នាក់លើតែឯកឯង ដើម្បីនឹងឲ្យខ្លួនគាត់រួចខ្លួននោះទេ[496]។ នៅពេលដែលមានការលើកឡើងអំពីភាពមិនស្របគ្នានៃសក្ខីកម្មមួយចំនួនដែលគាត់បានធ្វើនៅចំពោះមុខសហចៅក្រមស៊ើបអង្កេត គាត់បានបកស្រាយថា ភាពមិនស្របគ្នានេះគឺបណ្ដាលមកពីអារម្មណ៍នៃ *"ការភ័យខ្លាច និងការខ្មាស់អៀន'* នៅពេលដែលនឹកឃើញដល់ *"ប្រវត្តិនៃឧក្រិដ្ឋកម្មដ៏ឈឺចាប់បំផុត*[497] "។

១៦៩. គាត់បានអះអាងដោះបន្ទុកថា៖ *"ការចូលរួមទាំងស្រុងរបស់ខ្ញុំទៅក្នុងមនោគមន៍វិជ្ជារបស់បក្សកុម្មុយនីស្តកម្ពុជាគឺបូជាជីវិតដើម្បីប្រជាជនរបស់ខ្ញុំ"* គឺមិនមែនដើម្បី *"ប្រព្រឹត្តបទឧក្រិដ្ឋ"* នោះទេ និងបានបន្តថា *"ខ្ញុំត្រូវបានបង្ខំឲ្យគ្រប់គ្រងម-១៣ ចាប់ពីឆ្នាំ១៩៧១មក ខ្ញុំបានក្លាយទៅជាតួអង្គនៃបទឧក្រិដ្ឋ និងក៏ជាចំណាប់ ខ្មាំងនៃរបបនោះផងដែរ*[498] "។ **ឌុច**និយាយថា គាត់បានដឹងអំពីចរិតឧក្រិដ្ឋនៃ របបខ្មែរក្រហមបន្តិចម្ដងៗ គឺចាប់ផ្ដើមនៅពេលដែលគាត់ ឃើញការជម្លៀសប្រជាជន ការលុបបំបាត់កម្មសិទ្ធិឯកជន និងការសម្លាប់មនុស្សក្នុងទ្រង់ទ្រាយធំ[499]។ គាត់បានបន្ថែមថា នៅពេលដែលមានការចាប់មនុស្សជាឈុតត្រូវបានអនុវត្តក្រោមការប្រកាសរបស់ K គាត់ *"បានយល់ថាមនុស្សដែលបម្រើប្រជាជនអាចត្រូវបានចាប់ខ្លួន ក្នុងនាមជាជនក្បត់បក្ស*[500] "។ **ឌុច**បានបន្ថែមថា គាត់ចាប់ផ្ដើមមានអារម្មណ៍ព្រួយបារម្ភ និងភ័យខ្លាចចំពោះអាយុជីវិតរបស់គាត់ នៅពេលដែល J បញ្ជាឲ្យចាប់ខ្លួនបង LL និង MM ហើយដែលបន្ទាប់មកមានការចាប់ខ្លួនថ្នាក់លើមួយចំនួនទៀតដូចជា A[501]។ ឌុច បានអះអាងថា បន្ទាប់ពីការចាប់ខ្លួនអ្នកទាំងនោះ គាត់ចាប់ផ្ដើមភ័យស្លន់ស្លោរធ្វើអ្វីលែងកើត ហើយសួរខ្លួនឯងថា តើពេលណាដល់វេនខ្ញុំ[502]។ គាត់អះអាងទៀតថា ក្រោយពីព្រឹត្តិការណ៍នោះ គាត់កាន់តែមិនអាចមានលទ្ធភាពបំពេញការងាររបស់គាត់ ហើយគាត់បានផ្ទេរការងារសួរចម្លើយទាំងអស់ឲ្យទៅ C

ដោយគាត់នៅអង្គុយតែនៅក្នុងបន្ទប់ចម្លាក់តែប៉ុណ្ណោះ។ គាត់បានបញ្ជាក់ថា នៅចុងបញ្ចប់គាត់ខ្លាចរហូតដល់គិតតែពីដេកទាំងយប់ទាំងថ្ងៃ[503]។

១៧០. គាត់ក៏បានពន្យល់ទៀតថា ទាំងក្នុងអំឡុងពេលនៃរបបខ្មែរក្រហម និងក្រោយការដួលរលំនៃរបបនេះ ទោះបីជាគាត់ធ្លាប់បានព្យាយាមជាច្រើនលើកច្រើនសារក៏ដោយ ក៏គាត់មិនដែលបានទទួលជោគជ័យក្នុងការចាកចេញពីមុខតំណែងរបស់គាត់ទេ ព្រោះថាគាត់ឋិតនៅក្រោមការឃ្លាំមើលជាប្រចាំ និងដោយសារថា *"រត់គេចខ្លួន មានន័យស្មើស្លាប់សម្រាប់ខ្ញុំ និងគ្រួសារខ្ញុំ*[504] *"*។

## ឃ. កោសល្យវិច័យចិត្តសាស្ត្រ

១៧១. កោសល្យវិច័យចិត្តសាស្ត្រលើជនត្រូវចោទ ត្រូវបានបង្គាប់ឲ្យធ្វើ និងបានប្រគល់ការងារ នេះទៅឲ្យអ្នកជំនាញការអន្តរជាតិម្នាក់ ដែលជំនាញខាងផ្នែកចិត្តសាស្ត្រភូមិសាស្ត្រនយោបាយ (Psychologie géopolitique clinique) និងគ្រូពេទ្យចិត្តសាស្ត្រកម្ពុជាម្នាក់។ អ្នកជំនាញការទាំងនេះបានធ្វើសេចក្តីសន្និដ្ឋានថា ឌុច មិនមានរោគសញ្ញាផ្លូវចិត្តនោះទេ។ ឌុចទទួលខុសត្រូវចំពោះរាល់ទង្វើទាំងអស់របស់គាត់។ គាត់ជាមនុស្សមានប្រាជ្ញាវាងវៃ និងមានការចងចាំល្អ។ គាត់ជាមនុស្សដែលឆាប់ទទួល ឥទ្ធិពលពីខាងក្រៅ និងងាយរំភើប ចំពោះតែអ្វីដែលគាត់ធ្លាប់ទទួលការបំពាក់បំប៉ន់ផ្នែកមនោគមន៍វិជ្ជាពីមុនមកតែប៉ុណ្ណោះ។ ឌុច ប្រកាន់នូវឥរិយាបថឃ្លាតឆ្ងាយពីទង្វើ កាលពី អតីតកាលរបស់ខ្លួន និងបានបង្ហាញពីសមត្ថភាពដ៏ល្អរបស់គាត់ក្នុងការធ្វើវិភាគ។ ប៉ុន្តែទោះបីជា យ៉ាងណាក៏ដោយ ក៏ឥរិយាបថឃ្លាតឆ្ងាយ និងសមត្ថភាពវិភាគនេះ មិនអាចលាក់បាំង នូវគំនិតមនោគមន៍វិជ្ជាខ្មែរក្រហមរបស់គាត់ ដែលមានពេលខ្លះវាស្តែងឡើងតាមរយៈពាក្យសម្តី ការគិត ស្ថានភាពចិត្តសាស្ត្រ និងអាកប្បកិរិយារបស់គាត់។ បុគ្គលិកលក្ខណៈពីអតីតកាល និង បច្ចុប្បន្នរបស់ឌុច បានបង្ហាញថាគាត់ជាមនុស្សមានះ និងងប់ងុល។ គាត់ជាមនុស្សម្នាក់ដែលល្អិតល្អន់ មានមនសិការ និងចេះធ្វើឲ្យថ្នាក់លើរបស់ខ្លួន

ចាប់អារម្មណ៍។ ឌុចមានការលំបាកក្នុងការបង្ហាញពីអារម្មណ៍របស់ខ្លួនតាមរយៈពាក្យសម្ដី។ គាត់មានយន្តការការពារខ្លួនដ៏មានប្រសិទ្ធភាព ជាពិសេសគឺ៖ ភាពប្រទូស្តរ៉ាយរវាងការទទួល និងការបដិសេធតថភាព និងការប្រកែក។ ក៏ប៉ុន្តែនៅប៉ុន្មានឆ្នាំចុងក្រោយនេះ គេសង្កេតឃើញមានការវិវត្តន៍ជាវិជ្ជមានខ្លះហើយចំពោះចំនុចនេះ។ ការគិតវែងឆ្ងាយរបស់គាត់មានកម្រិតពោលគឺសមត្ថភាពក្នុងការគិតអំពីគំនិតរបស់អ្នកដទៃ។ អ្នកជំនាញការ បានលើកឡើងថា ទោះបីជាគាត់ឋិតក្នុងស្ថានភាព ដែលមិនសូវយល់អំពីអារម្មណ៍របស់អ្នកដទៃក៏ដោយ ក៏គាត់តែងតែសម្តែងនូវវិប្បដិសារីរបស់គាត់តាំងពីឆ្នាំ១៩៩៩ មកម្ល៉េះ។ ចំពោះសំណួរដែលសួរថាតើការសម្តែងការសោកស្តាយទាំងអស់នេះ ពិតជាបានផុសចេញពីឆន្ទៈពិតប្រាកដ ឬគ្រាន់តែជាទង្វើដែលធ្វើឡើងដើម្បីសម្របទៅនឹងកាលៈទេសៈ អ្នកជំនាញការបានបញ្ជាក់ថា សំណួរនេះ "*គ្មានចម្លើយទេ ព្រោះការពិតឋិតនៅក្រៅពីសម្មតិកម្មទាំងពីរនេះ*"។ អ្នកជំនាញការក៏បានបញ្ជាក់ទៀតដែរថា តាមគំនិតរបស់ពួកគេ *"សហគមន៍គ្រិស្តសាសនា សង្គមលោកខាងលិច ស្ថាប័នយុត្តិធម៌អន្តរជាតិ សុទ្ធសឹងជាយន្តការការពារដ៏ថ្មីមួយ (និយាយឲ្យចំ គឺដ៏មានប្រសិទ្ធភាពបំផុត) សម្រាប់បុគ្គលម្នាក់ដែលពុំមានសុវត្ថិភាពផ្លូវចិត្ត"*។ ចំពោះសំណួរដែលថា *"តើគាត់អាចនឹងធ្វើសមាហរណកម្ម ឬអាចសម្របខ្លួនចូលទៅក្នុងសង្គមបានដែរឬទេ?'* អ្នកជំនាញការបានឆ្លើយតបដោយវិជ្ជមាន តែបានបញ្ជាក់ថា វាអាស្រ័យទៅនឹងកត្តាបីយ៉ាងគឺ៖ លទ្ធផលនៃរឿងក្តី អាយុរបស់សាមីខ្លួន និងសន្តិសុខផ្ទាល់ខ្លួនរបស់គាត់[505]។

## ផ្នែកទី ៤៖ សេចក្ដីសម្រេច

**ជាលទ្ធផល** ការស៊ើបសួរបានបង្ហាញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ប្រឆាំងនឹង **កាំង ហ្គេក អ៊ាវ** ហៅ **ឌុច** ដែលតាមរយៈអំពើសកម្ម និង អកម្មរបស់ខ្លួននៅទីក្រុងភ្នំពេញ និង លើទឹកដីកម្ពុជា ក្នុងឋានៈជាអនុលេខា ឬ លេខា មន្ទីរ ស-២១ បានរៀបចំផែនការ បានញុះញង់ឲ្យប្រព្រឹត្ត បានបញ្ជា បានប្រព្រឹត្តបទឧក្រិដ្ឋដូចខាងក្រោម បានជួយ និង ជម្រុញដល់ចារីនៃបទឧក្រិដ្ឋទាំងនោះ ឬ ជាអ្នកទទួលខុសត្រូវក្នុងនាមជាមេកើយ ៖

**១- បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ** ដែលមាន៖

- ការធ្វើមនុស្សឃាត
- ការសម្លាប់រង្គាល
- ការធ្វើឱ្យទៅជាទាសករ
- ការដាក់ក្នុងមន្ទីរឃុំឃាំង
- ការធ្វើទារុណកម្ម
- ការរំលោភលើផ្លូវភេទ
- ការធ្វើទុក្ខបុកម្នេញ ដោយមូលហេតុនយោបាយ
- អំពើអមនុស្សធម៌ផ្សេងៗទៀត។

បទឧក្រិដ្ឋដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៥ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

**២- ការបំពារបំពានយ៉ាងធ្ងន់ធ្ងរលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី១២ ខែសីហា ឆ្នាំ១៩៤៩** ដែលមាន៖

- ការធ្វើមនុស្សឃាតដោយចេតនា
- ការធ្វើទារុណកម្ម ឬការធ្វើបាបដោយអមនុស្សធម៌
- ការបង្កដោយចេតនាឱ្យមានរបួសធ្ងន់ធ្ងរ ឬឱ្យមានការឈឺចាប់ដល់រាងកាយ ឬសុខភាព
- ការដកហូតដោយចេតនាពីឈ្លើយសឹក ឬជនស៊ីវិលនូវសិទ្ធិទទួលបានការកាត់ទោសដោយយុត្តិធម៌
- ការឃុំខ្លួនជនស៊ីវិលដោយខុសច្បាប់

បទឧក្រិដ្ឋដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៦ មាត្រា ២៩ (ថ្មី) និងមាត្រា ៣៩ (ថ្មី) នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ។

## ការបន្តការឃុំខ្លួន

**យល់ឃើញថា** លក្ខខណ្ឌដែលតម្រូវនៅក្នុងវិធាន ៦៣.៣ នៃវិធានផ្ទៃក្នុងរបស់អ.វ.ត.ក នៅតែត្រូវបានបំពេញ ហើយសំអាងហេតុរបស់អង្គបុរេជំនុំជម្រះនៅក្នុងសេចក្តីសម្រេចចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០០៧ (កឋាខ័ណ្ឌ ៣៧ ដល់ កឋាខណ្ឌ ៦១) នៅតែមានលក្ខណៈត្រឹមត្រូវ។ ដូចនេះជាការចាំបាច់ដែលត្រូវរក្សាជនជាប់ចោទនៅក្នុងឃុំរហូតដល់ការបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង ដើម្បី៖

- ធានាថាជនជាប់ចោទមានវត្តមាននៅក្នុងដំណាក់កាលសាលក្រម
- ការពារសុវត្ថិភាពរបស់ជនជាប់ចោទ
- រក្សាសណ្តាប់ធ្នាប់សាធារណៈ

## ហេតុដូច្នេះ

យោងដល់វិធាន ៦៧ និងវិធាន ៦៨ នៃវិធានផ្ទៃក្នុងនៃ អ.វ.ត.ក

សម្រេចដាក់អោយជាប់ចោទឈ្មោះ **កាំង ហ្គេក អ៊ាវ** ហៅ **ឌុច**

សម្រេចបញ្ជូនជននេះទៅអង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

សម្រេចបន្តការឃុំខ្លួនរហូតដល់ពេលបង្ហាញខ្លួនរបស់ជននេះនៅមុខអង្គជំនុំជម្រះសាលាដំបូង។

*ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ៨ ខែ សីហា ឆ្នាំ ២០០៨*

**សហចៅក្រមស៊ើបអង្កេត**

**Co-juges d'instruction**

ដីកានេះត្រូវបានតាក់តែងឡើងជាភាសាខ្មែរ និង បារាំង ហើយបកប្រែជាភាសាអង់គ្លេស។

---

1. [1]
2. [2]
3. [3]
4. [4]
5. [5]
6. [6]
7. [7]
8. [8]
9. [9]
10. [10]
11. [11]
12. [12]
13. [13]
14. [14]
15. [15]
16. [16]
17. [17]
18. [18]
19. [19]
20. [20]
21. [21]
22. [22]
23. [23]
24. [24]
25. [25]
26. [26]
27. [27]
28. [28]
29. [29]
30. [30]
31. [31]
32. [32]
33. [33]
34. [34]